- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការនៅក្នុងអង្គការនីតិប្រតិបត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងមុខតំណែងជាអនុរដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ២រូបៈ

១- លោកជំទាវ **ទេព សុទ្ធី**

២- ឯកឧត្តម **ស្វាយ សុវណ្ណារិទ្ធ**។

មាត្រា២ : តែងតាំងឯកឧត្តម **ឈឹម ភាន** ជាទីប្រឹក្សា នៃទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា៣ : តែងតាំងឯកឧត្តម **ទ៉ាន់ មុនីសុវណ្ណា** ជាជំនួយការ នៃទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា៤ : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០២៥

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ចរល. ៧៥០៣. ៤០១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានបង្ហាញត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៣២៥/ ៤០០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តាំងស៊ប់ទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រីដល់មន្ត្រីរាជការ **២៤** រូប ចាប់ពីថ្ងៃទី**១** ខែ**មករា** ឆ្នាំ**២០២៥**៖

១-លោក **សុរ សុជាតិ**	អនុមន្ត្រី	ថ្នាក់លេខ ៤
២-លោក **ផន ណាយេលីន**	អនុមន្ត្រី	ថ្នាក់លេខ ៤
៣-លោកស្រី **ឡាំ ម៉ីលីញ**	អនុមន្ត្រី	ថ្នាក់លេខ ៤
៤-លោកស្រី **ឡាំ ម៉ីលី**	អនុមន្ត្រី	ថ្នាក់លេខ ៤
៥-លោកស្រី **ជា លីស៊ាន**	អនុមន្ត្រី	ថ្នាក់លេខ ៤
៦-លោក **ស៊ាន រតនៈ**	អនុមន្ត្រី	ថ្នាក់លេខ ៤
៧-លោកស្រី **ហួន ពៅ**	អនុមន្ត្រី	ថ្នាក់លេខ ៤
៨-លោក **យ៉ាត សំណាង**	អនុមន្ត្រី	ថ្នាក់លេខ ៤

៩-លោក **សុ សុតា**	អនុមន្ត្រី	ថ្នាក់លេខ ៤
១០-លោកស្រី **ហុង ស៊ាងហ៊ាវ**	អនុមន្ត្រី	ថ្នាក់លេខ ៤
១១-លោក **សោ សិរីពន្លឺ**	អនុមន្ត្រី	ថ្នាក់លេខ ៤
១២-លោកស្រី **ថោង សុផាតារាចន្ទ្រី**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៣-លោកស្រី **ខូនរតនៈ សុជាតា**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៤-លោក **ជា បុញ្ញនិធិ**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៥-លោកស្រី **ឡុញ ដាណោ**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៦-លោក **នុត រក្សា**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៧-លោក **ឡោ បុរិន**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៨-លោក **ប៉ោ ឥន្ទ្រាប៊ុនីម៉ា**	អនុមន្ត្រី	ថ្នាក់លេខ ៤
១៩-លោកស្រី **ឈៀ សុជាតា**	អនុមន្ត្រី	ថ្នាក់លេខ ៤
២០-លោកស្រី **នៃ ច័ន្ទចិសាល**	អនុមន្ត្រី	ថ្នាក់លេខ ៤
២១-លោក **សេក ឧត្តម**	អនុមន្ត្រី	ថ្នាក់លេខ ៤
២២-លោកស្រី **ធីម ស្រីរ៉**	អនុមន្ត្រី	ថ្នាក់លេខ ៤
២៣-លោកស្រី **គួយ ហាឌ្យលីនណា**	អនុមន្ត្រី	ថ្នាក់លេខ ៤
២៤-លោក **រឹម សុខសុភ័ក្រ្ត**	អនុមន្ត្រី	ថ្នាក់លេខ ៤។

មាត្រា២ : សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២៥

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបន្ទាប់

ប្រមុខរដ្ឋស្តីទី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ពសរ. ២៥០៣. ៤០២

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

វង្សី វិស្សុត

ព្រះរាជក្រឹត្យ

នស/រកត/០៣២៥/៤០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ៦៣អង្គ/រូប៖

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១-ព្រះគ្រូវិជ្ជារតនវង្ស	អ៊ាង សុខនី	២-ភិក្ខុវិសេសោ	កែ ហេង
៣-ឧបាសក	ម៉េង ណង	៤-ឧបាសិកា	អន មុំ
៥-ឧបាសិកា	លី ស៊ូហ្គេច	៦-លោក	អ៊ីវ វិសាល
៧-ឧបាសិកា	សុង ចន្ថា	៨-ឧកញ៉ា	ថៃ ស្រ៊ុន
៩-លោកជំទាវ	ហ៊ាង ស៊ាងលី	១០-លោក	លី សុងហួរ
១១-លោកស្រី	ខូវ ស៊ុអេង	១២-ឧកញ៉ា	ហុង ហៀង
១៣-លោកជំទាវ	ទី អេង	១៤-ឯកឧត្តម	អ៊ឹង អៀង
១៥-លោកជំទាវ	ស្រ៊ុន សុខា	១៦-ឧបាសិកា	នាង ហួរ
១៧-ឧបាសក	ជីវ ស៊ូគុយ	១៨-ឧបាសិកា	អ៊ា គុយហុង
១៩-ឧបាសក	ឆេង គីមថា	២០-ឧបាសិកា	ជាន មួយឡេង

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍**

១-លោកជំទាវ	តាំង ហុងស៊ាម	២-ឧបាសិកា	លឹម ទាមធីង
៣-ឧកញ៉ា	ខូយ អ៊ាងឡាយ	៤-លោក	ហេង ប៊ុនខេង
៥-លោកស្រី	ហួង វួចឆេង	៦-ឧកញ៉ា	គង់ ប៊ុនហាវ
៧-លោកជំទាវ	អប់ សុភាព	៨-ឧកញ៉ា	ថៃ ឈុនគ្រី
៩-លោកជំទាវ	លី ឡាលីន	១០-ឧបាសក	លឹម ឆាយឃី
១១-លោក	អ៊ឹង គីមឈន	១២-លោកស្រី	លឹម ស៊ាវលី
១៣-ឧកញ៉ា	បេ លាងហ៊ុយ	១៤-លោកជំទាវ	ចាប ស្រីចាន់
១៥-លោក	អៀង ប៊ុនតេក	១៦-លោកស្រី	អ៊ឹង ស្រីឡៃ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

១-លោក	សែម ហាក់	២-លោក	ជុំ ពៅ

ឃ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

១-លោក	ហុង សេង	២-លោកស្រី	យិត គីមឈន់
៣-លោក	ជា គីមសាន	៤-លោកស្រី	គូ មួយអ៊ាង
៥-ឧកញ៉ា	លី គាង	៦-លោកស្រី	លី ស៊ូលី
៧-លោក	មាស ចំរើន	៨-លោកស្រី	ម៉ន ស៊ីណាត
៩-ឧបាសិកា	ឡាយ ហ្គេចស្រួយ	១០-ឧបាសក	គីវ ងីន
១១-លោក	លីម ហោសាន	១២-លោកស្រី	ខូវ ស៊ីវហៀង
១៣-ឧបាសិកា	ស៊ិន យ៉េកហួយ	១៤-ឧបាសក	ឆេង ទន់
១៥-ឧបាសិកា	ស៊ាង គីមជូ	១៦-ឧបាសិកា	គាន គឹមស្រាំង
១៧-ឧបាសិកា	ស៊ុយ សំខាន់	១៨-លោក	កាំង ហុក
១៩-លោកស្រី	ខូវ ស៊ីវហេង	២០-ឧបាសិកា	ប៊ិន់ យុម៉េង
២១-លោក	សឿន វណ្ណី	២២-លោកស្រី	ពឹង ពិសី
២៣-ឧបាសក	ពូន លាង		

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

១-លោក	គង់ ចាន់រិទ្ធី	២-លោក	ពៅ សារិទ្ធ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០២៥

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ពនស. ៥៥០៣.៤០៣

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ទន្យ វិស្សុត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២២ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរទ្រព្យសម្បត្តិរដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាន និងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១.-

ត្រូវបានផ្ទេរដីមួយផ្នែកទំហំ ៩៩ (កៅសិបប្រាំបួន) ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិដើមគរ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ (ដូចមានក្នុងសលាកប័ត្រក្បាលដីភ្ជាប់មកជាមួយ) របស់វិទ្យាស្ថានបច្ចេកទេស ហ្ស៊ី វ៉េ សេ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជូនអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រង និងប្រើប្រាស់។

មាត្រា២.-

ត្រូវបានអនុញ្ញាតឱ្យវិទ្យាស្ថានបច្ចេកទេស ហ្ស៊ី វ៉េ សេ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លុបទំហំដី ដែលបានផ្ទេរដូចមានចែងក្នុងមាត្រា ១ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ។

មាត្រា៣.-

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកត់ត្រាដីទំហំ ៩៩ (កៅសិបប្រាំបួន) ម៉ែត្រការ៉េ ចូលក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តាមនីតិវិធីជាធរមាន។

មាត្រា៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៤រោចខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្ទេរឥណទានថវិកា
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៤/០០៨ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៩១ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក និងតាមកម្មវិធីនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា១ .-

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាចំនួន ៣ ២៥៧,០លានរៀល (បីពាន់ពីររយហាសិបប្រាំពីរលានរៀលគត់) ពីជំពូក ៦០ (ការទិញ) ចំនួន ៣៦៤,៨លានរៀល និងជំពូក ៦១ (សេវាកម្ម) ចំនួន ២ ៨៩២,២លានរៀល មកជំពូក ៦៥ (ឧបត្ថម្ភធន) ជូនក្រសួងផែនការ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។

មាត្រា២ .-

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់បំពេញតម្រូវការទូទាត់ចំណាយលើការគាំទ្រដល់កិច្ចដំណើរការរបស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការក្នុងឆ្នាំ២០២៥។

មាត្រា៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស កំពតហ្វូណាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពបំពេញបន្ថែមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៣/២៥៦៤ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញអនុក្រឹត្យលេខ១៣៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្ដីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រេច

មាត្រា១ .-

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស កំពតហ្វូឈាន** ដែលមានទីតាំងស្ថិតនៅភូមិចង្ហោន សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត។

មាត្រា២ .-

តំបន់សេដ្ឋកិច្ចពិសេស កំពតហ្វូឈាន មានទំហំ ៧២១ ហិកតា ៣៨ អា និង ១៥ សង់ទីអា ដូចមានប្លង់បង្ហាញទីតាំងក្បាលដី និងតារាងនិយាមកាចំណុចព្រំដីភ្ជាប់ជាឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ។

មាត្រា៣ .-

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស កំពតហ្វូឈាន** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុនសម្រាប់ការអភិវឌ្ឍជាតំបន់សេដ្ឋកិច្ចពិសេស។

មាត្រា៤ .-

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស កំពតហ្វូឈាន** នេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា៥ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ស៊ុន ចាន់ថុល

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ប្លង់បង្ហាញទីតាំងក្បាលដីស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស របស់ក្រុមហ៊ុន កំពត ឡូជីស្ទីក អេន ឌីធ ឯ.ក

ភូមិសាស្ត្រស្ថិតនៅភូមិចង្ហោន សង្កាត់ព្រែកត្នោត ក្រុងបូកគោ ខេត្តកំពត



តារាងនិយាមកាចំណុចព្រំដី

Projection UTM, Zone 48N, Datum WGS 84.

Point_ID	Easting(m)	Northing(m)
1	388576.032	1168722.803
2	388578.910	1168763.687
3	388698.129	1168958.587
4	388785.571	1169013.577
5	389028.351	1169313.438
6	389034.119	1169318.291
7	389041.908	1169323.700
8	389045.933	1169325.660
9	389065.799	1169332.945
10	389085.457	1169335.837
11	389119.219	1169338.228
12	389136.371	1169335.495
13	389139.026	1169334.809
14	389221.610	1169288.340
15	389432.009	1169214.744
16	389470.460	1169197.784
17	389573.556	1169152.309
18	389596.237	1169120.556
19	389499.476	1168583.113
20	389495.931	1168563.421
21	389249.236	1167193.201
22	388182.401	1167238.725
23	388344.490	1168139.017
24	388494.930	1168462.191
25	388572.232	1168703.150
26	389631.578	1169034.672
27	389642.327	1168981.940
28	389697.276	1168966.413
29	389737.456	1168935.330
30	389856.582	1168810.437
31	389933.092	1168779.403
32	389940.804	1168715.564
33	389992.477	1168726.423
34	390043.878	1168726.354
35	390122.814	1168706.243
36	390195.356	1168699.223
37	390245.293	1168691.599
38	390297.094	1168661.560
39	390320.193	1168631.755
40	390337.804	1168597.560
41	390231.457	1167151.288
42	389299.653	1167191.050
43	389296.077	1167171.187
44	390229.991	1167131.347
45	390159.420	1166171.618
46	389129.825	1166247.774
47	389079.689	1166251.482
48	388018.786	1166329.954
49	388178.825	1167218.859
50	389245.660	1167173.338
51	388015.232	1166310.217
52	389076.131	1166231.718
53	388914.747	1165335.338
54	387853.396	1165411.325
55	389126.267	1166228.009
56	390157.954	1166151.671
57	390091.731	1165251.072
58	388964.904	1165331.747

ល.រ	លេខបណ្ណកម្មសិទ្ធិ	ក្រឡាផ្ទៃដី (ម៉ែត្រការ៉េ)
1	07071104-0300	949,900
2	07071104-0301	973,312
3	07071104-0302	964,987
4	07071104-0303	981,635
5	07071104-0304	931,259
6	07071104-0305	978,572
7	07071104-0307	500,514
8	07071104-0308	541,357
9	07071104-0309	392,279
	សរុប	7,213,815

សញ្ញាសំគាល់

- ចំណុចព្រំដី
- ផ្លូវជាតិលេខ៣
- ផ្លូវ
- ព្រំដី
- ក្បាលដីស្នើសុំ

ក្រឡាផ្ទៃដីសរុប : ៧២១ហិកតា ៣៨អា ១៥សង់ទីអា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៦០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៩/២៥៨ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាភូមិន្ទរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា១.-

ត្រូវបានតាំងស៊ប់ទៅក្នុងឋានន្តរស័ក្តិក្រមការ នៃក្របខណ្ឌមន្ត្រីក្រមការ នៅក្រសួងរ៉ែ និងថាមពល ដល់មន្ត្រីរាជការចំនួន ០៥ រូប ដែលបានបញ្ចប់ការសិក្សាពីសាលាភូមិន្ទរដ្ឋបាល ចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៤ ដូចមានរាយនាមខាងក្រោម៖

១-លោក	**ទ៉ាន់ តុលា**	ក្រមការ	ថ្នាក់លេខ ១
២-លោក	**អុល ម៉េងឡាង**	ក្រមការ	ថ្នាក់លេខ ១
៣-លោកស្រី	**ហ៊ិម ម៉ិនណា**	ក្រមការ	ថ្នាក់លេខ ១
៤-លោកស្រី	**ម៉ម រច្ចណី**	ក្រមការ	ថ្នាក់លេខ ១
៥-លោក	**កែវ រដ្ឋា**	ក្រមការ	ថ្នាក់លេខ ១។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៤ រោច ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦១ អនក្រ.តត

អនុក្រឹត្យ
ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ .-

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោក វ៉ន សំភាស់ នាយកប្រចាំប្រទេសនៃអង្គការ អេដ អេ អាកស្យុង ដែលបានចូលរួមចំណែកអភិវឌ្ឍវិស័យអប់រំ នៅស្រុកសង្កែ មោងឫស្សី ឯកភ្នំ និងស្រុកថ្មគោល ខេត្តបាត់ដំបងកន្លងមក។

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៤រោច ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៦២ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ .-

ត្រូវបានបំពាក់មេដាយ **មាសស្ថាបនាជាតិ** ជូនអង្គការដៃគូអភិវឌ្ឍចំនួន ៣អង្គការ បុគ្គលិកអង្គការ អេដ អេ អាកស្យុងចំនួន ១៣រូប និងសប្បុរសជនចំនួន ៣រូប ដែលបានចូលរួមចំណែកអភិវឌ្ឍវិស័យអប់រំ នៅស្រុកសង្កែ មោងឫស្សី ឯកភ្នំ និងស្រុកថ្មគោល ខេត្តបាត់ដំបងកន្លងមក ដូចមានរាយនាមខាងក្រោម៖

១- Education Above All Foundation

២- Action Education

៣- Aid et Action

៤- ឧកញ៉ា សយ សំរេច	សប្បុរសជន
៥- លោកវេជ្ជបណ្ឌិត សេង សាវេត	សប្បុរសជន
៦- លោក មិ ភ័ទ្ធ	សប្បុរសជន
៧- Mr. Gilles Delecourt	នាយកប្រតិបត្តិ អង្គការ អេដ អេ អាកស្យុង
៨- Mr. DIDIER PAUL JACQUES LAHAYE	ប្រធានគណៈកម្មាធិការនាយក
៩- លោកស្រី ទេព ចរិយា	នាយកហិរញ្ញវត្ថុ
១០- លោកស្រី ជឿន សុខុំ	នាយកហិរញ្ញវត្ថុ និងភាពជាដៃគូ អង្គការ អេដ អេ អាកស្យុង
១១- លោក ជា ច័ន្ទតារ៉ា	នាយកប្រតិបត្តិការ និងធនធានមនុស្ស
១២- លោក យិនសៀង សុមេធ	ប្រធានកម្មវិធីអប់រំ
១៣- លោក ហ៊ឹម សុវណ្ណារ៉ាក់	ប្រធានហិរញ្ញវត្ថុ និងភាពជាដៃគូ
១៤- លោក ធឹង ម៉ារ៉ុង	ប្រធានកម្មវិធី
១៥- លោកស្រី ខាត់ទី ឯកវិសុទ្ធ	ប្រធានកម្មវិធី
១៦- លោក ជុយ សាមីត	ប្រធានហិរញ្ញវត្ថុ និងភាពជាដៃគូ
១៧- Mr. Oskar Haq	ប្រធានកម្មវិធីជាន់ខ្ពស់
១៨- លោក អៀ ចុង	មន្ត្រីសម្របសម្រួលកម្មវិធី
១៩- លោកស្រី សុវណ្ណ លីដា	ប្រធានហិរញ្ញវត្ថុ

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

៤

សម្រេច

មាត្រា១ .-

ត្រូវបានដាក់លោក **គង់ ម៉េងស្រ៊ី** ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ៣ នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យចូលនិវត្តន៍មុនអាយុកំណត់តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៥។

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

សម្រេច

មាត្រា១ .-

ត្រូវបានដាក់លោក **លឹម សុគន្ធា** ឋានន្តរស័ក្តិវមន្ត្រី ថ្នាក់លេខ **១** នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងមុខងារសាធារណៈ ឱ្យចូលនិវត្តន៍មុនអាយុកំណត់តាមការស្នើសុំរបស់សាមីខ្លួន ចាប់ពីថ្ងៃទី**១** ខែ**មីនា** ឆ្នាំ**២០២៥**។

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :១៦៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

ជ

សម្រេច

មាត្រា១.-

ត្រូវបានតាំងស៊ប់ទៅក្នុងឋានន្តរស័ក្តិក្រមការ នៃក្របខណ្ឌមន្ត្រីក្រមការ នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់មន្ត្រីរាជការចំនួន **០៣ រូប** ដែលបានបញ្ចប់ការសិក្សាពីសាលាភូមិន្ទរដ្ឋបាល ចាប់ពី**ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៤** ដូចមានរាយនាមខាងក្រោម ៖

១-លោក **ឃី ពុទ្ធឌុន**	ក្រមការ	ថ្នាក់លេខ ១
២-លោក **គង់ ទិបុល**	ក្រមការ	ថ្នាក់លេខ ១
៣-លោក **សំ សុខឡាក់គី**	ក្រមការ	ថ្នាក់លេខ ១។

មាត្រា២.-

ត្រូវបានតាំងស៊ប់ទៅក្នុងឋានន្តរស័ក្តិក្រមការ នៃក្របខណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ដល់មន្ត្រីរាជការចំនួន **០៥ រូប** ដែលបានបញ្ចប់ការសិក្សាពីសាលាភូមិន្ទរដ្ឋបាល ចាប់ពី**ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៤** ដូចមានរាយនាមខាងក្រោម ៖

១-លោក **ឃឹម ទិចិត្រតារា**	ក្រមការ	ថ្នាក់លេខ ១
២-លោកស្រី **ពេជ្រ រត្សា**	ក្រមការ	ថ្នាក់លេខ ១
៣-លោក **ហេង ស្រេង**	ក្រមការ	ថ្នាក់លេខ ១
៤-លោក **ប៉ោ គឹមឡុង**	ក្រមការ	ថ្នាក់លេខ ១
៥-លោក **សុខ កុសល្យ**	ក្រមការ	ថ្នាក់លេខ ១។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៦៧ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៤៨ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៩នៃអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.តត ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

មាត្រា១ .–

ត្រូវបានតែងតាំងឯកឧត្តម **ហុង វ៉ាដា** តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាសមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ជំនួសឯកឧត្តម **គួក ហ្វីដេរ៉ូ** ដែលបានទទួលភារកិច្ចថ្មី។

មាត្រា២ .–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៥
នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦៨ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ .-

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូន Mr. Mark Ou សប្បុរសជន ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងស្រុកជីក្រែង ខេត្តសៀមរាប កន្លងមក។

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៦៩ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១ .-

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រី និងជំនួយការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ២៤រូប ដែលបានបំពេញភារកិច្ចយ៉ាងសកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

១- ឯកឧត្តម អ៊ឹង គ័ងហ៊ាង
២- លោក វណ្ណា អម្រឹត
៣- លោក គុប សារ៉ែន
៤- លោក ទួន ឧុល។

ចុ

ខ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

លោក វង្ស ម៉ៅប្ញូរ៉ូ។

គ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

១- លោកស្រី នង ម៉ាលីកា
២- លោក ថេង គីមឈា
៣- លោកស្រី នង ណានូ
៤- លោកស្រី ប៊ូ លក្ខិណា
៥- លោក សឿយ មុំរដ្ឋស័ក្ត
៦- លោក ម៉ា វុណ្ណាផានិត
៧- លោកស្រី សុន ចាន់នី
៨- លោក ហ៊ត់ បូរ៉ា
៩- លោកស្រី ម៉ា វុឌ្ឍាដាលីន
១០- លោក ខឺ ម៉ាន់ជីង
១១- លោកស្រី ជី ចិន្តា
១២- លោក សុខ ផងស៊ីង
១៣- លោកស្រី សុន វុទ្ធីអានីតា
១៤- លោក ជី ចិត្រា
១៥- លោក គីម វណ្ណាត
១៦- លោក ផល រឹទ្ធការៈ
១៧- លោក វ៉ុន សំនីត
១៨- លោក សុខុម ពៅ
១៩- លោក គុណ គីណា។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ .-

ត្រូវបានបំពាក់មេដាយ **មាសស្ថាបនាជាតិ** ជូនអង្គការ Good Neighbors Cambodia ដែលបានរួមចំណែកអភិវឌ្ឍវិស័យអប់រំនៅខេត្តបន្ទាយមានជ័យ ខេត្តរតនគិរី ខេត្តបាត់ដំបង ខេត្តក្រចេះ រាជធានីភ្នំពេញ តំបន់បណ្តែតទឹកលើបឹងទន្លេសាប និងវិស័យផ្សេងៗទៀត រយៈពេលចំនួន ២០ឆ្នាំកន្លងមក។

មាត្រា២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧១ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលសមាសភាពនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២៤/១២៣០ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤ ស្តីពីការផ្ទេរនិងតែងតាំងរដ្ឋលេខាធិការនៃក្រសួងទេសចរណ៍មកជារដ្ឋលេខាធិការនៃក្រសួងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៧២អនក្រ.តត ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលសមាសភាពនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

៥

- បានឃើញអនុក្រឹត្យលេខ ៨៦៦អនក្រ.តត ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

សម្រេច

មាត្រា១.-

ត្រូវបានតែងតាំងឯកឧត្តម **នាង ម៉ៅ** រដ្ឋលេខាធិការក្រសួងទេសចរណ៍ ជាសមាជិកគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា ជំនួសឯកឧត្តម **អ៊ុន វ៉ាល់ឡឺរ៉ូ**។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈ-កម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣៧២ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់មេដាយ **មាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ៤រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងសមិទ្ធផលនានាក្នុងស្រុកជីក្រែង ខេត្តសៀមរាប កន្លងមក ដូចមានរាយនាមខាងក្រោម៖

១- Mr. Peche Loo Chee Keong

២- លោក លី រិទ្ធី

៣- លោក លី វ៉ានី

ᕱ

៤- លោក អ៊ិត ប៉ូឡា។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើតខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៦ សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំពិធីបុណ្យទន្លេ លើកទី៩

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦៥ អនក្រ.បក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១៤ ស្តីពីពិធីបុណ្យទន្លេ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

សម្រេច

ប្រការ១ .-

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំពិធីបុណ្យទន្លេ លើកទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ ៩រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥ នៅខេត្តតាកែវ ក្រោមប្រធានបទ គុណតម្លៃនៃទន្លេ៖ ផ្សារភ្ជាប់វប្បធម៌ និងទេសចរណ៍ធម្មជាតិ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ហួត ហាក់**	រដ្ឋមន្ត្រីក្រសួងទេសចរណ៍	ប្រធាន
២- ឯកឧត្តម **អ៊ី សំណាង**	អភិបាលនៃគណៈអភិបាលខេត្តតាកែវ	អនុប្រធាន
៣- ឯកឧត្តម **ទិត ចន្ថា**	រដ្ឋលេខាធិការប្រចាំការ ក្រសួងទេសចរណ៍	អនុប្រធានអចិន្ត្រៃយ៍
៤- ឯកឧត្តម **ឃឿន ណារត**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
៥- ឯកឧត្តមសន្តិបណ្ឌិត **គៀត ច័ន្ទថារិទ្ធ**	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន
៦- ឯកឧត្តម **ឃី សុវណ្ណរតនា**	រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន
៧- ឯកឧត្តម **ឈន សុភាព**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អនុប្រធាន
៨- ឯកឧត្តម **ចាន់ ចេស្តា**	រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	អនុប្រធាន
៩- ឯកឧត្តម **សំហេង បូរ៉ា**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	អនុប្រធាន
១០- ឯកឧត្តម **ខ៊ូវ បូរីណា**	រដ្ឋលេខាធិការក្រសួងបរិស្ថាន	អនុប្រធាន
១១- ឯកឧត្តម **ភឹម គុណាវឌ្ឍន៍**	រដ្ឋលេខាធិការក្រសួងព័ត៌មាន	អនុប្រធាន
១២- ឯកឧត្តម **សូ ទិសុទ្ធី**	រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	អនុប្រធាន
១៣- ឯកឧត្តម **សាន់ សាប់អី**	រដ្ឋលេខាធិការក្រសួងសុខាភិបាល	អនុប្រធាន
១៤- ឯកឧត្តម **នូ សុវត្ថិ**	រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន	អនុប្រធាន
១៥- ឯកឧត្តម **ទិត ថាវរិទ្ធ**	រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	អនុប្រធាន
១៦- ឯកឧត្តម **ប៉ាក់ សុខុម**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
១៧- លោកជំទាវ **ហ៊ុន ដានី**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
១៨- ឯកឧត្តម **ហោ មុនីរ័ត្ន**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
១៩- ឯកឧត្តម **ហោ សារុន**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
២០- ឯកឧត្តម **តុប សុភ័ក**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
២១- ឯកឧត្តម **សុខ តុងហាប់**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
២២- លោកជំទាវ **ឡុង តិរម្យ**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
២៣- ឯកឧត្តម **នី ផល្លី**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
២៤- ឯកឧត្តម **គុជ បញ្ញាសា**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
២៥- ឯកឧត្តម **វ៉ាហេង ដាវុធ**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន

២៦- ឯកឧត្តម **ភាធី មហាំម៉ាត់ ណោសស្រី** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន
២៧- ឯកឧត្តម **នាង ម៉ៅ** រដ្ឋលេខាធិការក្រសួងទេសចរណ៍ អនុប្រធាន
២៨- ឯកឧត្តម **កែវ ស៊ីវន** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល អនុប្រធាន
២៩- ឯកឧត្តម **ម៉ាត់ ចំរើន** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អនុប្រធាន
៣០- ឯកឧត្តម **ឡេង ប៊ុនដែន** អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
៣១- ឯកឧត្តម **ខន សារណៈ** អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ សមាជិក
៣២- ឯកឧត្តមនាយឧត្តមសេនីយ៍ **ពិន ពិសិដ្ឋ** អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ សមាជិក
៣៣- ឯកឧត្តមឧត្តមសេនីយ៍ឯក **យឹម លាង** អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
៣៤- ឧត្តមសេនីយ៍ទោ **ស សំបូរធន** មេបញ្ជាការរង និងជានាយសេនាធិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
៣៥- លោក **គាំ ច័ន្ទកុសល** អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សមាជិក
៣៦- លោក **អ៊ុក នាង** ប្រធាននាយកដ្ឋានពិធីការនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
៣៧- ឧត្តមសេនីយ៍ឯក **ជុំ សាធុឡា** ប្រធាននាយកដ្ឋានអង្គរក្សនៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
៣៨- ឧត្តមសេនីយ៍ឯក **រុន រ័ត្នវាសនា** ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក។

ប្រការ២ .-

ទទួលស្គាល់តំណាងអង្គការ សង្គមស៊ីវិលឬសមាគម និងក្រុមហ៊ុនឯកជន សម្រាប់ធ្វើជាសមាជិកគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំពិធីបុណ្យទន្លេ លើកទី៩ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **សំហេង បុរស** សមាជិកអចិន្ត្រៃយ៍សហភាពសហព័ន្ធយុវជនកម្ពុជា(ស.ស.យ.ក.) សមាជិក
២- លោកជំទាវ **ឆាយ ស៊ីវលីន** ប្រធានសមាគមទេសចរណ៍កម្ពុជា សមាជិកា
៣- ឧកញ៉ា **ម៉ាន់ ឆារស័ជួន** តំណាងក្រុមហ៊ុនកាណាឌីយ៉ាគ្រុប សមាជិក
៤- ឧកញ៉ា **លូ ម៉េង** សហប្រធានផ្នែកឯកជនវិស័យទេសចរណ៍ សមាជិក
៥- តំណាងសមាគមឧកញ៉ាកម្ពុជា សមាជិក

៦- លោក **ជីប ឆក្តីភាព**	តំណាងសភាពាណិជ្ជកម្មកម្ពុជា	សមាជិក
៧- លោក **សេត គីមសឿន**	តំណាងសមាគមសិល្បករខ្មែរ និងជាតំណាងក្រុមហ៊ុន CBS	សមាជិក
៨- លោក **ហ៊ី សុធា**	ប្រធានសមាគមសណ្ឋាគារកម្ពុជា	សមាជិក
៩- កញ្ញា **ហោង ឆ្នួនហួង**	ប្រធានសមាគមភោជនីយដ្ឋានកម្ពុជា	សមាជិកា
១០- លោក **ខិន សុមេធារិទ្ធ**	ប្រធានសហព័ន្ធទេសចរណ៍កម្ពុជា	សមាជិក
១១- លោក **ឆួន ស៊ីណាន**	ប្រធានសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិក	សមាជិក
១២- លោក **Jean Claude Dhuez**	តំណាងសមាគមស្ប៉ា និងសុខុមាលភាពកម្ពុជា	សមាជិក
១៣- តំណាងក្រុមហ៊ុន VINCI នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ		សមាជិក
១៤- តំណាងក្រុមហ៊ុនសូស៊ីយេតេ កុងសេស្យូនែរ ដឺ ឡាអេរ៉ូព័រ		សមាជិក
១៥- កញ្ញា **Chiang Jo-Peng**	តំណាងក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា	សមាជិកា
១៦- តំណាងក្រុមហ៊ុនអាកាសចរណ៍អ៊ែរអេស៊ា(ខេមបូឌា) ឯ.ក		សមាជិក
១៧- លោក **Lu Xiaoqiang**	តំណាងក្រុមហ៊ុនអង្គរអ៊ិនធើណេសិនណល អ៊ែរផត អ៊ិនវេសមិន(ខេមបូឌា) ឯ.ក	សមាជិក
១៨- លោក **យ៉េង សីហា**	តំណាងទូរទស្សន៍ជាតិកម្ពុជា	សមាជិក
១៩- លោក **ប៉ុល សៀងវ៉ាលី**	តំណាងទូរទស្សន៍បាយ័ន	សមាជិក
២០- លោក **សាយ កែវសុខ**	តំណាងក្រុមហ៊ុន ឋោន អេនធើធេនមិនគ្រុប	សមាជិក
២១- តំណាងទូរទស្សន៍អប្សរាប៉ុស្តិ៍លេខ១១		សមាជិក
២២- តំណាងទូរទស្សន៍ហង្សមាស		សមាជិក។

ប្រការ៣ .-

គណៈកម្មការអន្តរក្រសួងនេះ មានតួនាទីនិងភារកិច្ចដឹកនាំ ចាត់ចែង និងត្រួតពិនិត្យដំណើរការរៀបចំពិធីបុណ្យទន្លេ លើកទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ ៩រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៥ នៅខេត្តតាកែវ ឱ្យមានប្រសិទ្ធភាពនិងទទួលបានជោគជ័យ។

ប្រការ៤ .-

អនុប្រធានអចិន្ត្រៃយ៍ អនុប្រធាន និងសមាជិកនៃគណៈកម្មការអន្តរក្រសួងនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈចាំបាច់ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ឱ្យដឹកនាំកិច្ចប្រជុំជំនួស។

ប្រធានគណៈកម្មការអន្តរក្រសួងនេះ អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអ្នកជំនាញពាក់ព័ន្ធផ្សេងៗទៀត ចូលរួមកិច្ចប្រជុំតាមការចាំបាច់។

ប្រការ៥ .-

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយចំនួនតាមការចាំបាច់ ដែលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំពិធីបុណ្យទន្លេ លើកទី៩។

ប្រការ៦ .-

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើត្រារបស់ក្រសួងទេសចរណ៍ ដើម្បីដំណើរការការងាររបស់ខ្លួន។

ប្រការ៧ .-

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ថវិការបស់ក្រសួងទេសចរណ៍ និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន។

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់និងឧបត្ថម្ភដល់ដំណើរការរៀបចំពិធីបុណ្យទន្លេ លើកទី៩។

ប្រការ៨ .-

គណៈកម្មការអន្តរក្រសួងនេះ ត្រូវរំសាយដោយស្វ័យប្រវត្តិនៅពេលចប់ភារកិច្ច។

ប្រការ៩ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១០ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣ រោច ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៧៧ សសរ

សេចក្តីសម្រេច
ស្តីពី
ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៩៤ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

ប្រការ១ .-

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្មដូចខាងក្រោម៖

១- លោកជំទាវ **ចម និម្មល**	រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	ប្រធាន
២- ឯកឧត្តម **សុខ សុផាក្រ្គ**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	អនុប្រធានអចិន្ត្រៃយ៍
៣- ឯកឧត្តម **ឡេង សេខ**	រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធាន
៤- ឯកឧត្តម **ម៉ែន សំអាត**	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អនុប្រធាន
៥- ឯកឧត្តម **កែ គី**	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	សមាជិក
៦- ឯកឧត្តម **ជីវ សុខហាក់**	រដ្ឋលេខាធិការក្រសួងយុត្តិធម៌	សមាជិក
៧- ឯកឧត្តម **ហូ ស៊ីវយ៉ុខ**	ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម	សមាជិក
៨- ឯកឧត្តម **គីម មាសសុខសីហា**	អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម	សមាជិក
៩- ឯកឧត្តម **ឡុង កែមវិចិត្រ**	អគ្គនាយកនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម	សមាជិក
១០- ឯកឧត្តម **សរ សិនិរ៉ា**	អគ្គលេខាធិការរងនៃគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
១១- លោកជំទាវ **ប៊ុន នារី**	អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ	សមាជិកា
១២- លោក **ចាន់ សុភាព**	អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា	សមាជិក
១៣- លោក **សៀង ហុង**	ប្រធានលេខាធិការដ្ឋាននៃ **គ.ជ.ឧ.ព.**	សមាជិក។

ប្រការ២ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៨ សសរ

សេចក្តីសម្រេច
ស្តីពី
ការដាក់ឱ្យអនុវត្តកម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួន នៅតំបន់ភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពី ការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ១.-

ត្រូវបានដាក់ឱ្យអនុវត្ត «កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨» ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

ប្រការ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួន នៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨

ខែ មករា ឆ្នាំ ២០២៥

អារម្ភកថា

ការគិតគូរលើការអភិវឌ្ឍប្រកបដោយចីរភាព និងមានបរិយាប័ន្ន និងកិច្ចខិតខំប្រឹងប្រែងបែងចែកភាគលាភនៃកំណើនសេដ្ឋកិច្ច គឺជាចំណោទបញ្ហាដែលរដ្ឋាភិបាលនៅលើពិភពលោកត្រូវយកចិត្តទុកដាក់ជាប្រចាំ។ បន្ទាប់ពីកម្ពុជាទទួលបានសន្តិភាពពេញលេញនៅឆ្នាំ ១៩៩៨ តាមរយៈភាពជោគជ័យនៃនយោបាយ **ឈ្នះ-ឈ្នះ** ដែលបានផ្តួចផ្តើម និងអនុវត្ត ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាអតីតនាយករដ្ឋមន្ត្រី, ភាគលាភនៃសន្តិភាពបានផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាល អាចប្រមូលផ្តុំធនធានភាគច្រើនដើម្បីចំណាយលើការអភិវឌ្ឍនៅគ្រប់វិស័យ។ សមិទ្ធផលរបស់រាជរដ្ឋាភិបាលអាណត្តិមុនៗ ដែលបានកើតឡើងតាមរយៈការអនុវត្តដោយជោគជ័យនៃ **យុទ្ធសាស្ត្រត្រីកោណ** និង **យុទ្ធសាស្ត្រចតុកោណ** ទាំង ៤ ដំណាក់កាល, បានផ្លាស់ប្តូរមុខមាត់កម្ពុជា គួរឱ្យកត់សម្គាល់លើគ្រប់ទិដ្ឋភាព ហើយសូចនាករសេដ្ឋកិច្ច-សង្គម ជាច្រើនត្រូវបានកែលម្អ ប្រកបដោយមោទនភាព។ លើសពីការបង្កើតសន្តិភាព និងអភិវឌ្ឍសេដ្ឋកិច្ចជាតិខ្លួន, តួនាទីរបស់កម្ពុជា នៅក្នុងរបៀបវារៈនៃការកសាងសន្តិភាព និងជំរុញការអភិវឌ្ឍប្រកបដោយចីរភាព នៅក្នុងតំបន់ ក៏មានការទទួលស្គាល់ជាអន្តរជាតិ។ ទាំងនេះគឺជាមត៌កនៃការកសាងជាតិ ដែលរាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ត្រូវបន្តថែរក្សា និងពង្រឹងបន្ថែមទៀត តាមរយៈការដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១** ដើម្បីបន្តដឹកនាំប្រទេសកម្ពុជា ឱ្យកាន់តែសម្បូរសប្បាយរុងរឿង ស្របតាម **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០**។

ពិតណាស់ថា ធនធានរបស់យើងមានកំណត់ ដូច្នេះ ល្បឿននៃការអភិវឌ្ឍ និងរបាយនៃការអភិវឌ្ឍ ពុំអាចកើតមានឡើងស្មើៗគ្នា នៅទូទាំងប្រទេសភ្លាមៗ តាមអ្វីដែលយើងចង់បាននោះឡើយ។ តំបន់ដែលនៅឆ្ងាយៗ ជាពិសេស តំបន់ភូមិភាគឦសាន រួមមាន ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ទាមទារឱ្យមានការគិតគូរជាពិសេសដោយឡែក។ តំបន់ភូមិភាគឦសាន គឺជាតំបន់ដែលមានវិសាលភាពដីបង្កបង្កើនផលធំទូលាយ និងសម្បូរទៅដោយធនធានធម្មជាតិ។ ក្នុងអាណត្តិមុនៗ, រាជរដ្ឋាភិបាលបានខិតខំយកចិត្តទុកដាក់លើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីតភ្ជាប់តំបន់នេះដែលនៅឆ្ងាយពីមជ្ឈមណ្ឌលនៃកំណើន ឬប៉ូលសេដ្ឋកិច្ចសំខាន់ៗ។ ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ បានរួមចំណែកយ៉ាងសំខាន់នៅក្នុងការជួយសម្រួលដល់ការតភ្ជាប់តំបន់នេះ ជាមួយនឹងចរន្តសេដ្ឋកិច្ច និងពាណិជ្ជកម្មផ្ទៃក្នុងប្រទេស ក៏ដូចជាជាមួយបណ្តាប្រទេសជាប់ព្រំដែន។ ដើម្បីបង្កើនចរន្តសេដ្ឋកិច្ចសម្រាប់តំបន់នេះបន្ថែមទៀត, កាលពីខែសីហា ឆ្នាំ២០២៤ ខ្ញុំបានអំពាវនាវឱ្យវិស័យឯកជនបង្កើនការវិនិយោគឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ហើយបានណែនាំឱ្យគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) ដែលមាន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន, ដឹកនាំរៀបចំការសិក្សា និងបង្កើតកម្មវិធីពិសេសមួយសម្រាប់តំបន់ភូមិភាគឦសាន។

«**កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨**» គឺជាលទ្ធផលនៃការសិក្សាស្រាវជ្រាវ ការចូលរួមផ្តល់ធាតុចូល និងការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ ពីសំណាក់ភាគីពាក់ព័ន្ធជាច្រើន

ទាំងក្នុងកម្រិតជាតិ និងថ្នាក់ក្រោមជាតិនៃវិស័យសាធារណៈ, ព្រមទាំងភាគីជាច្រើននៃវិស័យឯកជន ក៏ដូចជាប្រជាសហគមន៍។ កម្មវិធីពិសេសនេះ គឺជាឯកសារដ៏មានសារៈសំខាន់ នៅក្នុងការចង្អុលបង្ហាញវិស័យអាទិភាពចំនួន ៣ គឺកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ដែលស្របតាមទាយជ្ជទានដែលមានស្រាប់របស់ខេត្តទាំងបួន ដែលគួរជំរុញការវិនិយោគបន្ថែម ដោយមានការគាំទ្រយ៉ាងទូលំទូលាយពីរាជរដ្ឋាភិបាល។ កម្មវិធីពិសេសនេះបានគូសបញ្ជាក់យ៉ាងច្បាស់នូវការលើកទឹកចិត្តដ៏ច្រើនដែលរាជរដ្ឋាភិបាលអាចផ្តល់ជូនវិស័យឯកជន ហើយក៏មានការគិតគូរពីការផ្តល់ហិរញ្ញប្បទានដែលមានអត្រាការប្រាក់សមរម្យ, ការជួយកាត់បន្ថយថ្លៃដើមផលិតកម្ម,ការសម្រួលនីតិវិធី និងការគាំទ្រសកម្មភាពវិនិយោគឯកជនផងដែរ។

ក្នុងន័យនេះ, ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន គ.ស.ហ. ដែលបានដឹកនាំរៀបចំកម្មវិធីពិសេសនេះឡើង។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ការសហការគាំទ្រប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ពីសំណាក់ថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកធ្វើឱ្យការរៀបចំកម្មវិធីពិសេសនេះ កាន់តែមានភាពជាក់ស្តែងនិយម, ចំគោលដៅ និងអាចអនុវត្តបាន។

ជាទីបញ្ចប់, ខ្ញុំសូមប្រកាសដាក់ឱ្យប្រើប្រាស់ «**កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅតំបន់ភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨**» និងស្នើឱ្យគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ ចូលរួមអនុវត្តកម្មវិធីពិសេសនេះ ប្រកបដោយស្មារតីទទួលខុសត្រូវ, និងមានភាពម្ចាស់ការ ដើម្បីសម្រេចជោគជ័យ ស្របតាមគោលបំណង និងគោលដៅដែលបានដាក់ចេញ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងភាពរីកចម្រើនរុងរឿង ប្រកបដោយបរិយាប័ន្ន នៅក្នុងបណ្តាខេត្តនៅជាប់ព្រំដែន ក្នុងដំណើរប្រកបដោយក្តីសង្ឃឹមរបស់កម្ពុជា ឆ្ពោះទៅរកចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០។

ថ្ងៃសុក្រ ១០រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
នៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

មាតិកា

អារម្ភកថា ១

១. សេចក្តីផ្តើម ៣

២. ទិដ្ឋភាពទូទៅនៃបណ្តាខេត្តក្នុងតំបន់ភូមិភាគឦសាន ៤

២.១ ខេត្តក្រចេះ ៤

២.២ ខេត្តស្ទឹងត្រែង ៥

២.៣ ខេត្តរតនគិរី ៥

២.៤ ខេត្តមណ្ឌលគិរី ៦

៣. សក្តានុពល និងបញ្ហាប្រឈមចម្បងៗ ៦

៣.១ សក្តានុពល ៦

៣.២ បញ្ហាប្រឈមចម្បងៗ ៧

៤. គោលគំនិត «៣.៣.៣» នៃការរៀបចំកម្មវិធីពិសេស ៨

៤.១ ទស្សនាទាន ៣ .... ៨

៤.២ វិស័យអាទិភាព ៣ .... ៨

៤.៣ វិធានការគាំទ្រ និងជំរុញការវិនិយោគ ៣ ប្រភេទ ៩

៥. វិធានការ និងលក្ខខណ្ឌវិនិច្ឆ័យទទួលបានការគាំទ្រ និងជំរុញ ការវិនិយោគ ៩

៦. យន្តការអនុវត្ត, តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ១៤

៧. សេចក្តីសន្និដ្ឋាន ១៥

៨. ឧបសម្ព័ន្ធអំពីវិធានការគាំទ្រ និងជំរុញការវិនិយោគ ១៧

១ សេចក្តីផ្តើម

ក្រោមម្លប់ដ៏សែនត្រជាក់នៃសុខសន្តិភាពពេញបរិបូរណ៍ ដែលកម្ពុជាទទួលបាននៅឆ្នាំ ១៩៩៨ តាមរយៈ នយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងអតីតនាយករដ្ឋមន្ត្រី, នាំកម្ពុជាបានបោះពួយយ៉ាងលឿន លើមាគ៌ានៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ប្រកបដោយភាពវិជ្ជមាន និងក្តីសង្ឃឹម។ សន្តិភាពបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ជាមួយនឹងការដាក់ចេញ និងអនុវត្តប្រកបដោយប្រសិទ្ធភាព និងសង្គតិភាព នូវគោលនយោបាយអភិវឌ្ឍន៍ជាតិសំខាន់ៗជាបន្តបន្ទាប់ តួយ៉ាងដូចជា យុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណទាំង ៤ ដំណាក់កាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា និងកម្មវិធីកែទម្រង់សំខាន់ៗ សំដៅលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ក្រោមការដឹកនាំដ៏ប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ មរតកសន្តិភាព ក្នុងរយៈពេលជាង ២០ ឆ្នាំកន្លងមក គឺជាបុព្វលក្ខខណ្ឌ និងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ហើយផ្លែផ្កាទាំងនេះបានហុចផលដល់ប្រជាជនកម្ពុជា តាមរយៈវឌ្ឍនភាពនៃសូចនាករសេដ្ឋកិច្ច-សង្គម លើគ្រប់វិស័យ។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងថាមវន្តរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានដាក់ចេញនូវ **«យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១»** សំដៅបន្តកសាងមូលដ្ឋានសេដ្ឋកិច្ច-សង្គមកម្ពុជា ឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០។ ក្នុងនោះផងដែរ, បញ្ចកោណទី២ បានគូសរំលេចពីសារៈសំខាន់នៃ **«ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង»** ហើយមុំទី១ បានផ្តោតការយកចិត្តទុកដាក់លើ **«ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច»**។

ផ្អែកលើស្មារតីនេះ, រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ចេញនូវ **«កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨»** ដើម្បីដាក់ទិសដៅអាទិភាពវិនិយោគ និងអភិវឌ្ឍន៍ សម្លឹងឆ្ពោះទៅទិសឦសាន ដែលជាការគិតគូរមានលក្ខណៈជាយុទ្ធសាស្ត្រ ពោលគឺជំរុញការពង្រីកមូលដ្ឋានសេដ្ឋកិច្ចចំពោះបណ្តាខេត្តដែលនៅឆ្ងាយពីមជ្ឈមណ្ឌលកំណើន ក៏ដូចជាជំរុញការតភ្ជាប់នៃចរន្តសេដ្ឋកិច្ចជាតិ។ កម្មវិធីពិសេសនេះ នឹងក្លាយជាទិសដៅគោលនយោបាយ ដែលមានសារៈសំខាន់ មិនត្រឹមតែជំរុញការវិនិយោគ និងអភិវឌ្ឍន៍តំបន់ភូមិភាគឦសានប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងចូលរួមពង្រីកមូលដ្ឋានសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពកំណើនថ្មីរបស់សេដ្ឋកិច្ចជាតិជារួម ស្របតាមសេចក្តីប៉ងប្រាថ្នារបស់រាជរដ្ឋាភិបាល ដូចបានចង្អុលបង្ហាញក្នុងយុទ្ធសាស្ត្របញ្ចកោណ។

កម្មវិធីពិសេសនេះ បានកំណត់យកវិស័យអាទិភាពចំនួន ៣ គឺកសិកម្ម កសិ-ឧស្សាហកម្ម និង ទេសចរណ៍ ដែលស្របតាមទាយជ្ជទានដែលមានស្រាប់របស់ខេត្តទាំងបួននៅភូមិភាគឦសាន រួមមាន ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី។ កម្មវិធីពិសេសនេះ បាន[illegible]

ច្បាស់នូវការលើកទឹកចិត្តដ៏ច្រើនដែលរាជរដ្ឋាភិបាលអាចផ្ដល់ជូនវិស័យឯកជន ហើយក៏មានការគិតគូរពីការផ្ដល់ហិរញ្ញប្បទានដែលមានអត្រាការប្រាក់សមរម្យ, ការជួយកាត់បន្ថយថ្លៃដើមផលិតកម្ម, ការសម្រួលនីតិវិធី និងការគាំទ្រសកម្មភាពវិនិយោគឯកជនផងដែរ។

២. ទិដ្ឋភាពទូទៅនៃបណ្ដាខេត្តក្នុងតំបន់ភូមិភាគឦសាន

ខេត្តទាំងបួននៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា (ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី) ជាខេត្តដែលមានសក្ដានុពល ក្នុងន័យថាខេត្តទាំងនេះមានកត្តាទាយជ្ជទាន (Factor Endowment) ដែលធ្វើឱ្យមានភាពអំណោយផលដល់វិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍។ ដំណាំកសិកម្ម និងកសិ-ឧស្សាហកម្មយុទ្ធសាស្ត្រក្នុងខេត្តទាំងបួន មានដូចជា៖ កៅស៊ូ ស្វាយចន្ទី ដំឡូងមី ម្រេច ស្វាយ និងចេកអំបូងលឿង ជាដើម, ដែលសុទ្ធសឹងជាផលិតផលកសិផលមានសក្ដានុពលទាំងទីផ្សារនាំចេញ និងទីផ្សារក្នុងស្រុក។ ជាមួយគ្នានេះ, ភាពអំណោយផលនៃសម្បត្តិវប្បធម៌ធម្មជាតិ (ឧទា. អាកាសធាតុ ខ្យល់បរិសុទ្ធ ធនធានធម្មជាតិដ៏សម្បូរបែប, ព្រៃឈើ និងដែនជម្រកសត្វព្រៃ ជាដើម) បានធ្វើឱ្យខេត្តទាំងបួន ក្លាយជាតំបន់ដែលមានសក្ដានុពលទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍ផងដែរ។ ទោះជាយ៉ាងនេះ, ខេត្តទាំងនេះក៏នៅតែមានបញ្ហាប្រឈមជារចនាសម្ព័ន្ធមួយចំនួន ដែលតម្រូវឱ្យរាជរដ្ឋាភិបាលបន្តគិតគូរ និងដោះស្រាយ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចខេត្ត ដោយផ្អែកលើកត្តាទាយជ្ជទាន។

២.១ ខេត្តក្រចេះ

ខេត្តក្រចេះមានផ្ទៃដី ១១ ០៩៤ គីឡូម៉ែត្រការ៉េ និងចែកជា ៦ ស្រុក (ស្រុកស្នួល ស្រុកសំបូរ, ស្រុកព្រែកប្រសព្វ ស្រុកចិត្របុរី ស្រុកឆ្លូង និងស្រុកអូរគ្រៀងសែនជ័យ) និង ក្រុងចំនួន ១ (ក្រុងក្រចេះ)។ ផ្អែកតាមទិន្នន័យឆ្នាំ ២០២៣ ខេត្តក្រចេះមានប្រជាជនសរុប ៤៤៧ ៣៣០ នាក់ និងដង់ស៊ីតេប្រជាជន ៤០ នាក់/គីឡូម៉ែត្រការ៉េ។ សេដ្ឋកិច្ចនៃខេត្តនេះ ពឹងអាស្រ័យលើវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ជាចម្បង។ ចំពោះវិស័យកសិកម្ម ខេត្តក្រចេះមានផ្ទៃដីដាំដុះសរុប ១៧០ ៦២៨ ហិកតា ដែលក្នុងនោះដំណាំចម្បងៗ រួមមាន៖ ដំឡូងមី (១ ៥២៩ ៦៩១ តោន) ស្រូវ (១៨១ ០៦៤ តោន) ស្វាយចន្ទី (៩៣ ០៣០ តោន) កៅស៊ូ (៧៥ ៦៥៤ តោន) និងដំណាំឈើហូបផ្លែដូចជា ចេកអំបូងលឿង (៤៩ ១២០ តោន) ខ្នុរ (១២ ៩៦០ តោន) និងក្រូចថ្លុង (៩ ៣១០ តោន)។ ខេត្តក្រចេះ មានតំបន់សេដ្ឋកិច្ចពិសេសមួយនៅស្រុកស្នួល (តំបន់សេដ្ឋកិច្ចពិសេស យូ ប៊ី អ៊ី ស្នួល) ជិតព្រំដែនកម្ពុជា-វៀតណាម ដែលជាតំបន់ឧស្សាហកម្មចម្បងសម្រាប់ខេត្តភូមិភាគឦសាន។ តំបន់សេដ្ឋកិច្ចពិសេសនេះមានទំហំ ៨១៧ ហិកតា និងមានក្រុមហ៊ុនសរុបចំនួន ៧ ដែលក្នុងនោះ ក្រុមហ៊ុនកំពុងដំណើរការ និងសាងសង់មានចំនួន ៣ (ក្រុមហ៊ុនផលិតសំបកកង់យានយន្តចំនួន ២, និងក្រុមហ៊ុនផលិតចំហាយទឹក និងខ្យល់ក្ដៅចំនួន ១)។ ចំពោះវិស័យទេសចរណ៍, ខេត្តក្រចេះសម្បូរទៅដោយរមណីយដ្ឋានទេសចរណ៍ធម្មជាតិ និងវប្បធម៌ ដែលបច្ចុប្បន្នមានចំនួន ២៤ កន្លែង។ [illegible] អន្លង់ផ្សោត និងរមណីយដ្ឋានទឹកជ្រោះកាំពី សុទ្ធសឹងជាតំបន់ទេសចរណ៍ដែលមាន[illegible]ពេញនិយមក្នុងខេត្ត។ ទន្ទឹមនេះ, តំបន់ទេសចរណ៍បែបសហគមន៍លើកោះ សុទ្ធសឹងជាតំ[illegible]

អាចអភិវឌ្ឍបន្ថែម។ ក្នុងឆ្នាំ ២០២៣, មានភ្ញៀវទេសចរ ២៣៣ ៤៦១ នាក់ បានមកកម្សាន្តនៅខេត្តក្រចេះ ដោយក្នុងនោះ ២១៩ ៨៩២ នាក់ ជាភ្ញៀវជាតិ និង ១៣ ៥៦៩ នាក់ ជាភ្ញៀវអន្តរជាតិ។

២.២ ខេត្តស្ទឹងត្រែង

ខេត្តស្ទឹងត្រែងមានផ្ទៃដី ១២ ០១៦ គីឡូម៉ែត្រការ៉េ និងចែកជា ៥ ស្រុក (ស្រុកថាឡាបរិវ៉ាត់, ស្រុកសេសាន ស្រុកសៀមប៉ាង ស្រុកសៀមបូក និងស្រុកបូរីអូរស្វាយសែនជ័យ) និង ក្រុងចំនួន ១ (ក្រុងស្ទឹងត្រែង)។ ខេត្តនេះមានប្រជាជនសរុបចំនួន ១៨៣ ៥៦៨ នាក់ (ឆ្នាំ ២០២៣) និងដង់ស៊ីតេប្រជាជន ១៥,៣ នាក់/គីឡូម៉ែត្រការ៉េ។ សេដ្ឋកិច្ចនៃខេត្តស្ទឹងត្រែង ពឹងអាស្រ័យលើវិស័យកសិកម្មជាចម្បង។ ផ្ទៃដីដាំដុះសរុបក្នុងខេត្តមានចំនួន ១៥០ ៣៦៧ ហិកតា និងមានកសិផលសំខាន់ៗដូចជា៖ ដំឡូងមី (៥៩៩ ០៩៧ តោន) ស្រូវ (៧២ ២៧០ តោន) ស្វាយចន្ទី (៤៧ ៣៨៨ តោន) កៅស៊ូ(៧ ៤៤២ តោន) និងចេកអំបូងលឿង (៤៨ ០០០ តោន)។ ទន្ទឹមនេះ, វិស័យទេសចរណ៍ក៏ជាវិស័យសក្តានុពលផងដែរ ដោយខេត្តស្ទឹងត្រែងមានទន្លេចំនួន ៤ ហូរកាត់ (ទន្លេមេគង្គ ទន្លេសេកុង ទន្លេសេសាន និងទន្លេស្រែពក) ដែលបង្កជាលក្ខណៈអំណោយផលដល់ទេសចរណ៍ធម្មជាតិតាមដងទន្លេ។ ជាក់ស្តែង, ក្នុងឆ្នាំ២០២៣ មានភ្ញៀវទេសចរជាង ៤២ ១២៨ នាក់ បានមកកម្សាន្តនៅខេត្តស្ទឹងត្រែង ដោយក្នុងនោះ ៤១ ៣២១ នាក់ ជាភ្ញៀវជាតិ និង ៨០៧ នាក់ ជាភ្ញៀវអន្តរជាតិ។ ដោយឡែក, តំបន់ទេសចរណ៍ក្នុងខេត្តនៅពុំទាន់ត្រូវបានអភិវឌ្ឍឱ្យបានអស់សក្តានុពលនៅឡើយ ដែលមានរមណីយដ្ឋានទេសចរណ៍ ដូចជា តំបន់ឧទ្យានជាតិវីរៈជ័យ, សហគមន៍អេកូទេសចរណ៍ត្បូងខ្លា, តំបន់រ៉ាមសារមេគង្គ និងតំបន់ទេសចរណ៍ធម្មជាតិផ្សេងៗដែលមានសម្រស់ស្អាត និងគួរជាទីមនោរម្យចំពោះភ្ញៀវទេសចរបែបធម្មជាតិ ប៉ុន្តែនៅខ្វះខាតហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងធនធានហិរញ្ញវត្ថុក្នុងការអភិវឌ្ឍ។

២.៣ ខេត្តរតនគិរី

ខេត្តរតនគិរី ជាតំបន់ភ្នំ ដែលមានផ្ទៃដីសរុប ១០ ៧៨២ គីឡូម៉ែត្រការ៉េ ចែកចេញជា ៨ ស្រុក (ស្រុកកូនមុំ ស្រុកអូរយ៉ាដាវ ស្រុកបរកែវ ស្រុកលំផាត់ ស្រុកអូរជុំ ស្រុកវើនសៃ ស្រុកអណ្តូងមាស និងស្រុកតាវែង) និង ក្រុងចំនួន ១ (ក្រុងបានលុង)។ ខេត្តរតនគិរី មានប្រជាជនសរុបចំនួន ២៣១ ០២៧ នាក់ (ឆ្នាំ ២០២៣) និងមានដង់ស៊ីតេប្រជាជនចំនួន ២១,៤៣ នាក់/គីឡូម៉ែត្រការ៉េ។ សេដ្ឋកិច្ចនៃខេត្តរតនគិរីមួយផ្នែកធំ គឺផ្អែកលើវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងវិស័យទេសចរណ៍។ ចំពោះវិស័យកសិកម្ម ខេត្តរតនគិរីមានផ្ទៃដីដាំដុះសរុបចំនួន ១១៨ ៨២៧ ហិកតា។ ដំណាំសំខាន់ៗដែលខេត្តនេះ ផលិតបានក្នុងឆ្នាំ ២០២៣ រួមមាន៖ ដំឡូងមី (៤២៥ ៧៦៨ តោន) ចេកអំបូងលឿង (១៦១ ៧៥៤ តោន) កៅស៊ូ (៦៥ ៤៦០ តោន) និងស្វាយចន្ទី (៣៥ ១៨១ តោន)។ ក្នុងវិស័យកសិ-ឧស្សាហកម្ម ខេត្តនេះមានរោងចក្រចំនួន ៨ រោងចក្រ ក្នុងនោះមាន រោងចក្រកែច្នៃកៅស៊ូ (៤) រោងចក្រកែច្នៃចេក (២) រោងចក្រដំឡូងមី (១) និងរោងចក្រកែច្នៃចម្រុះ កៅស៊ូ ដូងប្រេង និងផ្សិតឈើ (១) រួមទាំងសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មជាច្រើនទៀត។ ចំណែកវិស័យទេសចរណ៍ ខេត្តរតនគិរី មានរមណីយដ្ឋានទេសចរណ៍សរុប ២៧ កន្លែង រួមមាន រមណីយដ្ឋានទេសចរណ៍ធម្មជាតិ

(២០ កន្លែង) រមណីយដ្ឋានវប្បធម៌ (២ កន្លែង) និងរមណីយដ្ឋានកែច្នៃ (៥ កន្លែង)។ លើសពីនេះ, ខេត្តរតនគិរី ក៏មាននូវវប្បធម៌ជនជាតិដើមភាគតិចដែលជាចំណុចទាក់ទាញសម្រាប់ទេសចរណ៍វប្បធម៌។ យោងតាមទិន្នន័យក្នុងឆ្នាំ ២០២៣, ខេត្តរតនគិរី ទទួលបានភ្ញៀវទេសចរជាតិចំនួន ៧ ៨១៥ នាក់ និងភ្ញៀវទេសចរអន្តរជាតិចំនួន ២៩៣ ០៨៩ នាក់។ ជារួម, ខេត្តរតនគិរីមានសក្តានុពលលើដំណាំកសិ-ឧស្សាហកម្ម និងទេសចរណ៍ធម្មជាតិដែលអាចកែច្នៃបន្ថែមបាន ដើម្បីជំរុញកំណើនភ្ញៀវទេសចរដែលនិយមតំបន់ទេសចរណ៍បែបព្រៃភ្នំ។

២.៤ ខេត្តមណ្ឌលគិរី

ខេត្តមណ្ឌលគិរីមានផ្ទៃដី ១៤ ២៨៨ គីឡូម៉ែត្រការ៉េ និងចែកជា ៤ ស្រុក (ស្រុកកែវសីមា ស្រុកកោះញែក ស្រុកពេជ្រាដា និងស្រុកអូររាំង) និង ក្រុងចំនួន ១ (ក្រុងសែនមនោរម្យ)។ ប្រជាជនសរុបក្នុងខេត្តមានចំនួន ១០០ ២៣៧ នាក់ (ឆ្នាំ ២០២៣) ជាមួយនឹងដង់ស៊ីតេប្រជាជន ៧ នាក់/គីឡូម៉ែត្រការ៉េ។ សេដ្ឋកិច្ចនៃខេត្តមណ្ឌលគិរី ពឹងអាស្រ័យលើវិស័យធំៗចំនួន ២ គឺ វិស័យកសិកម្ម និងវិស័យទេសចរណ៍ ដោយសារតែកត្តាដីមានជីជាតិ និងភាពអំណោយផលនៃសម្បត្តិធម្មជាតិ (ជាតុ-អាកាសត្រជាក់ ខ្យល់បរិសុទ្ធ ក៏លស្មៅបៃតង និងទេសភាពព្រៃភ្នំស្អាតៗ)។ ចំពោះវិស័យកសិកម្មក្នុងឆ្នាំ ២០២៣ ខេត្តមណ្ឌលគិរីមានផ្ទៃដីដាំដុះសរុបចំនួន ១២៨ ២៣៩ ហិកតា ដែលក្នុងនោះកសិផលចម្បងៗ មានដូចជា៖ ដំឡូងមី (៣២០ ៩៤២ តោន) ស្រូវ (១០៦ ៩៦៥ តោន) កៅស៊ូ (២៥ ៦៤៣ តោន) ស្វាយចន្ទី (៩ ៦២២ តោន) និងសណ្តែកបាយ (៥ ៥២៨ តោន)។ ទន្ទឹមនេះ, ខេត្តមណ្ឌលគិរីក៏មានលក្ខណៈពិសេសដោយឡែកខុសប្លែកពីតំបន់ដទៃ ដែលមានភាពអំណោយផលដល់ការដាំដុះផលិតផលកសិកម្មផ្សេងទៀត ជាពិសេស ផ្កា បន្លែ និងផ្លែឈើ ដូចមានចង្អុលបង្ហាញក្នុងចក្ខុវិស័យនៃផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ ខេត្តមណ្ឌលគិរី ២០២១-២០៣៥។ ចំពោះវិស័យទេស-ចរណ៍វិញ ខេត្តមណ្ឌលគិរីសម្បូរទៅដោយ តំបន់ទេសចរណ៍ធម្មជាតិបែបទឹកជ្រោះ និងព្រៃភ្នំ ដូចជាទឹកជ្រោះប៊ូស្រា ទឹកជ្រោះជ្រៃធំ ទឹកជ្រោះរមនា ទឹកជ្រោះមនោរម្យ ដែនជម្រកសត្វព្រៃភ្នំណាមលៀរ និងភ្នំដោះក្រមុំ ជាដើម។ ក្នុងឆ្នាំ ២០២៣, ខេត្តមណ្ឌលគិរី ទទួលភ្ញៀវទេសចរចំនួនប្រមាណ ២៦៦ ៤២២ នាក់ ក្នុងនោះភ្ញៀវទេសចរជាតិមានចំនួន ២៦១ ៤៩៤ នាក់ និងភ្ញៀវទេសចរអន្តរជាតិមានចំនួនប្រមាណ ៤ ៩២៨ នាក់។ ជារួម, ខេត្តនេះ មានសក្តានុពលខ្លាំងលើវិស័យកសិកម្ម និងទេសចរណ៍ ដោយសារកត្តាទាយជ្ជទានធម្មជាតិអំណោយផល និងចំនួនអាជីវកម្មទេសចរណ៍ដែលមានលទ្ធភាពពង្រីកបន្ថែមដើម្បីទទួលកំណើនភ្ញៀវទេសចរ។

៣. សក្តានុពល និងបញ្ហាប្រឈមចម្បងៗ

៣.១ សក្តានុពល

តំបន់ភូមិភាគឦសាន មានលក្ខណៈពិសេសដែលអំណោយផលខ្ពស់ដល់វិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ជាពិសេសទេសចរណ៍ធម្មជាតិ និងទេសចរណ៍អត្តសញ្ញាណពិសេស (Unique Identity Tourism)។ ទេសចរណ៍អត្តសញ្ញាណពិសេស គឺចង់សំដៅលើផលិតផលទេសចរណ៍វប្បធម៌, ធម្មជាតិ និងប្រវត្តិសាស្ត្រ ដែលមានលក្ខណៈពិសេសដោយឡែកសម្រាប់តំបន់

និងតំបន់ភូមិភាគឦសាន, និង/ឬ ដែលមានតែនៅក្នុងប្រទេសកម្ពុជា នៅលើពិភពលោក ដើម្បីបង្កើតភាពទាក់ទាញខុសប្លែកពីខេត្តដទៃផ្សេងទៀត ដែលសម្បូរទៅដោយសម្បត្តិវប្បធម៌, ធម្មជាតិ និងប្រវត្តិសាស្ត្រដែរ។ ចំពោះវិស័យកសិកម្ម ដំណាំដែលជាសក្តានុពលក្នុងខេត្តទាំងបួន រួមមានជាអាទិ៍ កៅស៊ូ ស្វាយចន្ទី ដំឡូងមី ចេកអំបូងលឿង បន្លែ ផ្លែឈើ និងផ្កា។ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មនៅទីវាល ក៏អាចជាសក្តានុពលបន្ថែមក្នុងវិស័យកសិកម្មផងដែរ។ ជាសរុបក្នុងខេត្តទាំងបួន, ក្នុងឆ្នាំ ២០២៣ បើធៀបនឹងទិន្នផលសរុបតាមប្រភេទដំណាំនីមួយៗទូទាំងប្រទេស, បរិមាណផលកៅស៊ូ (១៧៤ ១៩៩ តោន) ស្មើនឹង ៤៤,៤៦% បរិមាណផលស្វាយចន្ទី (១៨៥ ២២១ តោន) ស្មើនឹង ៣៧,៤២% បរិមាណផលដំឡូងមី (២ ៨៧៥ ៤៩៨ តោន) ស្មើនឹង ២០,២៧% និងបរិមាណផលចេកអំបូងលឿង (២៥៨ ៨៧៤ តោន) ស្មើនឹង ៧៧,១០%។

ទិន្នន័យវិស័យកសិកម្ម ឆ្នាំ ២០២៣						
	ក្រចេះ	ស្ទឹងត្រែង	រតនគិរី	មណ្ឌលគិរី	សរុប	ធៀបនឹងទូទាំងប្រទេស
ផ្ទៃដីដាំដុះសរុប (ហិកតា)	១៧០ ៦២៨	១៥០ ៣៦៧	១១៨ ៨២៧	១២៨ ២៣៩	៥៦៨ ០៦១	១០,៣១ %
បរិមាណផលិតកម្មសរុប (តោន)						
កៅស៊ូ	៧៥ ៦៥៤	៧ ៤៤២	៦៥ ៤៦០	២៥ ៦៤៣	១៧៤ ១៩៩	៤៤,៤៦ %
ស្វាយចន្ទី	៩៣ ០៣០	៤៧ ៣៨៨	៣៥ ១៨១	៩ ៦២២	១៨៥ ២២១	៣៧,៤២ %
ដំឡូងមី	១ ៥២៩ ៦៩១	៥៩៩ ០៩៧	៤២៥ ៧៦៨	៣២០ ៩៤២	២ ៨៧៥ ៤៩៨	២០,២៧ %
ចេកអំបូងលឿង	៤៩ ១២០	៤៨ ០០០	១៦១ ៧៥៤	-	២៥៨ ៨៧៤	៧៧,១០ %

ប្រភពទិន្នន័យ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងខេត្តទាំងបួន

ទន្ទឹមគ្នានេះ, ខេត្តទាំងបួននៅភូមិភាគឦសាននេះក៏សម្បូរទៅដោយតំបន់ទេសចរណ៍ និងចំណុចទាក់ទាញទេសចរណ៍ (attractions) ប្លែកៗ ដូចជា ផ្សោតទឹកសាប សត្វទោចថ្ពាល់លឿង ស្វាកន្ទុយស សត្វត្មាត តំបន់រ៉ាមសារ វប្បធម៌ជនជាតិដើមភាគតិច និងតំបន់ស្លាកស្នាមប្រវត្តិសាស្ត្រ ដែលចំណុចទាក់ទាញទាំងនេះ អាចត្រូវបានប្រើប្រាស់ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍អត្តសញ្ញាណពិសេស (Unique Identity Tourism)។ ជាតួលេខ, ចំនួនភ្ញៀវទេសចរ ទាំងភ្ញៀវជាតិ និងអន្តរជាតិ ដែលបានទៅកម្សាន្តក្នុងខេត្តទាំងបួននេះ ក្នុងឆ្នាំ ២០២៣ មានចំនួន ៨៤២ ៩១៥ នាក់ ឬប្រមាណ ៣% នៃភ្ញៀវទេសចរសរុបទូទាំងប្រទេស។

៣.២ បញ្ហាប្រឈមចម្បងៗ

បើទោះបីតំបន់ភូមិភាគឦសានមានសក្តានុពលខ្ពស់ ជាពិសេសខាងវិស័យកសិកម្ម គុសិឧស្សាហកម្ម និងទេសចរណ៍យ៉ាងណាក្តី ក៏ខេត្តនីមួយៗហាក់មិនទាន់អាចទាញយក[illegible]ពីសក្តានុពល និងកត្តាទាយជ្ជទានទាំងនេះឱ្យបានជាអតិបរមានៅឡើយ។ ជាក់ស្តែង [illegible]

ផលិតកម្មកែច្នៃផលិតផលកសិ-ឧស្សាហកម្មនៅតំបន់នេះ គឺនៅមានកម្រិត និងក្នុងទ្រង់ទ្រាយតូច (small scale) ហើយមានលក្ខណៈរាយប៉ាយ។ កសិផលសំខាន់ៗ ជាពិសេស កៅស៊ូ ស្វាយចន្ទី ដំឡូងមី និងចេកអំបូងលឿង ដែលសុទ្ធសឹងជាដំណាំសក្តានុពលក្នុងបណ្តាខេត្តទាំងនេះ ស្ទើរតែទាំង-អស់គឺត្រូវបាននាំចេញជាវត្ថុធាតុដើម (raw materials) ទៅប្រទេសជិតខាង ដែលធ្វើឱ្យបាត់បង់តម្លៃបន្ថែមក្នុងសេដ្ឋកិច្ច។ ក្រៅពីវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម, តំបន់ទាំងនេះក៏មានលក្ខខណ្ឌអំណោយផលខ្ពស់លើវិស័យទេសចរណ៍ ប៉ុន្តែការវិនិយោគ (ផ្នែកផ្គត់ផ្គង់) និងទំហំភ្ញៀវទេសចរ (ផ្នែកតម្រូវការ) ទៅទស្សនានៅបណ្តាខេត្តទាំងនេះ គឺនៅមានកម្រិតទាប។

ការមិនទាន់អាចទាញយកប្រយោជន៍ពីកត្តាទាយជ្ជទានទាំងនេះ ឧទា. ឧបសគ្គក្នុងការទាក់-ទាញវិនិយោគិន និងភ្ញៀវទេសចរ បណ្តាលមកពីបញ្ហាប្រឈមចម្បងៗ មួយចំនួន៖ ថ្លៃអគ្គិសនីមិនមានភាពប្រកួតប្រជែង, អត្រាការប្រាក់ខ្ពស់, កង្វះហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់សំខាន់ៗ កង្វះកម្លាំងពលកម្មទាំងជំនាញ, បរិមាណ និងគុណភាព,បញ្ហាការចុះបញ្ជីដីធ្លី, បញ្ហាសម្បទានដីសេដ្ឋកិច្ចអសកម្ម, បញ្ហានៃការគ្រប់គ្រងរបស់សហគមន៍ទេសចរណ៍ និងកង្វះការចូលរួមពីវិស័យឯកជន។

៤. គោលគំនិត «៣.៣.៣» នៃការរៀបចំកម្មវិធីពិសេស

ជាលក្ខណៈគោលគំនិត, កម្មវិធីពិសេសមានលក្ខណៈសម្គាល់ **«៣.៣.៣»** ពោលគឺ **ទស្សនាទាន ៣**, **វិស័យអាទិភាព ៣** និង **វិធានការគាំទ្រ និងជំរុញការវិនិយោគ ៣ ប្រភេទ**។

៤.១ ទស្សនាទាន ៣

ទី១. កែប្រែមុខមាត់ខេត្តទាំងបួន ឱ្យទៅជាខេត្តដែលមានមូលដ្ឋានសេដ្ឋកិច្ចពឹងផ្អែកលើកសិកម្ម, កសិ-ឧស្សាហកម្ម, និងទេសចរណ៍ យោងលើកត្តាទាយជ្ជទានរបស់ខេត្ត-នីមួយៗ និងដោយមានភាពប្រទាក់ក្រឡាជាមួយនឹងគោលនយោបាយជាតិផ្សេងៗ,

ទី២. ដោះស្រាយបញ្ហាប្រឈមជាក់ស្តែងដែលនាំមកនូវលទ្ធផលឆាប់រហ័ស (Low-hanging and intermediate measures) ជាពិសេសកត្តាជំរុញការទាក់ទាញវិនិយោគឯកជន និង;

ទី៣. ជំរុញសហថាមពលដែលកើតចេញពីការប្រមូលផ្តុំ (Clustering Effects) ដើម្បីឈានទៅអភិវឌ្ឍសេដ្ឋកិច្ចមាត្រដ្ឋាន (Economies of Scale) ជាជាងការវិនិយោគដែលមានលក្ខណៈរាយប៉ាយ និងមិនអាចផ្សារភ្ជាប់គ្នាបាន។

៤.២ វិស័យអាទិភាព ៣

ទី១. កសិកម្ម៖ ផ្តោតលើការដាំដុះដំណាំកសិកម្មសំខាន់ៗ ដែលមានសក្តានុពលសេដ្ឋកិច្ចបូករួមទាំង ផ្កា បន្លែ ផ្លែឈើ និងឈើដាំ និងការចិញ្ចឹមសត្វជាលក្ខណៈ [illegible] នៅទីវាល;

ទី២. កសិ-ឧស្សាហកម្មៈ ផ្ដោតលើការកែច្នៃ និង/ឬ វេចខ្ចប់ (processing and/or packaging) នៃផលិតផលគន្លឹះ ដាអាទិ៍ កៅស៊ូ ស្វាយចន្ទី ដំឡូងមី ចេកអំបូង-លឿង ផ្លែឈើ និងឈើដាំ និង;

ទី៣. ទេសចរណ៍ៈ ផ្ដោតលើទេសចរណ៍អត្តសញ្ញាណពិសេស (Unique Identity Tourism) ដែលសំដៅលើការខិតខំអភិវឌ្ឍផលិតផលទេសចរណ៍វប្បធម៌ ធម្មជាតិ និងប្រវត្តិ-សាស្ត្រ ដែលមានលក្ខណៈពិសេសដោយឡែកសម្រាប់តែខេត្ត និងតំបន់ភូមិភាគ-ឦសាន, និង/ឬ ដែលមានតែនៅក្នុងប្រទេសកម្ពុជា នៅលើពិភពលោក ដើម្បីបង្កើតភាពទាក់ទាញខុសប្លែកពីខេត្តដទៃផ្សេងទៀត ដែលសម្បូរទៅដោយសម្បត្តិវប្បធម៌, ធម្មជាតិ និងប្រវត្តិសាស្ត្រដែរ។ ឧទាហរណ៍ដូចជាៈ អន្លង់ផ្សោតទឹកសាប នៅខេត្ត-ក្រចេះ និងស្ទឹងត្រែង, សត្វទោចថ្ពាល់លឿង (southern yellow-cheeked crested gibbons) និង ស្វាកន្ទុយស (black-shanked douc langurs) នៅដែនជម្រកសត្វព្រៃកែវសីមា ខេត្តមណ្ឌលគិរី និងក្នុងឧទ្យានជាតិវីរៈជ័យ ក្នុងខេត្តរតនគិរី, តំបន់រ៉ាមសារ នៅខេត្តស្ទឹងត្រែង, សត្វត្មាតនៅដែនជម្រកសត្វព្រៃសៀមប៉ាង ក្នុងខេត្ត-ស្ទឹងត្រែង, វប្បធម៌ និងជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច, ជ្រោះសុកមិត្រ និងតំបន់ស្លាកស្នាមប្រវត្តិសាស្ត្រ (តំបន់ប្រើប្រាស់ច្រើនយ៉ាងសសរស្ដម្ភសត្វតោ) ជាដើម។ ជាមួយគ្នានេះ, វិស័យអាទិភាពនេះក៏ផ្ដោតលើសកម្មភាពមួយចំនួនដូចជា ការបង្កើតតំបន់អេកូទេសចរណ៍, ការបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋ, ការបង្កើតសួនភូតគាម (សួនបូតានិក) ឬសួនទេសចរណ៍ ឬសួនសត្វ ឬសកម្មភាពអភិរក្សជីវៈចម្រុះ និងធនធានសេនេទិក, និងការបង្កើតរមណីយដ្ឋានដែលមានសេវាកម្មចម្រុះ (រួមមានជាអាទិ៍ សេវាកម្ម ដូចជាសណ្ឋាគារ សួនកម្សាន្ត កន្លែងហាត់កីឡា និងសួនសត្វ)។

៤.៣ វិធានការគាំទ្រ និងជំរុញការវិនិយោគ ៣ ប្រភេទ

ទី១. វិធានការផ្នែកពន្ធដារ និងពន្ធគយ;

ទី២. ការផ្ដល់ហិរញ្ញប្បទានក្រោមអត្រាការប្រាក់សមរម្យ និង;

ទី៣. ការជួយកាត់បន្ថយថ្លៃដើមផលិតកម្ម,ការសម្រួលនីតិវិធី និងការគាំទ្រសកម្មភាពវិនិ-យោគឯកជន។

៥. វិធានការ និងលក្ខខណ្ឌវិនិច្ឆ័យទទួលបានការគាំទ្រ និងជំរុញការវិនិយោគ

វិធានការគាំទ្រ និងជំរុញការវិនិយោគនេះ នឹងត្រូវបានអនុវត្តចំពោះ គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច ដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.វ.ស.គ.), គម្រោងពង្រីកនៃ គ.ល.គ. ដែលមានស្រាប់, គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍កសិកម្មទំនើប និង គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ដែលត្រូវបានចុះ

ដំណើរការ នៅក្នុងឆ្នាំ ២០២៥ ដល់ ២០២៨ នៅក្នុងខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ឬខេត្តមណ្ឌលគិរី។ ជាមួយគ្នានេះ, ក្នុងគោលដៅជំរុញសកម្មភាពវិនិយោគ ជាពិសេសកៀគរមូលធនវិនិយោគក្នុងស្រុក ដើម្បីទាញយកឧត្តមប្រយោជន៍ឱ្យបានជាអតិបរមា, រាជរដ្ឋាភិបាលនឹងរៀបចំលិខិតបទដ្ឋានគតិយុត្តកំណត់លក្ខខណ្ឌបន្ទុកបន្ថយពិសេសជាច់ដោយឡែក សំដៅបើកផ្លូវឱ្យសកម្មភាពធុរកិច្ចទូទៅ (ដែលមិនមែនជា គ.ល.គ.) អាចស្នើសុំជា គ.ល.គ. ដើម្បីធ្វើការវិនិយោគនៅភូមិភាគឦសានក្នុងឆ្នាំ ២០២៥-២០២៨ ជាមួយនឹងការទទួលបាននូវការលើកទឹកចិត្តដូច គ.ល.គ.។

វិធាននៃការផ្តល់ការលើកទឹកចិត្តចំពោះ គ.ល.គ. ពាក់ព័ន្ធទៅនឹងផលិតកម្ម និងការកែច្នៃកសិផល ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ត្រូវតែមានសង្គតិភាព និងសម្របជាមួយនឹងក្របខណ្ឌនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង និងអភិវឌ្ឍលើមុខទំនិញយុទ្ធសាស្ត្រសំខាន់ៗ។

១ វិធានការផ្នែកពន្ធដារ និងពន្ធគយ

ក- <u>គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចជា គ.ល.គ. ក្នុងវិស័យទូទៅ ក្រៅពីវិស័យអាទិភាព នឹងទទួលបានការលើកទឹកចិត្តវិនិយោគ ដូចខាងក្រោម៖</u>

- លើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ៣ ឆ្នាំបន្ថែម ដោយរយៈពេលលើកលែងពន្ធត្រូវគិតចាប់ពីពេល ដែលគម្រោងមានចំណូលពីសកម្មភាពអាជីវកម្មដំបូង;
- អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិតកម្ម ដែលផលិតក្នុងស្រុក;
- លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង;
- លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្សប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួន នៅភូមិភាគឦសាន។

ខ- <u>គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច ក្នុងវិស័យអាទិភាព៖</u>

គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច របស់សហគមន៍កសិកម្មទំនើប ក្នុងវិស័យកសិកម្ម និង គ.ល.គ. ក្នុងវិស័យកសិ-ឧស្សាហកម្ម ស្របតាមអាទិភាពដែលបានកំណត់ ព្រមទាំង គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ ក្នុងវិស័យទេសចរណ៍ រួមមាន ការបង្កើតតំបន់ទេសចរណ៍អត្តសញ្ញាណពិសេស, ការបង្កើតតំបន់អេកូទេសចរណ៍, ការបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋ, ការបង្កើតសួនភូតគាម (សួនបូតានិក) ឬសួនទេសចរណ៍ ឬសួនសត្វ ឬសកម្មភាពអភិរក្សជីវៈចម្រុះនិងការបង្កើតរមណីយដ្ឋានដែលមានសេវាកម្មចម្រុះ (រួមមានជាអាទិ៍ សេវាកម្មដូចជា សណ្ឋាគារ សួនកម្សាន្ត កន្លែងហាត់កីឡា និងសួនសត្វ) នឹងទទួលបានការលើកទឹកចិត្តវិនិយោគ ដូចខាងក្រោម៖

- លើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ១២ ឆ្នាំ ដោយរយៈពេលលើកលែងពន្ធត្រូវគិតចាប់ពីឆ្នាំដែលគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចមានចំណូលពីសកម្មភាពអាជីវកម្មដំបូង;
- ចំពោះ គ.ល.គ. ឬ គម្រោងវិនិយោគឬសកម្មភាពធុរកិច្ចរបស់សហគមន៍កសិកម្មទំនើប ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម, ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋលើការនាំចូលសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម;
- ចំពោះ គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ ក្នុងវិស័យទេសចរណ៍, ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋលើការនាំចូលសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈ-បរិក្ខារផលិតកម្ម;
- អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិត-កម្ម ដែលផលិតក្នុងស្រុក;
- លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង;
- លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្ស ប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួន នៅភូមិភាគឦសាន។

គ- **<u>គម្រោងពង្រីកនៃ គ.ល.គ. ក្នុងឆ្នាំ ២០២៥-២០២៨ នឹងទទួលបានការលើកទឹកចិត្ត វិនិយោគ ដូចខាងក្រោម៖</u>**

- លើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ៣ ឆ្នាំបន្ថែម ពីលើរយៈពេលជាក់លាក់ណាមួយ ទៅតាមប្រភេទក្រុមសកម្មភាព វិនិយោគដើម ផ្អែកតាមសមាមាត្រនៃអត្រាទុនពង្រីក ស្របតាមអនុក្រឹត្យស្តីពីការអនុវត្ត ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា;
- អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិត-កម្ម ដែលផលិតក្នុងស្រុក;
- លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង;
- លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្ស ប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួន នៅភូមិភាគឦសាន។

<u>សម្គាល់</u>៖ និយមន័យ និងវិធីគណនាទុនពង្រីក ត្រូវអនុវត្តដូចគ្នាទៅនឹងវិធានដូចមានចែងក្នុងប្រកាសលេខ ៣១៣ សហវ.ប្រក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះគម្រោងពង្រីកនៃ គ.ល.គ.។

ឃ- <u>សកម្មភាពធុរកិច្ច ដែលមិនទាន់បានចុះបញ្ជីពន្ធដារ៖</u>

សម្រាប់សកម្មភាពធុរកិច្ច ដែលកំពុងដំណើរការ តែមិនទាន់បានចុះបញ្ជីពន្ធដារ ត្រូវទៅចុះ-បញ្ជីពន្ធដារ តាមនីតិវិធីជាធរមានដោយស្ម័គ្រចិត្ត ក្នុងឆ្នាំ ២០២៥ នឹងទទួលបានការលើកលែង ពិន័យទោសទណ្ឌ បំណុលពន្ធ (រួមមាន ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់) និងការផាកពិន័យជាប្រាក់ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ដែលអនុលោមតាមយុទ្ធសាស្ត្រជាតិ ស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨។

ទន្ទឹមនេះ, ដើម្បីទទួលបានការលើកទឹកចិត្តបន្ថែម ដូចមានក្នុងវិធានការផ្អែកពន្ធដារ និងពន្ធគយ, សកម្មភាពធុរកិច្ច ដែលបានចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ត្រូវចុះបញ្ជីជា គ.ល.គ. ក្នុងឆ្នាំ ២០២៥ ស្របតាមលិខិតបទដ្ឋានគតិយុត្តកំណត់លក្ខខណ្ឌបន្ធូរបន្ថយនៃការចុះបញ្ជីជា គ.ល.គ. ក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃកម្មវិធីពិសេសនេះ។

ង- <u>គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច ដែលមិនទទួលបានការលើកទឹកចិត្ត</u>

ចំពោះគម្រោងវិនិយោគធំៗ, គម្រោងវិនិយោគ និងសកម្មភាពធុរកិច្ច ដែលមានវេទយិតភាពរួមបញ្ចូលគម្រោងដែលមានទីតាំងនៅក្បែរព្រំដែន ត្រូវអនុវត្តដោយនីតិវិធីដោយឡែក។ ចំពោះគម្រោងវិនិយោគ និងសកម្មភាពធុរកិច្ចផ្សេងទៀត ដែលស្ថិតនៅក្រៅវិសាលភាពនៃកម្មវិធីពិសេសនេះ ត្រូវដំណើរការតាមយន្តការរបស់រាជរដ្ឋាភិបាល ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីជាធរមាន។ ជាមួយគ្នានេះ, ការលើកទឹកចិត្តផ្អែកពន្ធ (ពន្ធដារ និងពន្ធគយ) ក្រោមកម្មវិធីពិសេសនេះមិនត្រូវអនុវត្ត ចំពោះសកម្មភាពវិនិយោគ និងធុរកិច្ចក្នុងវិស័យ ដូចខាងក្រោម៖

- ល្បែងពាណិជ្ជកម្ម;
- សេវាកម្ម និងអាជីវកម្មរូបិយវត្ថុ និងហិរញ្ញវត្ថុ រួមមានធនាគារ ស្ថាប័នហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និងប្រតិបត្តិការហិរញ្ញវត្ថុអន្តរការិយកម្មគ្រប់ប្រភេទ;
- កម្មន្តសាលភេសជ្ជៈ (វៀរលែងតែកម្មន្តសាលភេសជ្ជៈ ធ្វើពីផលិតផលកសិកម្ម);
- ការសិក្សាស្រាវជ្រាវប្រេងកាត និងរ៉ែគ្រប់ប្រភេទ;
- ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ;
- សកម្មភាពលក់ដុំ និងលក់រាយទំនិញ ថ្នាំជក់ ភេសជ្ជៈ គ្រឿងស្រវឹង យានយន្តគ្រប់ប្រភេទ ប្រេងឥន្ធនៈ និងឧស្ម័ន រួមទាំងសកម្មភាពជួសជុលយានយន្ត និងទោចក្រយានយន្តគ្រប់ប្រភេទ;
- សកម្មភាពវិនិយោគលើសេវាកម្មខារ៉ាអូខេ រង្គសាល បានីយដ្ឋាន កន្លែងម៉ាស្សា អាហារដ្ឋាន កន្លែងហាត់ប្រាណ តូបជួល ផ្សារលក់ដុំលក់រាយ សេវាបញ្ញើ;
- សកម្មភាពផ្គត់ផ្គង់អគ្គិសនីរបស់សេវាករអគ្គិសនី និង;

- សកម្មភាពសេវាកម្មស្ថាបត្យកម្ម សេវាកម្មវិស្វកម្ម និងលទ្ធកម្មសាធារណៈ។

២ ការផ្ដល់ហិរញ្ញប្បទានក្រោមអត្រាការប្រាក់សមរម្យ

ការដាក់ចេញនូវកម្មវិធីហិរញ្ញប្បទានក្រោមអត្រាការប្រាក់សមរម្យ ដោយផ្ដោតជាពិសេសលើសហគ្រាសធុនតូច និងមធ្យម, សហគមន៍កសិកម្មទំនើប និងសហគមន៍ទេសចរណ៍ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា (SME Bank) ដើម្បីផ្ដល់ឥណទាន ក្នុងវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ស្របតាមអាទិភាព ដែលបានកំណត់ខាងលើក្នុងគោលដៅ ១. គាំទ្រដល់ដំណើរការវិនិយោគ ឬពង្រីកអាជីវកម្ម, ២. ប្រមូលទិញ ឬស្ដុកទុកកសិផល និង ៣. ជំរុញអាជីវកម្មកែច្នៃ និង/ឬ វេចខ្ចប់។

៣ ការជួយកាត់បន្ថយថ្លៃដើមផលិតកម្ម, ការសម្រួលនីតិវិធី និងការគាំទ្រសកម្មភាពវិនិយោគឯកជន

ការដាក់ចេញនូវវិធានការដែលមានចរិតអន្តរស្ថាប័ន និងប្រទាក់ក្រឡា ទាំងការលើកទឹកចិត្តជាបន្ទុករដ្ឋ និងការសម្រួលនីតិវិធីរដ្ឋបាលនានា សំដៅចូលរួមកាត់បន្ថយថ្លៃដើមផលិតកម្ម និងលើកកម្ពស់ផលិតភាពផលិតកម្ម ដូចខាងក្រោម៖

- សម្រួលបែបបទ និងនីតិវិធីវិនិយោគ និងធុរកិច្ច រួមទាំង ការស្នើសុំអាជ្ញាបណ្ណ, វិញ្ញាបនបត្រ និងលិខិតអនុញ្ញាតនានា ព្រមទាំងការចុះបញ្ជីជា គ.ល.គ.;
- សម្រួលនីតិវិធី បែបបទ និងការអនុញ្ញាតផ្សេងៗ សម្រាប់បម្រើដល់ការអនុវត្តគម្រោង ឬសកម្មភាពពង្រីកការវិនិយោគ និង/ឬ ធុរកិច្ច;
- ពង្រឹងយន្តការ ឬនីតិវិធីដោះស្រាយបញ្ហាប្រឈមជាក់ស្ដែង ដែលជាបន្ទុកបន្ថែមរបស់វិនិយោគិនក្នុងការចុះបញ្ជី និងដំណើរការអាជីវកម្ម;
- ផ្ដល់ជូនការអនុគ្រោះថ្លៃប្រើប្រាស់អគ្គិសនីដូចមានក្នុងវិស័យកសិកម្ម សម្រាប់វិស័យកសិ-ឧស្សាហកម្ម រួមមានការកែច្នៃ និង/ឬ ការវេចខ្ចប់ នៃផលិតផលគន្លឹះ ជាអាទិ៍ កៅស៊ូ ស្វាយចន្ទី ដំឡូងមី ចេកអំបូងលឿង ផ្លែឈើ និងឈើដាំ;
- លើកទឹកចិត្តការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគន្លឹះៗ ដើម្បីគាំទ្រដល់ការវិនិយោគឯកជនក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលមានដូចជា គម្រោងកំពង់ផែ, គម្រោងសួនកសិ-ឧស្សាហកម្ម, គម្រោងបូមស្ដារផ្លូវនាវាចរណ៍ និងគម្រោងអាកាសយានដ្ឋាន;
- ដាក់ចេញនូវយន្តការសម្របសម្រួលក្នុងការផ្ទេរគម្រោងសម្បទានដីសេដ្ឋកិច្ចអសកម្ម ឱ្យទៅអ្នកវិនិយោគិនដែលមានបំណងច្បាស់លាស់ និងជាក់លាក់ក្នុងការ វិនិយោគនិងពង្រីកសកម្មភាពធុរកិច្ច លើវិស័យអាទិភាពដែលបានកំណត់ក្នុងលក្ខខណ្ឌអនុគ្រោះខ្ពស់;
- អនុញ្ញាតឱ្យមានការបញ្ជាក់វិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ (Phytosanitary Certificate) ដោយអង្គភាពមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទៅខេត្តជាប់ព្រំដែនដែលមានច្រកអន្តរជាតិ;

- ពង្រឹងយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា (Contract Farming) លើទំនិញកសិ-ឧស្សាហកម្មយុទ្ធសាស្ត្ររវាងអ្នកផលិត (ផ្តល់អាទិភាពដល់សហគមន៍កសិកម្មទំនើប) និងក្រុមហ៊ុនកែច្នៃក្នុងស្រុក;
- ពន្លឿនការចុះបញ្ជីដីធ្លី ឬប័ណ្ណកម្មសិទ្ធដីធ្លីនៅតាមតំបន់ដាយក្រុង ឬទីប្រជុំជននៃបណ្ដាខេត្តនីមួយៗ និង;
- រៀបចំឱ្យមានវគ្គបណ្តុះបណ្តាលកិច្ចទីផ្សារឌីជីថល (Digital Marketing) និងដាក់ឱ្យអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស (Enterprises Go Digital-EGD) ដើម្បីជំរុញការចូលរួមរបស់សហគ្រាសធុនតូច និងមធ្យម និងបង្កើនលទ្ធភាពក្នុងការតភ្ជាប់ជាមួយទីផ្សារ។

៦. យន្តការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីធានានូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងការអនុវត្ត «**កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគពាយ័ព្យ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨**», យន្តការអនុវត្ត តាមដាន និងវាយតម្លៃ នៃកម្មវិធីពិសេសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

ទី១. ក្រុមការងារជំរុញការវិនិយោគក្នុងភូមិភាគពាយ័ព្យ (ក.វ.ពាយ័ព្យ)» ត្រូវបានបង្កើតក្រោមឆ័ត្រគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) និងមានសិទ្ធិប្រើ-ប្រាស់ត្រាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បំពេញភារកិច្ច ទាំងតាមទម្រង់ច្បាប់ដើម និងតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រុមការងារនេះ មានភារកិច្ចដឹកនាំ សម្របសម្រួល និងអនុវត្តកម្មវិធីពិសេសនេះ ដោយដើរតួនាទីជា "ច្រកចេញចូលតែមួយ" ដែលមានតួនាទីពិនិត្យ វាយតម្លៃ និងផ្តល់ការ-អនុម័តគម្រោង, ផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនានា ជាកញ្ចប់ទៅលើគម្រោងវិនិយោគ នៃកម្មវិធីពិសេសនេះ, ស្នើសុំដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា តាមរយៈ គ.ស.ហ. និងអនុវត្តនូវកិច្ចការដទៃទៀត តាមការសម្រេចរបស់ គ.ស.ហ. ឬតាមការសម្រេចរបស់រាជរដ្ឋាភិបាល។ រាល់គម្រោងវិនិយោគ ដែលស្ថិតក្រោមវិសាលភាពនៃកម្មវិធីពិសេសនេះ ត្រូវដាក់ស្នើមកក្រុមការងារនេះ ដើម្បីក្រុមការងារពិនិត្យ វាយតម្លៃ និងផ្តល់ការអនុម័ត។

ទី២. ក.វ.ពាយ័ព្យ ត្រូវមានសមាសភាពមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធ ដែលមានដូចជាក្រសួងមហាផ្ទៃ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងពាណិជ្ជកម្ម, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងរ៉ែ និងថាមពល, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងបរិស្ថាន, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងទេសចរណ៍, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, អគ្គិសនីកម្ពុជា, ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា, ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម, និងរដ្ឋបាលខេត្តទាំងបួន (ខេត្ត

ក្រចេះ, ខេត្តស្ទឹងត្រែង, ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី) ព្រមទាំងក្រសួង-ស្ថាប័នផ្សេងទៀត ដែលទទួលបានប្រតិភូកម្ម ឬមានសិទ្ធិសម្រេច ក្នុងនាមប្រធានក្រសួង-ស្ថាប័ន។

ទី៣. ក.វ.ឦសាន មានលេខាធិការដ្ឋានមួយជាសេនាធិការ និងមានធនធានហិរញ្ញវត្ថុ ក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លេខាធិការដ្ឋានដើរតួនាទីសម្របសម្រួលផ្នែករដ្ឋបាលទាំងអស់ និងមានការិយាល័យនៅរាជធានីភ្នំពេញ និងអាចបង្កើតការិយាល័យតាមបណ្ដាខេត្តនៅភូមិភាគឦសាន តាមការចាំបាច់។

ទី៤. ក.វ.ឦសាន ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវកម្មវិធីពិសេសនេះ ឱ្យបានទូលំទូលាយ, ធ្វើការពន្យល់ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ, និងផ្ដល់សេវាបដិសណ្ឋារកិច្ច និងកិច្ចសហការល្អជាមួយវិនិយោគិន និងធុរជន ទាំងក្នុង និងក្រៅប្រទេស ដើម្បីលើកកម្ពស់ការយល់ដឹង និងទាក់ទាញការចូលរួមអនុវត្តពីកម្លាំងចលករសំខាន់ៗ។

ទី៥. ក.វ.ឦសាន ត្រូវដាក់ចេញកម្មវិធីពង្រឹងសមត្ថភាពដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ ព្រមទាំង អ្នកពាក់ព័ន្ធ ដោយផ្ដោតលើការបំពេញភារកិច្ច, ការសម្របសម្រួល, ការផ្ដល់សេវាដល់វិនិយោគិន និងធុរជន, ការរៀបចំគម្រោង, និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីផ្ដល់សេវា និងអនុវត្តការងារប្រកបដោយគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាព។

ទី៦. ក.វ.ឦសាន ត្រូវធ្វើការតាមដាន និងវាយតម្លៃ ការអនុវត្តកម្មវិធីពិសេស តាមរយៈការរៀបចំកិច្ចប្រជុំក្រុមការងារទៀងរាល់ត្រីមាស ឬកិច្ចប្រជុំណាមួយតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រឈម, ដាក់ចេញវិធានការកែតម្រូវ, វាស់វែងពីការខិតខំប្រឹងប្រែង, និងវាយតម្លៃប្រសិទ្ធភាព និងលទ្ធផលនៃកម្មវិធីពិសេសនេះ។ ក្នុងគោលបំណងឆ្លើយតបនឹងកម្មវត្ថុនេះ, ក្របខណ្ឌអនុវត្តការងារនេះត្រូវរៀបចំតាមអភិក្រម "ជវភាពនៃប្រព័ន្ធតួអង្គតែមួយ" ដែលមានសហថាមពលព្រមគ្នា និងសង្គតិភាពជាមួយគ្នា, មានកិច្ចសម្របសម្រួលខ្ពស់ និងការទទួលខុសត្រូវ, មានកិច្ចសហការល្អ និងការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ, និងមានការរៀបចំត្រួតពិនិត្យលទ្ធផលជាប្រចាំ។

ទី៧. ក.វ.ឦសាន ត្រូវរៀបចំរបាយការណ៍វឌ្ឍនភាព និងការវាយតម្លៃការអនុវត្តកម្មវិធីពិសេសនេះ ប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល តាមរយៈ គ.ស.ហ.។

៧. សេចក្ដីសន្និដ្ឋាន

ការដាក់ចេញនូវ **«កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨»** គឺជាការបោះជំហានគោលនយោបាយដែលមានលក្ខណៈយុទ្ធសាស្ត្រ។ ពិតណាស់ថា កម្មវិធីពិសេសនេះចង់ជំរុញការអភិវឌ្ឍ នៃខេត្តទាំងបួន ដែលនៅឆ្ងាយពីមជ្ឈមណ្ឌលកំណើនសេដ្ឋកិច្ច ប៉ុន្តែទន្ទឹមនេះ, កម្មវិធីពិសេសនេះក៏ជាកាតាលីករជួយពង្រឹងឯករាជ្យភាពនៃកម្លាំងសេដ្ឋកិច្ច និងសមត្ថភាពជាប៉ូលសេដ្ឋកិច្ចរបស់ភូមិភាគឦសាន[illegible] បង្កើនភាពទាក់ទាញដល់វិនិយោគិន ក៏ដូចជាប្រជាពលរដ្ឋទូទៅ ឱ្យចូលមករស់នៅ និងធ្វើសកម្មភាពសេដ្ឋកិច្ចកាន់តែស្វាហាប់ឡើង និងអាចជាការអភិវឌ្ឍតំបន់ព្រំដែន ប្រកបដោយប្រសិទ្ធភាព[illegible]

ភាពផងដែរ។ កម្មវិធីពិសេសនេះទាមទារឱ្យមានការចូលរួមចំណែកពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ប្រកបដោយស្មារតីម្ចាស់ការ ទទួលខុសត្រូវ ជាមួយនឹងឆន្ទៈមោះមុត នៅក្នុងការរួមគ្នាបង្កើតស្ពានដៃ អភិវឌ្ឍន៍ថ្មី ក្តីសង្ឃឹមថ្មី និងកម្លាំងចលករថ្មីបន្ថែមទៀត សម្រាប់លើកស្ទួយកំណើនសេដ្ឋកិច្ចជាតិ និងវិបុលភាពប្រកបដោយបរិយាប័ន្ន នៅទូទាំងប្រទេស។

«កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០២៥-២០២៨» មានភាពទន់ភ្លន់ និងបត់បែនខ្ពស់ ដោយត្រូវបានចាត់ទុកថាជា "ឯកសាររស់" ដែលអាចនឹងកែសម្រួលបន្ថែមជាយថាហេតុ ក្នុងករណីចាំបាច់ ដើម្បីធានាសង្គតិភាព និងការឆ្លើយតបទៅនឹងកាលៈទេសៈចំពោះមុខជាក់ស្តែង ទាំងក្នុងប្រទេស, តំបន់ និង សកលលោក។ លើសពីនេះ, ការអនុវត្តកម្មវិធីពិសេសនេះ គឺជាការបង្ហាញពីឆន្ទៈនយោបាយយ៉ាងមោះមុតរបស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចខិតខំប្រឹងប្រែងការពារសន្តិភាព ស្ថិរភាព ឯករាជ្យភាព និងបូរណភាពទឹកដី ក៏ដូចជាការខិតខំពង្រីក និងចែកចាយផលលាភពីកំណើនសេដ្ឋកិច្ច ទៅដល់គ្រប់មជ្ឈដ្ឋាននៃប្រជាជនខ្មែរ ក្នុងដំណើរឆ្ពោះទៅសម្រេចមហិច្ឆតានៃការក្លាយខ្លួនជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

៨. ឧបសម្ព័ន្ធអំពីវិធានការគាំទ្រ និងជំរុញការវិនិយោគ

I.	វិសាលភាព
១.	ការលើកទឹកចិត្តនេះ នឹងត្រូវបានអនុវត្តចំពោះ គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច ដែលបានចុះបញ្ជីជាគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ.), គម្រោងពង្រីកនៃ គ.ល.គ. ដែលមានស្រាប់, គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍កសិកម្មទំនើប និង គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ ដែលត្រូវចាប់ផ្តើមដំណើរការ នៅក្នុងឆ្នាំ ២០២៥ ដល់ ២០២៨ នៅក្នុងខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ឬខេត្តមណ្ឌលគិរី។ ជាមួយគ្នានេះ, ក្នុងគោលដៅជំរុញសកម្មភាពវិនិយោគ ជាពិសេសកៀរគរមូលធនវិនិយោគក្នុងស្រុក ដើម្បីទាញយកឧត្តមប្រយោជន៍ឱ្យបានជាអតិបរមា, រាជរដ្ឋាភិបាលនឹងរៀបចំលិខិតបទដ្ឋានគតិយុត្តកំណត់លក្ខខណ្ឌបន្ធូរបន្ថយពិសេសដាច់ដោយឡែក សំដៅបើកផ្លូវឱ្យសកម្មភាពធុរកិច្ចទូទៅ (ដែលមិនមែនជា គ.ល.គ.) អាចស្នើសុំជា គ.ល.គ. ដើម្បីធ្វើការវិនិយោគនៅភូមិភាគឦសាន ក្នុងឆ្នាំ ២០២៥-២០២៨ ជាមួយនឹងការទទួលបាននូវការលើកទឹកចិត្តដូច គ.ល.គ.។ វិធាននៃការផ្តល់ការលើកទឹកចិត្តចំពោះ គ.ល.គ. ពាក់ព័ន្ធទៅនឹងផលិតកម្ម និងការកែច្នៃកសិផល ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ត្រូវតែមានសង្គតិភាព និងសម្របជាមួយនឹងក្របខណ្ឌនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង និងអភិវឌ្ឍលើមុខទំនិញយុទ្ធសាស្ត្រសំខាន់ៗ។
២.	ចំពោះគម្រោងវិនិយោគធំៗ, គម្រោងវិនិយោគ និងសកម្មភាពធុរកិច្ច ដែលមានវេទយិតភាព រួមបញ្ចូលគម្រោងដែលមានទីតាំងនៅក្បែរព្រំដែន ត្រូវអនុវត្តដោយនីតិវិធីដោយឡែក។ ចំពោះគម្រោងវិនិយោគ និងសកម្មភាពធុរកិច្ចផ្សេងទៀត ដែលស្ថិតនៅក្រៅវិសាលភាពនៃកម្មវិធីពិសេសនេះ ត្រូវដំណើរការតាមយន្តការរបស់រាជរដ្ឋាភិបាល ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីជាធរមាន។ ជាមួយគ្នានេះ, ការលើកទឹកចិត្តផ្នែកពន្ធ (ពន្ធដារ និងពន្ធគយ) ក្រោមកម្មវិធីពិសេសនេះមិនត្រូវអនុវត្ត ចំពោះសកម្មភាពវិនិយោគ និងធុរកិច្ចក្នុងវិស័យ ដូចខាងក្រោម៖ - ល្បែងពាណិជ្ជកម្ម; - សេវាកម្ម និងអាជីវកម្មរូបិយវត្ថុ និងហិរញ្ញវត្ថុ រួមមានធនាគារ ស្ថាប័នហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង និងប្រតិបត្តិការហិរញ្ញវត្ថុអន្តរការិយកម្មគ្រប់ប្រភេទ; - កម្មន្តសាលកេសជ្ជៈ (វៀរលែងតែកម្មន្តសាលកេសជ្ជៈ ធ្វើពីផលិតផលកសិកម្ម); - ការសិក្សាស្រាវជ្រាវប្រេងកាត និងរ៉ែគ្រប់ប្រភេទ; - ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ និង;

	➢ សកម្មភាពលក់ដុំ និងលក់រាយទំនិញ ថ្នាំជក់ ភេសជ្ជៈ គ្រឿងស្រវឹង យានយន្តគ្រប់ប្រភេទ ប្រេងឥន្ធនៈ និងឧស្ម័ន រួមទាំងសកម្មភាពជួសជុលយានយន្ត និងទោចក្រយានយន្តគ្រប់ប្រភេទ ➢ សកម្មភាពវិនិយោគលើសេវាកម្មខារ៉ាអូខេ រង្គសាល បានីយដ្ឋាន កន្លែងម៉ាស្សា អាហារដ្ឋាន កន្លែងហាត់ប្រាណ តូបជួល ផ្សារលក់ដុំលក់រាយ សេវាបញ្ញើ ➢ សកម្មភាពផ្គត់ផ្គង់អគ្គិសនីរបស់សេវាករអគ្គិសនី ➢ សកម្មភាពសេវាកម្មស្ថាបត្យកម្ម សេវាកម្មវិស្វកម្ម និងលទ្ធកម្មសាធារណៈ។	
III.	**វិធានការផ្ដែកពន្ធដារ និងពន្ធគយ**	**ស្ថាប័នទទួលបន្ទុក**
១.	**<u>គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចជា គ.ល.គ. ក្នុងវិស័យទូទៅក្រៅពីវិស័យអាទិភាព នឹងទទួលបានការលើកទឹកចិត្តវិនិយោគ ដូចខាងក្រោម៖</u>** ➢ លើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ៣ ឆ្នាំបន្ថែម ដោយរយៈពេលលើកលែងពន្ធត្រូវគិតចាប់ពីឆ្នាំដែលគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចមានចំណូលពីសកម្មភាពអាជីវកម្មដំបូង; ➢ អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិតកម្ម ដែលផលិតក្នុងស្រុក; ➢ លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង; ➢ លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្សប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួននៅភូមិភាគឦសាន។	- អគ្គនាយកដ្ឋានពន្ធដារ - អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
២.	**<u>គម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច ក្នុងវិស័យអាទិភាព៖</u>** គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ច របស់សហគមន៍កសិកម្មទំនើប ក្នុងវិស័យកសិកម្ម, និង គ.ល.គ. ក្នុងវិស័យកសិ-ឧស្សាហកម្ម ស្របតាមអាទិភាពដែលបានកំណត់ ព្រមទាំង គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ ក្នុងវិស័យទេសចរណ៍ រួមមាន ការ-	- អគ្គនាយកដ្ឋានពន្ធដារ - អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

	បង្កើតតំបន់ទេសចរណ៍អត្តសញ្ញាណពិសេស, ការបង្កើតតំបន់អេកូទេសចរណ៍, ការបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋ, ការបង្កើតសួនភូតគាម (សួនបូតានិក) ឬសួនទេសចរណ៍ ឬសួនសត្វ ឬសកម្មភាពអភិរក្សជីវៈចម្រុះ, និងការបង្កើតរមណីយដ្ឋានដែលមានសេវាកម្មចម្រុះ (រួមមានជាអាទិ៍ សេវាកម្មដូចជា សណ្ឋាគារ សួនកម្សាន្ត កន្លែងហាត់កីឡា និងសួនសត្វ) នឹងទទួលបានការលើកទឹកចិត្តវិនិយោគ ដូចខាងក្រោម៖ ➢ លើកលែងពន្ធលើប្រាក់ចំណូល, ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ១២ ឆ្នាំ ដោយរយៈពេលលើកលែងពន្ធត្រូវគិតចាប់ពីឆ្នាំដែលគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចមានចំណូលពីសកម្មភាពអាជីវកម្មដំបូង; ➢ ចំពោះ គ.ល.គ. ឬ គម្រោងវិនិយោគឬសកម្មភាពធុរកិច្ចរបស់សហគមន៍កសិកម្មទំនើប ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម, ផ្តល់ការលើកទឹកចិត្តពន្ធគយ, អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋលើការនាំចូលសម្ភារៈសាងសង់ បរិក្ខារសំណង់ សម្ភារៈបរិក្ខារផលិតកម្ម និងធាតុចូលផលិតកម្ម; ➢ ចំពោះ គ.ល.គ. ឬគម្រោងវិនិយោគ ឬសកម្មភាពធុរកិច្ចរបស់សហគមន៍ទេសចរណ៍ ក្នុងវិស័យទេសចរណ៍, ផ្តល់ការលើកទឹកចិត្តពន្ធគយ អាករពិសេស និងអាករលើតម្លៃបន្ថែម ជាបន្ទុករបស់រដ្ឋលើការនាំចូលសម្ភារៈសាងសង់ បរិក្ខារសំណង់ និងសម្ភារៈបរិក្ខារផលិតកម្ម; ➢ អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិតកម្ម ដែលផលិតក្នុងស្រុក; ➢ លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង; ➢ លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្សប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួននៅភូមិភាគឦសាន។	
៣.	<u>**គម្រោងពង្រីកនៃ គ.ល.គ. ក្នុងឆ្នាំ ២០២៥-២០២៨ នឹងទទួលបានការលើកទឹកចិត្តវិនិយោគ ដូចខាងក្រោម៖**</u>	- អគ្គនាយកដ្ឋានពន្ធដារ - អគ្គនាយកដ្ឋានគយ និងរដ្ឋាករ

	➢ លើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និងពន្ធអប្បបរមា រយៈពេល ៣ ឆ្នាំ បន្ថែម ពីលើរយៈពេលជាក់លាក់ណាមួយ ទៅតាមប្រភេទក្រុមសកម្មភាពវិនិយោគដើម ផ្អែកតាមសមាមាត្រនៃអត្រាទុនពង្រីក ស្របតាមអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា; ➢ អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយចំពោះការទិញធាតុចូលផលិតកម្ម ដែលផលិតក្នុងស្រុក; ➢ លើកលែងពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និងពន្ធប៉ាតង់ រយៈពេល ៣ ឆ្នាំ និង; ➢ លើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិត ដែលទទួលបានប្រាក់បៀវត្សប្រចាំខែ ក្រោម ២ ០០០ ០០១ រៀល និងបម្រើការងារសម្រាប់ គ.ល.គ. ក្នុងខេត្តទាំងបួននៅភូមិភាគឦសាន។ *__សម្គាល់__៖ និយមន័យ និងវិធីគណនាទុនពង្រីក ត្រូវអនុវត្តដូចគ្នាទៅនឹងវិធានដូចមានចែងក្នុងប្រកាសលេខ ៣១៣ សហវប្រក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលចំពោះគម្រោងពង្រីកនៃ គ.ល.គ.។*	
៤.	__សកម្មភាពធុរកិច្ច ដែលមិនទាន់បានចុះបញ្ជីពន្ធដារ៖__ សម្រាប់សកម្មភាពធុរកិច្ច ដែលកំពុងដំណើរការ តែមិនទាន់បានចុះបញ្ជីពន្ធដារ ត្រូវទៅចុះបញ្ជីពន្ធដារតាមនីតិវិធីជាធរមានដោយស្ម័គ្រចិត្ត ក្នុងឆ្នាំ ២០២៥ នឹងទទួលបានការលើកលែង ពិន័យទោសទណ្ឌ, បំណុលពន្ធ (រួមមាន ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់) និងការផាកពិន័យជាប្រាក់ ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកមុនការចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ដែលអនុលោមតាមយុទ្ធសាស្ត្រជាតិ ស្តីពី ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ ២០២៣-២០២៨។ ទន្ទឹមនេះ, ដើម្បីទទួលបានការលើកទឹកចិត្តបន្ថែម ដូចមានក្នុងវិធានការផ្អែកពន្ធដារ និងពន្ធគយ, សកម្មភាពធុរកិច្ច ដែលបានចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត ត្រូវចុះបញ្ជីជា គ.ល.គ. ក្នុងឆ្នាំ ២០២៥	- អគ្គនាយកដ្ឋានពន្ធដារ - អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

	ស្របតាមលិខិតបទដ្ឋានគតិយុត្តកំណត់លក្ខខណ្ឌបន្ធូរបន្ថយនៃការចុះបញ្ជីជា គ.ល.គ. ក្នុងខេត្តទាំងបួន នៅភូមិភាគឦសាន នៃកម្មវិធីពិសេស នេះ។	
III.	**ការផ្ដល់ហិរញ្ញប្បទានក្រោមអត្រាការប្រាក់សមរម្យ**	**ស្ថាប័នទទួលបន្ទុក**
	ការដាក់ចេញនូវកម្មវិធីហិរញ្ញប្បទានក្រោមអត្រាការប្រាក់សមរម្យ ដោយផ្ដោតជាពិសេសលើសហគ្រាសធុនតូច និងមធ្យម សហគមន៍កសិកម្មទំនើប និងសហគមន៍ទេសចរណ៍ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា (SME Bank) ដើម្បីផ្ដល់ឥណទាន ក្នុងវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍អាទិភាព ដែលបានកំណត់ខាងលើ ក្នុងគោលដៅ ១. គាំទ្រដល់ដំណើរការវិនិយោគ ឬពង្រីកអាជីវកម្ម, ២. ប្រមូលទិញ ឬស្តុកទុកកសិផល និង ៣. ជំរុញអាជីវកម្មកែច្នៃ និង/ឬ វេចខ្ចប់។	- ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម - ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា
IV.	**ការជួយកាត់បន្ថយថ្លៃដើមផលិតកម្ម, ការសម្រួលនីតិវិធី និងការគាំទ្រសកម្មភាពវិនិយោគឯកជន**	**ស្ថាប័នទទួលបន្ទុក**
១.	➢ សម្រួលបែបបទ និងនីតិវិធីវិនិយោគ និងធុរកិច្ច រួមទាំង ការស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ និងលិខិតអនុញ្ញាតនានា ព្រមទាំងការចុះបញ្ជីជា គ.ល.គ.; ➢ សម្រួលនីតិវិធី បែបបទ និងការអនុញ្ញាតផ្សេងៗ សម្រាប់បម្រើដល់ការអនុវត្តគម្រោង ឬសកម្មភាពពង្រីកការវិនិយោគ និង/ឬ ធុរកិច្ច និង; ➢ ពង្រឹងយន្តការ ឬនីតិវិធីដោះស្រាយបញ្ហាប្រឈមជាក់ស្ដែង ដែលជាបន្ទុកបន្ថែមរបស់វិនិយោគិនក្នុងការចុះបញ្ជី និងដំណើរការអាជីវកម្ម។	- ក្រុមការងារអន្តរក្រសួងចំពោះកិច្ច
២.	ផ្ដល់ជូនការអនុគ្រោះថ្លៃប្រើប្រាស់អគ្គិសនីដូចមានក្នុងវិស័យកសិកម្ម សម្រាប់វិស័យកសិ-ឧស្សាហកម្ម រួមមានការកែច្នៃ និង/ឬ ការវេចខ្ចប់ នៃផលិតផលគន្លឹះ ជាអាទិ៍ កៅស៊ូ ស្វាយចន្ទី ដំឡូងមីចេកអំបូងលឿង ផ្លែឈើ និងឈើដាំ។	- អគ្គិសនីកម្ពុជា

៣.	លើកទឹកចិត្តការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគន្លឹះៗ ដើម្បីគាំទ្រដល់វិនិយោគឯកជន ក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនដែលមានដូចជា គម្រោងកំពង់ផែ, គម្រោងសួនកសិ-ឧស្សាហកម្ម, គម្រោងបូមស្ដារផ្លូវនាវាចរណ៍ និងគម្រោងអាកាសយានដ្ឋាន;	- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - ក្រសួង-ស្ថាប័នពាក់ព័ន្ធ
៤.	ដាក់ចេញនូវយន្តការសម្របសម្រួលក្នុងការផ្ទេរគម្រោងសម្បទានដីសេដ្ឋកិច្ចអសកម្ម ឱ្យទៅអ្នកវិនិយោគិនដែលមានបំណងច្បាស់លាស់ និងដាក់លាក់ក្នុងការ វិនិយោគនិងពង្រីកសកម្មភាពធុរកិច្ច លើវិស័យអាទិភាពដែលបានកំណត់ក្នុងលក្ខខណ្ឌអនុគ្រោះខ្ពស់។	- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - ក្រសួងបរិស្ថាន - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - រដ្ឋបាលខេត្ត
៥.	អនុញ្ញាតឱ្យមានការបញ្ជាក់វិញ្ញាបនបត្រអនាម័យ និងភូតគាមអនាម័យ (Phytosanitary Certificate) ដោយអង្គភាពមានសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខេត្តជាប់ព្រំដែនដែលមានច្រកអន្តរជាតិ។	- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
៦.	ពង្រឹងយន្តការផលិតកម្មកសិកម្មតាមកិច្ចសន្យា (Contract Farming) លើទំនិញកសិ-ឧស្សាហកម្មយុទ្ធសាស្ត្ររវាងអ្នកផលិត (ផ្ដល់អាទិភាពដល់សហគមន៍កសិកម្មទំនើប) និងក្រុមហ៊ុនកែច្នៃក្នុងស្រុក។	- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - ក្រសួងពាណិជ្ជកម្ម
៧.	ការពន្លឿនការចុះបញ្ជីដីធ្លី ឬប័ណ្ណកម្មសិទ្ធិដីធ្លីនៅតាមតំបន់ជាយក្រុង ឬទីប្រជុំជននៃបណ្ដាខេត្តនីមួយៗ។	- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
៨.	រៀបចំឱ្យមានវគ្គបណ្ដុះបណ្ដាលកិច្ចទីផ្សារឌីជីថល (Digital Marketing) និងដាក់ឱ្យអនុវត្តកម្មវិធីបរិវត្តកម្មឌីជីថលសហគ្រាស (Enterprises Go Digital-EGD) ដើម្បីជំរុញការចូលរួមរបស់សហគ្រាសធុនតូច និងមធ្យម និងបង្កើនលទ្ធភាពក្នុងការតភ្ជាប់ជាមួយទីផ្សារ។	- ក្រសួងប្រៃសណីយ៍ និទូរគមនាគមន៍ - ក្រសួងទេសចរណ៍ - មជ្ឈមណ្ឌលបណ្ដុះធុរកិច្ច "តេជោ"

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៩ សសរ

សេចក្តីសម្រេច

ស្តីពី

ការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៤/១០២៦ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

សម្រេច

ប្រការ១ .-

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដូចខាងក្រោម៖

១- សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយស

២- ឯកឧត្តម **ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ប្រធាន

៣- ឯកឧត្តម **ប៊ិន ត្រឈៃ** រដ្ឋមន្ត្រីក្រសួងផែនការ អនុប្រធាន

៤- ឯកឧត្តមសាស្ត្រាចារ្យ **ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល អនុប្រធាន

៥- ឯកឧត្តម **កែវ រតនៈ** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល អនុប្រធាន

៦- ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុប្រធាន

៧- ឯកឧត្តម **ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អនុប្រធាន

៨- ឯកឧត្តមបណ្ឌិត **អ៊ុំ រម្យណី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន

៩- ឯកឧត្តមបណ្ឌិត **សាត សាមី** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អនុប្រធានអចិន្ត្រៃយ៍

១០- ឯកឧត្តម **ខូយ ឃុនហ៊ួរ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១១- ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

១២- ឯកឧត្តម **អ៊ុន ឃាង** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៣- ឯកឧត្តមបណ្ឌិត **ស្តើង សុខុម** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៤- ឯកឧត្តម **ស៊ុន ដារ៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

១៥- ឯកឧត្តម **ឆាយ សុផល** រដ្ឋលេខាធិការក្រសួងព័ត៌មាន សមាជិក

១៦- លោកជំទាវ **ឥម នីថារ៉ា** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិកា

១៧- ឯកឧត្តម **កែង សុម៉ារិទ្ធ** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

១៨- ឯកឧត្តម **ហួត ស៊ីនាដ** រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៩- ឯកឧត្តម **ឌិន ពន្លក** រដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក

២០- ឯកឧត្តម **លាង មុនីរិទ្ធ** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

២១- ឯកឧត្តម **ម៉ុញ សច្ចៈ** រដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម សមាជិក

២២- ឯកឧត្តម **ឡុង ប៉ុណ្ណាស៊ីរីវត្ថ** រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

២៣- ឯកឧត្តមបណ្ឌិត **សៅ ជីវ័ន្ត** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

២៤- ឯកឧត្តម **នាង ម៉ៅ** រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

២៥- ឯកឧត្តម **ពៅ ប៉ូលីណោល** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

២៦- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** អនុប្រធានប្រចាំការ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សមាជិក

២៧- ឯកឧត្តម **ជូ ហេង** អគ្គលេខាធិការរងនៃគណៈកម្មាធិការសហប្រតិបត្តិការ អភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

២៨- ឯកឧត្តមសាស្ត្រាចារ្យ **សាផុន វឌ្ឍនៈ** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល សមាជិក

២៩- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ង៉ោ ប៊ុនថាន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ ភូមិន្ទកសិកម្ម សមាជិក

៣០- ឯកឧត្តមបណ្ឌិត **សេខ សុភាព**	ប្រធានបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា	សមាជិក
៣១- ឯកឧត្តមបណ្ឌិត **កែ សុជាតិ**	អគ្គនាយកវិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	សមាជិក
៣២- ឯកឧត្តមបណ្ឌិត **ទ្រី សុផល**	អគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍	សមាជិកអចិន្ត្រៃយ៍
៣៣- អ្នកឧកញ៉ា **គិត ម៉េង**	ប្រធានសភាពាណិជ្ជកម្មកម្ពុជា	សមាជិក
៣៤- លោកសាស្ត្រាចារ្យបណ្ឌិត **ជ័យ ចាន់អឿន**	ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ	សមាជិក
៣៥- លោកសាស្ត្រាចារ្យរងបណ្ឌិត **អោ ច័ន្ទម៉ូលី**	ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា	សមាជិក
៣៦- លោកបណ្ឌិត **ឃិន ម៉ូលីន**	ប្រធានមហាវិទ្យាល័យថ្នាក់ក្រោយបរិញ្ញាបត្រ នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា	សមាជិក
៣៧- ប្រធានវិទ្យាស្ថានចក្ខុវិស័យអាស៊ី		សមាជិក
៣៨- សាកលវិទ្យាធិការនៃសាកលវិទ្យាល័យបច្ចេកវិទ្យានិងវិទ្យាសាស្ត្រកម្ពុជា		សមាជិក
៣៩- នាយកវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ		សមាជិក
៤០- នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា		សមាជិក
៤១- នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលកម្ពុជា៤.០		សមាជិក។

ប្រការ២ .-

សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១០៦ សសរ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវទុកជានិរាករណ៍។

ប្រការ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ២ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣០ សសរ

សេចក្តីសម្រេច

ស្តីពី

ការដាក់ឱ្យអនុវត្តវិធានការគន្លឹះអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២៥

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- បានឃើញអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ១ .-

ត្រូវបានដាក់ឱ្យអនុវត្ត **វិធានការគន្លឹះអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២៥** ដែលជាឧបសម្ព័ន្ធនៃសេចក្ដីសម្រេចនេះ។

ប្រការ២ .-

គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ត្រូវត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តវិធានការគន្លឹះដូចបានកំណត់ក្នុងប្រការ១នៃសេចក្ដីសម្រេចនេះ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលជាប្រចាំ ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាព។

ប្រការ៣ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មីនា ឆ្នាំ២០២៥

នាយករដ្ឋមន្ត្រី

សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ ៣០ សសរ ចុះថ្ងៃទី ៤ ខែមីនា ឆ្នាំ២០២៥

ផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២៥

វិធានការ/សកម្មភាព	ក្របខណ្ឌពេលនៃការរៀបចំ	ស្ថាប័ននាំមុខរៀបចំនិងអនុវត្ត	ស្ថាប័នសហការអនុវត្ត
យុទ្ធសាស្ត្រទី១ - ទាក់ទាញភ្ញៀវទេសចរអន្តរជាតិមកទស្សនាខេត្តសៀមរាប			
វិធានការគន្លឹះទី១ - ការផ្សព្វផ្សាយឱ្យស្គាល់ និងទាក់ទាញឱ្យមកទស្សនាខេត្តសៀមរាប			
វិធានការទី១ - លើកកម្ពស់រូបភាពខេត្តសៀមរាបជា "គោលដៅទេសចរណ៍វប្បធម៌ និងធម្មជាតិ"			
▪ ជំរុញការផ្សព្វផ្សាយគោលដៅទេសចរណ៍ក្នុងខេត្តសៀមរាបឱ្យបានទូលំទូលាយតាមគ្រប់រូបភាព និងគ្រប់មធ្យោបាយ៖		- ក្រសួងទេសចរណ៍/ ក.ផ.ផ.	- គ.អ.ទ.ស. / Sub-DMO - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
- រៀបចំការប្រកួតប្រជែងថតរូបទេសចរណ៍ឆ្នើម ក្នុងព្រឹត្តិការណ៍សំខាន់ៗ (សមរាត្រី, អង្គរសង្រ្កាន្ត..)	មីនា/មេសា/ កញ្ញា		
- ផ្សព្វផ្សាយអំពីទិដ្ឋភាពជាក់ស្តែង នៃភាពពេញចិត្តរបស់ភ្ញៀវទេសចរ និងរូបភាពវិជ្ជមាននានា	មករា - ធ្នូ		
- ផ្សព្វផ្សាយជាវីដេអូខ្លីៗ និងបង្ហាញពីខ្លឹមសារឱ្យចំទីផ្សារគោលដៅ និងទាក់ទាញការមកទស្សនា។	មករា - ធ្នូ		
▪ បង្កើនការយល់ឃើញជាវិជ្ជមានរបស់ភ្ញៀវទេសចរតាមថ្នាលបណ្តាញសង្គមល្បីៗ៖		- ក្រសួងទេសចរណ៍/ ក.ផ.ផ.	- គ.អ.ទ.ស. / Sub-DMO - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
- បង្កើនការផ្សព្វផ្សាយ និងលើកកម្ពស់រូបភាពល្អៗ ដើម្បីលុបបំបាត់នូវការផ្សព្វផ្សាយនូវរូបភាពអវិជ្ជមាននិងព័ត៌មានមិនពិត	មករា - ធ្នូ		
- ទាក់ទាញការរៀបចំកិច្ចប្រជុំកម្រិតតំបន់ កម្រិតអន្តរជាតិ ដើម្បីផ្សព្វផ្សាយពីរូបភាពវិជ្ជមានរបស់ខេត្តសៀមរាប	មេសា - ធ្នូ		

- លើកទឹកចិត្តដល់អ្នកជំនាញការអន្តរជាតិ និងសាស្ត្រាចារ្យស្រាវជ្រាវល្បីៗ នៅក្នុងក្របខណ្ឌនៃ ICC Angkor និងក្របខណ្ឌផ្សេងទៀត ឱ្យជួយផ្សព្វផ្សាយពីរូបភាពវិជ្ជមាននិងគុណតម្លៃបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ នៅខេត្តសៀមរាប	មករា - ធ្នូ		
- អញ្ជើញអ្នកសារព័ត៌មានក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍ និងបុគ្គលដែលមានឥទ្ធិពល(KOLs), Influencers ក្នុងស្រុក និងមកពីទីផ្សារសំខាន់ៗ ដូចជា អាមេរិក អឺរ៉ុប ចិន ជប៉ុន កូរ៉េ អូស្ត្រាលី និងឥណ្ឌា ធ្វើទស្សនកិច្ចនៅតាមគោលដៅទេសចរណ៍អាទិភាពក្នុងខេត្តសៀមរាប	មេសា - ធ្នូ		
- ជ្រើសរើស **"ទូតសុច្ឆន្ទៈ"** ដើម្បីផ្សព្វផ្សាយអំពីវិស័យទេសចរណ៍ខេត្តសៀមរាប	កុម្ភៈ - មេសា		
- សហការជាមួយដៃគូពាណិជ្ជកម្មផ្នែកទេសចរណ៍ និង/ឬភ្នាក់ងារទេសចរណ៍អនឡាញ ដើម្បីលើកកម្ពស់ និងរក្សាកិត្តិនាមទេសចរណ៍ខេត្តសៀមរាប ទៅកាន់ពិភពលោក (ជាអាទិ៍ Tripadvisor, Agoda, Booking.com, Expedia សម្រាប់ទីផ្សារអាមេរិកនិងអឺរ៉ុប, Trip.com... ជាដើម)	កុម្ភៈ - មេសា		
- បំផុស និងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋខ្មែរនិងសហគមន៍ខ្មែរដែលរស់នៅក្រៅប្រទេស ចូលរួមផ្សព្វផ្សាយអំពីរូបភាពវិជ្ជមានរបស់ទឹកដីកំណើតខ្លួន និងផ្សព្វផ្សាយពីវប្បធម៌របស់ជាតិ តាមរយៈគណនីបណ្ដាញសង្គមផ្ទាល់ខ្លួន (Facebook, YouTube, Tiktok, Instagram, X។ល។)	មករា - ធ្នូ		
- ដាក់ចេញកម្មវិធីផ្សព្វផ្សាយឌីជីថលដោយឈរលើអភិក្រមនៃការចូលរួមផ្សព្វផ្សាយពីគ្រប់ភាគីពាក់ព័ន្ធ **"អាជីពណា ផ្សាយពីអាជីពនោះ"** និង **"អ្នកស្រុកណា ផ្សាយពីស្រុកនោះ"** ដែលតម្រូវឱ្យមានការធ្វើអក្ខរកម្មឌីជីថលដល់គ្រប់ភាគីពាក់ព័ន្ធ អំពីរបៀបរៀបចំខ្លឹមសារផ្សព្វផ្សាយ ការធ្វើទីផ្សារ វិធីសាស្ត្រ និងឧបករណ៍ផ្សព្វផ្សាយតាមគ្រប់ទម្រង់។ល។ ស្របតាមទស្សនាទាន **"ទេសចរណ៍ដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីទេសចរណ៍"** និង **"ម្នាក់ៗជាអ្នកផ្សព្វផ្សាយទេសចរណ៍កម្ពុជាម្នាក់"**	មករា - ធ្នូ		
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីការទទួលបានជ័យលាភី ឬការទទួលស្គាល់ជាលក្ខណៈអន្តរជាតិនានារបស់គោលដៅទេសចរណ៍ខេត្តសៀមរាប (ឧទា.Tripadvisor, Lonely Planet...)។	មករា - ធ្នូ		

▪ លើកកម្ពស់រូបភាពខេត្តសៀមរាបជាគោលដៅទេសចរណ៍មានភាពទាក់ទាញខ្ពស់ផ្នែកថ្លៃៈ		- ក្រសួងទេសចរណ៍ - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	- គ.អ.ទ.ស. - អាជ្ញាធរជាតិអប្សរា - ក្រ. ពាក់ព័ន្ធ - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
- **ថ្លៃធ្វើដំណើរ** : (ឧទា. ធ្វើឱ្យតម្លៃសំបុត្រយន្តហោះប្រហាក់ប្រហែលនឹងប្រទេសជិតខាង[1] បន្ថកាត់បន្ថយចំណាយដើមផ្សេងៗមិនចាំបាច់ សិក្សាលទ្ធភាពលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់កញ្ចប់ទស្សនកិច្ចទេសចរណ៍។ល។)	មករា - ធ្នូ		
- **ថ្លៃស្នាក់នៅ និងហូបចុក**: (ឧទា. លើកទឹកចិត្តឱ្យមានហាងម្ហូបអាហារច្រើនប្រភេទនិងថ្លៃសមរម្យ មានការអប់រំនិងការផ្សព្វផ្សាយថ្លៃឱ្យបានត្រឹមត្រូវ និងមានការទុកចិត្តពីភ្ញៀវ ការលក់វត្ថុអនុស្សាវរីយ៍ត្រូវផ្តល់បដិសណ្ឋារកិច្ចល្អនិងតម្លៃច្បាស់លាស់។ល។)	មករា - ធ្នូ		
- **ថ្លៃសំបុត្រចូលទស្សនា** : (ឧទា. បំផុសចលនាពីវិស័យសាធារណៈនិងឯកជនលើយុទ្ធនាការ **"ថ្លៃ"** ដោយបង្កើតនូវ **"បណ្ណទស្សនាសៀមរាប"**។ល។)	មករា - មិថុនា		
▪ ផ្សព្វផ្សាយពីការអនុវត្តល្អ (Best Practice) នៃអាជីវកម្មទេសចរណ៍និងអាជីវកម្មពាក់ព័ន្ធក្នុងការអនុវត្តតាមស្តង់ដាជាតិនិងអន្តរជាតិលើការអភិវឌ្ឍប្រកបដោយចីរភាពៈ		- ក្រសួងទេសចរណ៍	- ក្រ. ពាក់ព័ន្ធ - វិស័យឯកជន
- **កម្រិតថ្នាក់ជាតិ** : បំផុសការផ្សព្វផ្សាយពីអាជីវកម្មទេសចរណ៍ដែលទទួលបានជ័យលាភីក្នុងការអនុវត្តតាមស្តង់ដាបៃតង និងស្តង់ដាគុណភាពនានា	មករា - ធ្នូ		
- **កម្រិតថ្នាក់តំបន់ និងអន្តរជាតិ** : បំផុសការផ្សព្វផ្សាយពីអាជីវកម្មទេសចរណ៍ដែលទទួលបានជ័យលាភី ឬការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ។	មករា - ធ្នូ		

[1] រាជរដ្ឋាភិបាលបានសម្រេចកាត់បន្ថយកម្រៃសិទ្ធិហោះហើរតែម្តង (Traffic Right Charge -Royalty) ដល់ក្រុមហ៊ុនអាកាសចរណ៍ដែលប្រតិបត្តិការជើងហោះហើរអន្តរជាតិទៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ រួចហើយ។

វិធានការទី២ - ទាក់ទាញទីផ្សារទេសចរណ៍អាទិភាពមកកាន់ខេត្តសៀមរាប			
▪ រៀបចំផែនការទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២៥-២០២៨ ដោយសិក្សាកំណត់ប្រភពនិងប្រភេទទីផ្សារទេសចរណ៍សំខាន់ៗដែលមានសក្តានុពលសម្រាប់វិស័យទេសចរណ៍ខេត្តសៀមរាប	មករា - មីនា	- ក្រសួងទេសចរណ៍/ ក. ផ. ផ.	- គ.អ.ទ.ស. / Sub-DMO - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
▪ ទន្ទឹមនេះ ក្រៅពី**ទីផ្សារអឺរ៉ុប និងអាម៉េរិក** ដែលបានកើនឡើងដល់កម្រិតប្រហាក់ប្រហែលមុនវិបត្តិ ចំពោះមុខគួរចាប់យកប្រភពទីផ្សារទេសចរណ៍សំខាន់ៗបន្ថែមមកកាន់ខេត្តសៀមរាប ជាអាទិ៍ ទីផ្សារឥណ្ឌា ចិន ថៃ វៀតណាម ឡាវ កូរ៉េ ជប៉ុន និងអូស្ត្រាលី។ **<u>សម្រាប់ទីផ្សារឥណ្ឌា៖</u>**		- ក្រសួងទេសចរណ៍/ ក. ផ. ផ.	-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ -ក្រសួងមហាផ្ទៃ - ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ - គ.អ.ទ.ស. / Sub-DMO - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
- រៀបចំកញ្ចប់ទស្សនកិច្ចសម្រាប់បែបទេសចរណ៍ជំនឿ ដោយផ្តោតលើការផ្សព្វផ្សាយ **"សៀមរាប ជាគោលដៅជំនឿសាសនា សម្រាប់ទេសចរឥណ្ឌា" (Pilgrimage Tourism)**	មករា - ធ្នូ		
- រៀបចំកញ្ចប់ទស្សនកិច្ចសម្រាប់កម្មវិធីមុនអាពាហ៍ពិពាហ៍ កម្មវិធីអាពាហ៍ពិពាហ៍ និងក្រោយអាពាហ៍ពិពាហ៍ ដោយផ្តោតលើ **"សៀមរាប ជាគោលដៅផ្តល់ពរជ័យ និងសុភមង្គល"**	មករា - ធ្នូ		
- បន្តរៀបចំទិវាអន្តរជាតិកីឡាយ៉ូហ្គា	មិថុនា		
- ទាក់ទាញការវិនិយោគ និងពង្រឹងគុណភាពសេវាកម្មផ្នែកភោជនីយដ្ឋានលក់ម្ហូបឥណ្ឌា។	មករា - ធ្នូ		
<u>សម្រាប់ទីផ្សារចិន៖</u>			
- រៀបចំ Fam Trip សម្រាប់វិស័យឯកជន និង ក្រុមសារព័ត៌មានចិនល្បីៗមកខេត្តសៀមរាប	មេសា - កញ្ញា		
- រៀបចំកម្មវិធី **"សៀមរាប ដោយជីវតាក្មាន់"** តាមសាកលវិទ្យាល័យនៅប្រទេសចិន ដែលមានកិច្ចសហការជាមួយកម្ពុជា (តំបន់ដែលមានអគ្គកុងស៊ុលកម្ពុជា)	មីនា - ឧសភា		
- ពង្រឹងសមត្ថភាពភាសាចិនដល់មគ្គុទ្ទេសក៍និយាយភាសាចិន និងប្រតិបត្តិករ អមដោយចំណេះដឹងអំពីឥរិយាបថទេសចរជនជាតិចិន។	មករា - ធ្នូ		

សម្រាប់ទីផ្សារថៃ៖			
- រៀបចំកញ្ចប់ទស្សនកិច្ចទេសចរណ៍តាមផ្លូវគោកនិងផ្លូវអាកាស ពីប្រទេសថៃ ដូចជា កញ្ចប់ទស្សនកិច្ចទេសចរណ៍សិក្សាស្រាវជ្រាវ កញ្ចប់ទស្សនកិច្ចមុននិងក្រោយអាពាហ៍ពិពាហ៍ ការលើកទឹកចិត្តប្រចាំឆ្នាំរបស់បុគ្គលិកក្រុមហ៊ុន (Incentive Program) កញ្ចប់ទស្សនកិច្ចរួមសៀមរាប ប៉ាតាយ៉ា សម្រាប់ទេសចរប្រទេសទីពោ	មករា - មេសា		
- សិក្ខាសាលាពង្រឹងកិច្ចសហការទេសចរណ៍ MoU ជាមួយអាជ្ញាធរទេសចរណ៍ថៃ (TAT) និងអាជ្ញាធរខេត្តជាប់ព្រំដែន ដើម្បីទទួលបានការគាំទ្របន្ថែមនិងជំរុញការអនុវត្ត។	មករា - មីនា		
សម្រាប់ទីផ្សារវៀតណាម៖			
- សិក្ខាសាលាពង្រឹងកិច្ចសហការទេសចរណ៍ MoU ជាមួយអាជ្ញាធរជាតិទេសចរណ៍វៀតណាម (VNAT) និងអាជ្ញាធរខេត្តជាប់ព្រំដែន ដើម្បីទទួលបានការគាំទ្របន្ថែមនិងជំរុញការអនុវត្ត	មករា - មីនា		
- សហការរៀបចំកញ្ចប់ទស្សនកិច្ចជាមួយប្រតិបត្តិករកម្ពុជា និងវៀតណាម	មករា - មីនា		
- រៀបចំកញ្ចប់ទស្សនកិច្ចទេសចរណ៍ តាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ពីវៀតណាម សៀមរាប-ហាឡុង សៀមរាប-ដាណាំង សៀមរាប-ភូកុក សៀមរាប-ហាណូយ សៀមរាប-ហូជីមិញ សម្រាប់ទេសចរប្រទេសទីពោ។	មករា - មីនា		
សម្រាប់ទីផ្សារឡាវ៖			
- សិក្ខាសាលាពង្រឹងកិច្ចសហការទេសចរណ៍ MoU ជាមួយក្រសួងទេសចរណ៍ឡាវ និងអាជ្ញាធរខេត្តជាប់ព្រំដែន ដើម្បីទទួលបានការគាំទ្របន្ថែមនិងជំរុញការអនុវត្ត	មករា - មីនា		
- សហការរៀបចំកញ្ចប់ទស្សនកិច្ចជាមួយប្រតិបត្តិករកម្ពុជានិងឡាវ	មករា - មីនា		
- រៀបចំកញ្ចប់ទស្សនកិច្ចទេសចរណ៍ តាមផ្លូវគោក និងផ្លូវអាកាស ពីឡាវ សៀមរាប- ហ្លួងប្រាបាង សម្រាប់ទេសចរប្រទេសទីពោ។	មករា - មីនា		

សម្រាប់ទីផ្សារកូរ៉េ៖			
- រៀបចំផលិតផលទេសចរណ៍ថ្មីៗ ស្របតាមចំណង់ចំណូលចិត្តទីផ្សារទេសចរណ៍កូរ៉េ	មករា - មិថុនា		
- ទាក់ទាញផលិតកម្មកូរ៉េ មកថតកម្មវិធីទូរទស្សន៍ នៅតាមគោលដៅទេសចរណ៍សៀមរាប	មករា - ធ្នូ		
- ពង្រឹងសមត្ថភាពមគ្គុទេសក៍ទេសចរណ៍និយាយភាសាកូរ៉េឱ្យបានច្រើននិងច្បាស់លាស់	មករា - ធ្នូ		
- រៀបចំ Fam Trip សម្រាប់វិស័យឯកជននិងក្រុមសារព័ត៌មានកូរ៉េល្បីៗមកខេត្តសៀមរាប។	មេសា - កញ្ញា		
សម្រាប់ទីផ្សារជប៉ុន៖			
- រៀបចំផលិតផលទេសចរណ៍ថ្មីៗ ស្របតាមចំណង់ចំណូលចិត្តទីផ្សារទេសចរណ៍ជប៉ុន ដូចជាផលិតផលទេសចរណ៍ (MICE) ផលិតផលគិតគូរពីបរិស្ថាន។ល។	មករា - មិថុនា		
- រៀបចំ Fam Trip សម្រាប់វិស័យឯកជននិងក្រុមសារព័ត៌មានជប៉ុនល្បីៗមកខេត្តសៀមរាប	មេសា - កញ្ញា		
- រៀបចំកម្មវិធីផ្លាស់ប្តូរបទពិសោធ ដូចជា ការរៀបចំដំណើរទស្សនកិច្ចសិក្សាស្វែងយល់វប្បធម៌និងធម្មជាតិរបស់ខេត្តរវាងនិស្សិតជប៉ុននិងនិស្សិតខ្មែរ	មេសា - កញ្ញា		
- ពង្រឹងសមត្ថភាពភាសាជប៉ុនដល់មគ្គុទ្ទេសក៍និយាយភាសាជប៉ុន និងប្រតិបត្តិករ ឱ្យបានច្រើននិងច្បាស់លាស់។	មករា - ធ្នូ		
សម្រាប់ទីផ្សារអូស្ត្រាលី៖			
- បន្តធ្វើការផ្សព្វផ្សាយទៅកាន់ទីផ្សារទេសចរណ៍អូស្ត្រាលី តាមរយៈការចូលរួមពិព័រណ៍នៅប្រទេសអូស្ត្រាលី	មករា - ធ្នូ		
- ការរៀបចំ Fam Trip និង Tourism Road Show ដោយសហការជាមួយនឹងសភាពាណិជ្ជកម្មកម្ពុជា -អូស្ត្រាលី និងសមាគមខ្មែរនៅអូស្ត្រាលី	មករា - ធ្នូ		
- ជំរុញឱ្យមានការហោះហើរត្រង់ពីអូស្ត្រាលីរបស់ក្រុមហ៊ុនអាកាសចរណ៍ Qantas ឬក្រុមហ៊ុនអាកាសចរណ៍ជាតិ Cambodia Angkor Air។	មករា - ធ្នូ		

សម្រាប់ទីផ្សារផ្ទៃក្នុងអាស៊ាន (Intra-ASEAN Travelers)÷			
- ជំរុញ និងបង្កើនកាតភ្ជាប់និងការហោះហើរពីបណ្ដាប្រទេសក្នុងតំបន់អាស៊ានមកកាន់ខេត្តសៀមរាប (ឧទា. ការទាក់ទាញជើងហោះហើរថ្មីៗមកកាន់ខេត្តសៀមរាប ចូលរួមអនុវត្តបណ្ដាកម្មវិធីក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទេសចរណ៍អាស៊ាន...)	មករា - ធ្នូ		
- សហការរៀបចំកញ្ចប់ទស្សនកិច្ចទេសចរណ៍ និងផ្សព្វផ្សាយរួមគ្នាជាមួយប្រទេសថៃ វៀតណាម ឡាវ និង/ឬ ប្រទេសក្នុងតំបន់ផ្សេងទៀត ក្រោមមូលបទ **"ប្រទេសពីរ គោលដៅទេសចរណ៍មួយ"** និង **"ប្រទេសបី/បួន គោលដៅទេសចរណ៍មួយ"** និងការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯង	មករា - ធ្នូ		
- បន្តសម្រួលការធ្វើដំណើរ និងកាត់បន្ថយរបាំងមិនចាំបាច់ (ឧទា. សិក្សាការលើកលែងទិដ្ឋាការសម្រាប់ភ្ញៀវទេសចរបរទេសដែលរស់នៅឬធ្វើការក្នុងបណ្ដាប្រទេសអាស៊ាន...)។	មករា - ធ្នូ		
▪ ពង្រីកចំណែកទីផ្សារទេសចរណ៍អន្តរជាតិមកខេត្តសៀមរាប ដោយផ្ដោតលើប្រភេទទីផ្សារទេសចរណ៍ថ្មីៗ (Niche Markets)៖ - គិតគូរបន្ថែមលើការរៀបចំសម្បទាទេសចរណ៍ និងការបង្កលក្ខណៈងាយស្រួលបន្ថែមទៀត ដើម្បីទាក់ទាញទេសចរណ៍បែបសាសនានិងជំនឿ ទេសចរណ៍ម៉ាយ (MICE) ទេសចរដែលធ្វើការចល័តតាមឌីជីថល (Digital Nomad) ទេសចរណ៍កីឡា ទេសចរណ៍ជនបទ និងកសិ-ទេសចរណ៍ ទេសចរណ៍តាមផ្លូវទឹក ទេសចរណ៍រៀបចំកម្មវិធីអាពាហ៍ពិពាហ៍។ល។	មករា - កញ្ញា	- ក្រសួងទេសចរណ៍/ ក.ផ.ផ.	- គ.អ.ទ.ស. / Sub-DMO - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
វិធានការគន្លឹះទី២ - បង្កលក្ខណៈងាយស្រួលដល់ការសម្រេចចិត្ត និងការរៀបចំដំណើរទេសចរណ៍មកកាន់ខេត្តសៀមរាប			
វិធានការទី៣ - ពង្រឹងការផ្ដល់ព័ត៌មានអំពីគោលដៅទេសចរណ៍ខេត្តសៀមរាបដល់ភ្ញៀវទេសចរអន្តរជាតិ			
▪ បង្កលក្ខណៈងាយស្រួលក្នុងការធ្វើការកក់ (Booking) មកខេត្តសៀមរាប៖			

- តាមរយៈថ្នាលអនឡាញ : បង្កើនប្រសិទ្ធភាពនៃការស្វែងរកគេហទំព័រ និងថ្នាលឌីជីថលនានាដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ខេត្តសៀមរាប នៅលើប្រព័ន្ធស្វែងរក ដូចជា Google, Baidu.com, Naver.com ជាដើម តាមរយៈវិធីសាស្ត្រ Search Engine Optimization (SEO) និង AI	មករា - ធ្នូ	- ក្រសួងទេសចរណ៍ / ក.ផ.ផ.	- គ.អ.ទ.ស. / Sub-DMO - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
- តាមរយៈការីទេសចរណ៍ : ពង្រឹងការីទេសចរណ៍ ពិសេសការីទេសចរណ៍នាំភ្ញៀវចូលជាតិនិងអន្តរជាតិ មានសមត្ថភាពក្នុងការចូលទីផ្សារទេសចរណ៍ក្នុងតំបន់និងអន្តរជាតិ។	មីនា - មិថុនា		
▪ សិក្សាផ្តល់ការលើកទឹកចិត្ត (Incentives) ដល់ការីទេសចរណ៍ដែលបាននាំភ្ញៀវ មកទស្សនាខេត្តសៀមរាបច្រើនជាងគេ ប្រចាំឆ្នាំ២០២៥	មីនា - មិថុនា	- ក្រសួងទេសចរណ៍ / ក.ផ.ផ.	- គ.អ.ទ.ស. / Sub-DMO - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
▪ សហការពង្រឹងទំនាក់ទំនងជាមួយនឹងបណ្តាស្ថានទូតនិងស្ថានតំណាងបរទេសប្រចាំកម្ពុជា ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបណ្តាប្រទេសទីផ្សារទេសចរណ៍សំខាន់ៗ ដើម្បីផ្សព្វផ្សាយអំពីទេសចរណ៍ខេត្តសៀមរាប	មករា - ធ្នូ	- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	- ក្រសួងទេសចរណ៍/ ក.ផ.ផ. - វិស័យឯកជន
▪ ជំរុញការបង្កើតអនុព័ន្ធទេសចរណ៍អមស្ថានទូតកម្ពុជាប្រចាំនៅទីផ្សារទេសចរណ៍អាទិភាព (ចិន ជប៉ុន កូរ៉េ អាមេរិក ឥណ្ឌា អូស្ត្រាលី បារាំង អង់គ្លេស អាល្លឺម៉ង់...)។	មករា - ធ្នូ	- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	- ក្រសួងទេសចរណ៍ - ក.ផ.ផ.
វិធានការទី៤ - បង្កើនការតភ្ជាប់ និងសហប្រតិបត្តិការទេសចរណ៍អន្តរជាតិ			
▪ **ផ្លូវអាកាស** : បង្កលក្ខណៈងាយស្រួលដល់ការចាប់យកប្រភពទីផ្សារទេសចរណ៍សំខាន់ៗ និងបង្កើនជើងហោះហើរត្រង់ពីប្រភពទីផ្សារអាទិភាព ឱ្យបានច្រើន មកកាន់ខេត្តសៀមរាប៖			
- ជំរុញនិងទាក់ទាញក្រុមហ៊ុនអាកាសចរណ៍និងជើងហោះហើរថ្មីៗមកកាន់ខេត្តសៀមរាបឱ្យបានច្រើន ពិសេស "**ថ្លៃទាប**" (LCCs) តាមរយៈកម្មវិធីពិសេសសម្រាប់ឆ្នាំ២០២៥ ក្នុងនោះ ការបញ្ចុះថ្លៃ	មករា - មេសា		

ចុះចត (Landing) ថ្លៃចំណត (Parking) ថ្លៃភ្លើងបំភ្លឺ (Lighting) និងថ្លៃស្ពានឆ្លងចូលយន្តហោះ នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ		- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ក្រុមហ៊ុនគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ - ក្រុមហ៊ុនអាកាសចរណ៍	- ក្រសួងទេសចរណ៍/ក. ផ. ផ. - ក្រ. ពាក់ព័ន្ធ - វិស័យឯកជន
- ការពង្រឹងក្រុមហ៊ុនអាកាសចរណ៍ជាតិ **"កម្ពុជាអង្គរអ៊ែរ"** និង/ឬ លើកទឹកចិត្តក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និង/ឬ ក្រុមហ៊ុនអាកាសចរណ៍ Air Asia ហោះត្រង់ទៅកាន់សៀមរាប - ញ៉ូវដេលី សៀមរាប - បាលី សៀមរាប- ប៊្រូបន្ធ សៀមរាប - ម៉ាល់ឌីវ។ល។	មករា - តុលា		
- សិក្សាលទ្ធភាពបន្ធូរបន្ថយពន្ធប្រេងសាំងចាក់យន្តហោះនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ សម្រាប់ឆ្នាំ២០២៥	មករា - មិថុនា		
- ពិនិត្យឡើងវិញ និងសម្រួល Slot ម៉ោងហោះហើរតភ្ជាប់មកកាន់អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ឱ្យមានភាពទាក់ទាញជាងមុន។	មករា - មីនា		
▪ **ផ្លូវគោក:** សម្រួលការធ្វើដំណើរដល់ភ្ញៀវទេសចរដែលឆ្លងកាត់តាមច្រកទ្វារព្រំដែនអន្តរជាតិផ្លូវគោក ចូលមកកម្ពុជា និងបន្តមកដល់គោលដៅខេត្តសៀមរាប ពិសេសនៅច្រកទ្វារប៉ោយប៉ែត និងអូរស្មាច់ ពីប្រទេសថៃ ច្រកទ្វារបាវិត ពីប្រទេសវៀតណាម និង ច្រកទ្វារត្រពាំងក្រៀល ពីប្រទេសឡាវ		- ក្រសួងទេសចរណ៍/គ. អ. ច. ទ. - ក្រសួងមហាផ្ទៃ	- ក្រសួងការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា - ក. ផ. ផ. - ក្រុមហ៊ុនអាកាសចរណ៍ - ក្រ... - ...ខេត្ត... - ...
- ជំរុញចលនា **"ការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯង"** សំដៅសម្រួលការធ្វើដំណើរទេសចរណ៍ពីបណ្តាប្រទេសក្នុងតំបន់អាស៊ានចូលមកខេត្តសៀមរាបឱ្យកាន់តែប្រសើរថែមទៀត ក្នុងនោះត្រូវរៀបចំអនុក្រឹត្យស្តីពី **"នីតិវិធីប្រតិបត្តិស្តង់ដា (SOP) ស្តីពីការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯង"**	មករា - មេសា		
- សិក្សាលទ្ធភាពការផ្តល់នូវបណ្ណធ្វើដំណើរ (Laissez-passer) សម្រាប់ប្រជាពលរដ្ឋថៃដែលរស់នៅខេត្តជាប់ព្រំដែនអាចចូលមកទស្សនាខេត្តសៀមរាប	មករា - ធ្នូ		
- សម្រួលការធ្វើដំណើរចេញ- ចូលតាមផ្លូវអាកាស និងផ្លូវគោកឱ្យកាន់តែប្រសើរនិងងាយស្រួល ដោយបង្កើតជាកម្មវិធីពិសេស និងមានក្រុមការងារបដិសណ្ឋារកិច្ចពិសេសនៅច្រកទ្វារទាំងនោះ។	មករា - ធ្នូ		

វិធានការគន្លឹះទី៣ - បង្កលក្ខណៈងាយស្រួលក្នុងការមកដល់របស់ភ្ញៀវទេសចរនៅខេត្តសៀមរាប			
វិធានការទី៥ - សម្រួលការធ្វើដំណើរទេសចរណ៍នៅតាមច្រកទ្វារអន្តរជាតិ			
▪ ជំរុញការបង្កលក្ខណៈងាយស្រួលនៅក្នុងអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ដោយ៖		- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	- ក្រសួងមហាផ្ទៃ/អ.អ. - អាជ្ញាធរជាតិអប្សរា - អាកាសយានដ្ឋាន - ក្រសួងទេសចរណ៍ - ក្រ.ពាក់ព័ន្ធ - រដ្ឋបាលខេត្តសៀមរាប
- សហការរៀបចំជាមួយ**ក្រុមហ៊ុនដែលមានជំនាញ**ក្នុងការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដើម្បីពង្រឹងការគ្រប់គ្រងនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ	មករា - មីនា		
- បន្ថែមសម្បទា សេវាកម្ម និងផលិតផលនៅក្នុងអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ដូចជាហាងលក់ទំនិញ ភោជនីយដ្ឋាន កន្លែងកម្សាន្ត កីឡា និងសួនកុមារ	មករា - ធ្នូ		
- ពង្រឹងសមត្ថភាពមន្ត្រីនៅក្នុងអាកាសយានដ្ឋានក្នុងការផ្ដល់សេវាកម្មនិងបដិសណ្ឋារកិច្ចល្អដល់ភ្ញៀវទេសចរ	មករា - ធ្នូ		
- ពង្រឹងយន្តការគ្រប់គ្រងរថយន្តតាក់ស៊ី នៅ**អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ** (ធានាតម្លៃសមរម្យ)	មករា - ធ្នូ		
- សម្រួលការធ្វើដំណើរភ្ញៀវទេសចរពីអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរទៅមកក្រុងសៀមរាប ក្នុងនោះជំរុញការពង្រីកផ្លូវចូលក្រុងសៀមរាប ចាប់ពីកន្លែងច្រកចូលអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរឆ្ពោះទៅក្រុងសៀមរាប	មករា - ធ្នូ		
- បន្តចរចាឱ្យក្រុមហ៊ុនមិនយកថ្លៃផ្លូវចូលព្រលាន មិនយកប្រាក់សម្រាប់ការចូលដាក់ភ្ញៀវ[2]	មករា - មេសា		

[2] ការងារនេះ **សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** បានណែនាំរួចហើយកាលពីឆ្នាំ២០២៤។

- ជំរុញការអនុវត្តគម្រោងរថភ្លើងធុនស្រាល (Tramway) ភ្ជាប់ពីអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ -រុនតាឯក -ក្រុងសៀមរាប	មករា - ធ្នូ		
- សិក្សាផ្លូវតភ្ជាប់ពីអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ- រុនតាឯក- តំបន់អង្គរ-ក្រុងសៀមរាប។	មករា - មេសា		
▪ ជំរុញការបង្កលក្ខណៈងាយស្រួលតាមច្រកចូលផ្លូវគោក ដោយៈ		- ក្រសួងមហាផ្ទៃ/អ.អ. - ក្រសួងទេសចរណ៍/គ.អ.ច.ទ.	- រដ្ឋបាលខេត្តពាក់ព័ន្ធ - ក្រសួងសាធារណការ និងដឹកជញ្ជូន - វិស័យឯកជន
- បង្កលក្ខណៈងាយស្រួលដល់ការធ្វើដំណើរទេសចរណ៍នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត អូរស្មាច់ បាវិត និងត្រពាំងក្រៀល ដោយបង្កើតឱ្យមានក្រុមបដិសណ្ឋារកិច្ចពិសេស និង Lane ពិសេស	មករា - ធ្នូ		
- ពង្រឹងការគ្រប់គ្រងរថយន្តដឹកភ្ញៀវទេសចរពីច្រកទ្វារទាំងនេះមកក្រុងសៀមរាប លើទិដ្ឋភាពតម្លៃ គុណភាព និងសុវត្ថិភាព។	មករា - ធ្នូ		
វិធានការគន្លឹះទី៤ - សម្រួលដល់ដំណើរកម្សាន្តក្នុងខេត្តសៀមរាប ស្របតាមទិសស្លោក "សៀមរាបៈ តារាវនាទិសខុត្តរ"			
វិធានការទី៦ - ពិពិធកម្មគោលដៅទេសចរណ៍នៅតាមតំបន់អាទិភាពទាំង៦			
▪ កសាងនិងកែលម្អឱ្យកាន់តែប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាគាំទ្រទេសចរណ៍ នៅតាមគោលដៅអាទិភាពដូចខាងក្រោមៈ			
<u>១- តំបន់បេតិកភណ្ឌអង្គរៈ</u>		- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/អាជ្ញាធរជាតិអប្សរា	- គ.អ.ទ.ស. - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/គ្រឹះស្ថានអង្គរ - រដ្ឋបាលខេត្តសៀមរាប - ក្រ[illegible]
- បន្តលើកទឹកចិត្ត និងសម្រួលនូវលក្ខខណ្ឌតម្រូវថ្មីពាក់ព័ន្ធនឹងការថតវីដេអូឬរូបភាពសន្លឹកក្នុងតំបន់រមណីយដ្ឋានអង្គរ[3]	មករា - ធ្នូ		
- សិក្សាបង្កើនវង់ទស្សនាប្រាសាទឱ្យមានច្រើនជម្រើសសម្រាប់ភ្ញៀវទេសចរ	មករា - មិថុនា		
- រៀបចំផែនការសេវាកម្មដឹកជញ្ជូនទេសចរណ៍ក្នុងតំបន់អង្គរ	មករា - ធ្នូ		
- សិក្សារៀបចំឱ្យមានសេវាកម្មអាហារនិងភេសជ្ជៈ (F&B) នៅតាមទីតាំងជាក់លាក់មួយចំនួននៅក្នុងតំបន់អង្គរ ដោយត្រូវអនុលោមតាមសៀវភៅបន្ទុកច្បាស់លាស់ពីអាជ្ញាធរជាតិអប្សរា	មករា - មេសា		

[3] អាជ្ញាធរជាតិអប្សរាបាននិងកំពុងកែសម្រួលការងារនេះ ក្រោយ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** បានណែនាំ។

- ថែរក្សាភាពស្អាត អនាម័យ សន្តិសុខ និងសណ្តាប់ធ្នាប់	មករា - ធ្នូ		- ក្រ.ពាក់ព័ន្ធ - វិស័យឯកជន - ដៃគូអភិវឌ្ឍ
- បង្កើនការផ្សព្វផ្សាយអំពីប្រភេទប្រាសាទ ឬក្រុមប្រាសាទ ដែលអនុញ្ញាតឱ្យរៀបចំព្រឹត្តិការណ៍ទេសចរណ៍និងវប្បធម៌	មករា - ធ្នូ		
- ពង្រឹងការគ្រប់គ្រងសេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍ : ដើម្បីឱ្យការគ្រប់គ្រងសេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍បានល្អប្រសើរ ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលវិក្រឹតការពិសេស ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍និងអាជ្ញាធរជាតិអប្សរា	មករា - ធ្នូ		
- បន្តរៀបចំដាក់ភ្លើងបំភ្លឺពេលយប់នៅតាមផ្លូវសំខាន់ៗក្នុងតំបន់អង្គរ	មករា - ធ្នូ		
- រៀបចំព្រឹត្តិការណ៍ និងផលិតផលទេសចរណ៍ថ្មីៗបន្ថែម អនុលោមតាមគោលការណ៍នៃទេសចរណ៍វប្បធម៌-ទេសចរណ៍បៃតង	មករា - ធ្នូ		
- បន្តការអនុវត្តការកែសម្រួលពេលវេលាបើក-បិទ នៃការចូលទស្សនាប្រាសាទក្នុងរមណីយដ្ឋានអង្គរ និងសិក្សាលទ្ធភាពកែសម្រួលពេលវេលាបើក-បិទផ្សេងៗទៀត ដោយផ្អែកលើតម្រូវការជាក់ស្តែងរបស់ភ្ញៀវទេសចរ[3]	មករា - ធ្នូ		
- រៀបចំបញ្ជីព័ត៌មានទេសចរណ៍ អមជាមួយការបំពាក់សម្បទាឱ្យបានគ្រប់គ្រាន់	មករា - តុលា		
- បន្តពង្រឹងការធ្វើពិពិធកម្មសកម្មភាពបម្រើឱ្យទេសចរណ៍ក្នុងតំបន់អង្គរ ឱ្យកាន់តែមានភាពសម្បូរបែប ស្របតាមតម្រូវការថ្មីៗរបស់ភ្ញៀវទេសចរគ្រប់កម្រិត ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ "**ការអភិរក្សគាំទ្រដល់ការអភិវឌ្ឍ ហើយការអភិវឌ្ឍបម្រើដល់ការអភិរក្ស**"។	មករា - ធ្នូ		
- **ឌីជីថលអង្គរ (Digital Angkor)៖**		- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/អាជ្ញាធរជាតិអប្សរា - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍	- គ.អ.ទ.ស. - រដ្ឋ[illegible] - ក្រ.ពាក់ព័ន្ធ
• បន្តធ្វើទំនើបកម្ម កម្មវិធីទូរសព្ទ Visit Angkor ដើម្បីផ្សព្វផ្សាយពីរង់ទស្សនាប្រាសាទគោលដៅទេសចរណ៍ និងផលិតផលទេសចរណ៍ថ្មីៗនៅក្នុងតំបន់រមណីយដ្ឋានអង្គរ	មករា - ធ្នូ		
• ជំរុញការអនុវត្តគម្រោងបង្កើតសារមន្ទីរ Immersive Angkor	មករា - ធ្នូ		
• សិក្សាលទ្ធភាពដាក់ឱ្យដំណើរការ "**សារមន្ទីរសព្វទស្សន៍អង្គរ**" (Angkor Panorama)	មករា - ធ្នូ		

• បន្តជំរុញទំនើបកម្មប្រព័ន្ធគ្រប់គ្រងការលក់សំបុត្ររបស់គ្រឹះស្ថានអង្គរ ដែលប្រព័ន្ធនេះអាចជួយដល់ការគ្រប់គ្រងទិន្នន័យរំហូររបស់ភ្ញៀវទេសចរ	មករា - ធ្នូ	- គ្រឹះស្ថានអង្គរ - ក្រុមហ៊ុន Immersive Angkor	
• ជំរុញសេវាទូរគមនាគមន៍ក្នុងតំបន់អង្គរ។	មករា - ធ្នូ		
២- ក្រុងសៀមរាប៖			
- រៀបចំកែលម្អស្ទឹងសៀមរាប (ផ្នែកកណ្តាល) ជាកន្លែងកម្សាន្តទេសចរណ៍	មករា - ធ្នូ	- អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ក្រុងសៀមរាប - គ.អ.ទ.ស.	- ក្រសួងទេសចរណ៍ - ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/អាជ្ញាធរជាតិអប្សរា - ក្រសួងពាណិជ្ជកម្ម - ក្រសួងសាធារណការនិងដឹកជញ្ជូន - ក្រ.ពាក់ព័ន្ធ - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន - ដៃគូអភិវឌ្ឍ
- រៀបចំ "**សង្កាត់ទេសចរណ៍គំរូ**" នៅក្រុងសៀមរាប ផ្សារភ្ជាប់នឹងការរៀបចំវត្តទេសចរណ៍	មករា - ធ្នូ		
- រៀបចំវិថីម្ហូបអាហារនិងផ្សាររាត្រីឱ្យមានភាពទាក់ទាញ	មករា - ធ្នូ		
- ពង្រឹងភាពស្អាតនិងបៃតង	មករា - ធ្នូ		
- ពង្រឹងសណ្តាប់ធ្នាប់តាមផ្លូវក្នុងទីក្រុង ចំណតរថយន្ត និងចំណតរ៉ឺម៉កកង់បី	មករា - មេសា		
- តុបតែងលម្អក្នុងទីក្រុង	មករា - ធ្នូ		
- ទំនើបកម្មសេវាកម្មមណ្ឌលព័ត៌មានទេសចរណ៍	មករា - មិថុនា		
- ពង្រឹងគុណភាពសេវាហាងលក់ទំនិញ វត្ថុអនុស្សាវរីយ៍ ពិសេសត្រូវមានតម្លៃ តាមរយៈការបង្កើតយន្តការគ្រប់គ្រងច្បាស់លាស់ ដើម្បីធានាទំនុកចិត្តដល់ភ្ញៀវទេសចរ	មករា - មេសា		
- គិតគូរលើសម្បទាទាក់ទាញប្រភេទទេសចរណ៍ Digital Nomad (Co-Working Spaces និងប្រភេទទិដ្ឋាការពិសេស)	មករា - កញ្ញា		
- សិក្សានិងកំណត់ទីតាំងរៀបចំតំបន់ (zoning) សេវាកម្មមណ្ឌលកម្សាន្តមនុស្សពេញវ័យ។	មករា - កញ្ញា		
៣- តំបន់បឹងទន្លេសាប (ពិសេសនៅចុងឃ្នៀស កំពង់ភ្លុក កំពង់ឃ្លាំង និងបឹងពាំរាំង (ជ្រាវ))៖			
- សិក្សាគម្រោងកែលម្អផ្លូវចូលទៅសហគមន៍ចុងឃ្នៀស កំពង់ភ្លុក បឹងពាំរាំង និងកំពង់ឃ្លាំង	មករា - ធ្នូ	- អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់បឹងទន្លេសាប - គ.អ.ទ.ស.	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/គ្រឹះស្ថានអង្គរ - ក្រសួងទេសចរណ៍ - អាជ្ញាធរជាតិទន្លេសាប
- កែលម្អទូកទេសចរណ៍នៅតំបន់បឹងទន្លេសាប ជាជំហានៗ ស្របតាមតម្រូវការនិងសំណូមពរជាច្រើនពីភ្ញៀវទេសចរ ក៏ដូចជាសហគមន៍ដែលជាអ្នកផ្គត់ផ្គង់សេវាទូកទេសចរណ៍នេះផ្ទាល់តែម្តង	មករា - ធ្នូ		
- ពង្រឹងសហគមន៍ ទាំងធនធាននិងសមត្ថភាពក្នុងការទទួលស្វាគមន៍ភ្ញៀវ	មករា - ធ្នូ		

- បញ្ចុះតម្លៃទូកសម្រាប់ភ្ញៀវក្នុងស្រុកនៅចុងឃ្លៀស[4]	កុម្ភៈ - ឧសភា		- អាជ្ញាធរទន្លេសាប - ក្រ. ពាក់ព័ន្ធ - រដ្ឋបាលខេត្តសៀមរាប - សហគមន៍ - វិស័យឯកជន - ដៃគូអភិវឌ្ឍ
- ជំរុញសកម្មភាពសិប្បកម្មងាយៗនៅតាមសហគមន៍	កុម្ភៈ - ឧសភា		
- សិក្សារៀបចំប្រព័ន្ធបង់វិលស់ទូកទេសចរណ៍នៅក្នុងសហគមន៍ទេសចរណ៍ក្នុងតំបន់បឹងទន្លេសាប (ដោយមានការផ្ដល់ការធានាពីរដ្ឋ អមជាមួយការកំណត់នូវលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការធានាច្បាស់លាស់)	កុម្ភៈ - ឧសភា		
- រៀបចំឱ្យមានទីតាំងថតរូបអនុស្សាវរីយ៍ ជាមួយទេសភាពស្អាតៗ	មេសា - កញ្ញា		
- ពង្រឹងការគ្រប់គ្រងសំរាម សំណល់រឹង-រាវ	មករា - ធ្នូ		
- រៀបចំឱ្យមានការសម្ដែងទស្សនីយភាពផ្សេងៗ ឬបុណ្យប្រពៃណីប្រចាំតំបន់ ឬព្រឹត្តិការណ៍ផ្សេងៗ។	មករា - ធ្នូ		
៤- តំបន់ឧទ្យានជាតិភ្នំគូលែន៖			
- ដាក់ឱ្យដំណើរការអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ភ្នំគូលែន	មករា - កុម្ភៈ	- អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម-"ភ្នំគូលែន" - គ.អ.ទ.ស.	- ឧ.ជ.ភ.គ. - រដ្ឋបាលខេត្តសៀមរាប - ក្រសួងបរិស្ថាន - ក្រសួងទេសចរណ៍ - ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/អាជ្ញាធរជាតិអប្សរា - ក្រ. ពាក់ព័ន្ធ - ក្រុមហ៊ុនទទួលសិទ្ធិ - សហគមន៍ - វិស័យឯកជន - ដៃគូ[illegible]
- រៀបចំសណ្ដាប់ធ្នាប់	មករា - ធ្នូ		
- កែលម្អផ្លូវឡើង និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ (ដូចជា ខ្សែ-តូបអាហារ រៀបចំមណ្ឌលព័ត៌មានទេសចរណ៍នៅជើងភ្នំ កែលម្អបន្ទប់ទឹកនៅលើភ្នំ គ្រប់គ្រងសំរាម)	មករា - ធ្នូ		
- រៀបចំផ្លូវទស្សនាចរណ៍បន្ថែម ទៅកាន់ទីតាំងធម្មជាតិនិងវប្បធម៌	មករា - ធ្នូ		
- ពិពិធកម្មផលិតផល និងសេវាទេសចរណ៍ រួមទាំងសហគមន៍ព្រៃធំអន្លង់ធំ និងសហគមន៍ព្រៃធំពពេល	មករា - ធ្នូ		
- រៀបចំបង្កើតមណ្ឌលវិបស្សនា ឬសមាធិ ឱ្យមានមាត្រដ្ឋានជាទីជ្រះថ្លា នៅតំបន់ភ្នំគូលែន	មករា - ធ្នូ		
- ពង្រឹងសមត្ថភាពសហគមន៍ ពិសេសគុណភាពសេវាកម្ម	មករា - ធ្នូ		
- សិក្សាសម្រួលថ្លៃសំបុត្រចូលទស្សនា	មករា - មិថុនា		
- បំពាក់សេវាទូរគមនាគមន៍។	មករា - ធ្នូ		

[4] ត្រីះស្ថានអង្គរបាននិងកំពុងកែសម្រួលការងារនេះ ក្រោយទទួលបានការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**។

៥- តំបន់ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី៖		- អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី - គ.អ.ទ.ស.	- ក្រសួងទេសចរណ៍ - ក្រ.ពាក់ព័ន្ធ - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
- ដាក់ឱ្យដំណើរការអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី	មករា - កុម្ភៈ		
- ការកែលម្អផ្លូវទៅបន្ទាយស្រី	មករា - ធ្នូ		
- ផ្សារភ្ជាប់ការអភិវឌ្ឍជាមួយក្រុងរុនតាឯកតេជោសែន	មករា - ធ្នូ		
- ការរៀបចំភូមិទេសចរណ៍គិរូ (ដាក់ភូមិព្រះដាក់ជាភូមិទេសចរណ៍ឆ្នើមនៃអង្គការទេសចរណ៍ពិភពលោក - UN Tourism)	មករា - ធ្នូ		
- ការពង្រឹងសហគមន៍។	មករា - ធ្នូ		
៦- តំបន់ទេសចរណ៍សៀមរាបថ្មី - ក្រុងរុនតាឯកតេជោសែន៖		- គ.អ.រ.ព.ស. - គ.អ.ទ.ស.	- ក្រសួងទេសចរណ៍ - រដ្ឋបាលខេត្តសៀមរាប - ក្រ.ពាក់ព័ន្ធ
- សិក្សាសមាហរណកម្មតំបន់ទេសចរណ៍សៀមរាបថ្មី ចូលក្នុងគម្រោងអភិវឌ្ឍន៍ក្រុងរុនតាឯកតេជោសែន	មិថុនា - ធ្នូ		
- រៀបចំគម្រោងសាកល្បងលើការរៀបចំភូមិទេសចរណ៍នៅក្នុងក្រុងរុនតាឯកតេជោសែន។	កញ្ញា - ធ្នូ		
▪ សិក្សាលទ្ធភាពកែលម្អហេដ្ឋារចនាសម្ព័ន្ធទៅកាន់គោលដៅទេសចរណ៍ និងបំពាក់បន្ថែមនូវសម្ភារទ្រទ្រង់នៅក្នុងក្រុងនិងផ្លូវទៅកាន់គោលដៅសំខាន់ៗ ជាអាទិ៍ ភ្លើងបំភ្លឺផ្លូវ បំពាក់ស្លាកសញ្ញាដូចខាងក្រោម៖		- Sub-DMO - គ.អ.ទ.ស.	- ក្រសួងសាធារណការនិងដឹកជញ្ជូន - រដ្ឋបាលខេត្តសៀមរាប - អាជ្ញាធរទន្លេសាប - ក្រ.ពាក់ព័ន្ធ - [illegible]
- **កំពង់ផែចុងឃ្នៀស : ១)-** ផ្លូវទឹកសម្រាប់កាណូតដឹកភ្ញៀវទេសចរនៅរដូវប្រាំង ទំហំទទឹង១២ម៉ និងបណ្តោយ៤០០០ម៉ ដោយត្រូវជីកស្តារជម្រៅ២ម៉ែត្របន្ថែមទៀត **២)-** ចំណតរថយន្តមានទំហំ៣០ម៉ និងបណ្តោយ៥០ម៉ (តូចចង្អៀត) និង **៣)-** ចំណតកាណូតនិងទូកមានទំហំតូចចង្អៀតនៅរដូវប្រាំងនិងរដូវវស្សា។	មករា - មេសា		

- **សហគមន៍ទេសចរណ៍កំពង់ភ្លុក** : **១)**- រៀបចំផ្លូវបេតុង១ខ្សែ ប្រវែង១៤គ.ម ចាប់ពីស្ពានទិនប់ទឹកវត្តរការហូតដល់ស្ពានដើមរាំងមួយដើម **២)**- រៀបចំមណ្ឌលព័ត៌មានសម្រាប់ដាក់តាំងឧបករណ៍នេសាទផ្សេងៗទៀត **៣)**- រៀបចំចំណតកាណូតនិងចំណតរថយន្ត១កន្លែង សម្រាប់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ ប្រវែង(២០០ម×២០០ម) **៤)**- រៀបចំបង្គន់អនាម័យចំនួន៦នៅកន្លែងលក់សំបុត្រ **៥)**- រៀបចំបង្គន់អនាម័យចំនួន៦នៅចំណតរថយន្ត **៦)**- រៀបចំសួនច្បារ១កន្លែង នៅក្បែរចំណតរថយន្តសម្រាប់ភ្ញៀវទេសចរ **៧)**- រៀបចំបច្ចេកទេសក្នុងការទុកដាក់សំរាម។	មករា - មេសា		
- **រមណីយដ្ឋានទឹកធ្លាក់ភ្នំគូលែននិងព្រះអង្គធំ** : ផ្លូវបេតុងប្រវែង១ ០០០ម៉ែត្រ ចំណតរថយន្តទំហំ៥០ម×១០០ម បន្ទប់ទឹកចំនួន២០បន្ទប់។	មករា - មេសា		
▪ សិក្សាគម្រោងប្លង់លម្អិតកែលម្អគោលដៅទេសចរណ៍អាទិភាព ដូចជា គម្រោងអភិវឌ្ឍន៍សង្កាត់ទេសចរណ៍ក្នុងក្រុងសៀមរាប (ផ្សារចាស់ វត្តរាជបូណ៌ និងវត្តព្រះព្រហ្មរ័ត្ន) គម្រោងលើកកម្ពស់ភាពទាក់ទាញទេសចរណ៍នៅតំបន់ចុងឃ្នៀស គម្រោងលើកកម្ពស់ភាពទាក់ទាញទេសចរណ៍នៅសហគមន៍ទេសចរណ៍ធម្មជាតិកំពង់ភ្លុក គម្រោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តម-"ភ្នំគូលែន" និងគម្រោងអភិវឌ្ឍន៍ផ្សាររាត្រីនិងវិថីម្ហូបអាហារ	មករា - ធ្នូ	- គ.អ.ទ.ស.	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - ទីស្តីការគណៈរដ្ឋមន្ត្រី - Sub-DMO - ក្រ.ពាក់ព័ន្ធ - វិស័យឯកជន
▪ សិក្សាគោលនយោបាយអនុគ្រោះបន្ថែមដល់ការវិនិយោគបង្កើតផលិតផលនិងសេវាកម្មទេសចរណ៍ថ្មីៗនៅខេត្តសៀមរាប ដោយផ្តល់អាទិភាពសម្រាប់រមណីយដ្ឋានកែច្នៃ អាជីវកម្មភោជនីយដ្ឋានកម្រិតស្តង់ដាខ្ពស់ ដូចជា ភោជនីយដ្ឋានចិន ឥណ្ឌា ជប៉ុន កូរ៉េ អឺរ៉ុប និងហាលឡាល់ នៅខេត្តសៀមរាប	មករា - មិថុនា	- ក្រសួងទេសចរណ៍ - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	- រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
▪ សិក្សាស្វែងរកដៃគូវិនិយោគបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋនៅក្នុងខេត្តសៀមរាប។	មករា - ធ្នូ	- ក្រសួងទេសចរណ៍ - ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - គ.អ.ទ.ស.	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន

វិធានការទី៧ - ពង្រឹងយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍គោលដៅទេសចរណ៍អាទិភាព			
▪ រៀបចំនិងពង្រឹងយន្តការគ្រប់គ្រងកម្រៃចូលទស្សនានៅតាមគោលដៅទេសចរណ៍អាទិភាពទាំងអស់	មករា - មិថុនា	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/គ្រឹះស្ថានអង្គរ - គ.អ.ទ.ស. - រដ្ឋបាលខេត្តសៀមរាប	- សហគមន៍ - វិស័យឯកជន
▪ ពិនិត្យឡើងវិញនូវគោលនយោបាយសំបុត្រអង្គរឱ្យស្របតាមនិន្នាការទេសចរណ៍ និងបរិបទជាក់ស្តែង	មករា - មីនា	- គ្រឹះស្ថានអង្គរ	- អាជ្ញាធរជាតិអប្សរា - គ.អ.ទ.ស. - រដ្ឋបាលខេត្តសៀមរាប
▪ បន្តពង្រឹងរចនាសម្ព័ន្ធ ធនធាន និងយន្តការ នៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ឱ្យស្របតាមតម្រូវការជាក់ស្តែង។	មករា - ធ្នូ	- ទីស្តីការគណៈរដ្ឋមន្ត្រី - គ.អ.ទ.ស. - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	- ក្រ.ពាក់ព័ន្ធ - វិស័យឯកជន
វិធានការទី៨ - ពិពិធកម្មផលិតផលទេសចរណ៍មានសក្តានុពលនៅខេត្តសៀមរាប			
▪ លើកទឹកចិត្តក្នុងការទាក់ទាញទេសចរណ៍ម៉ាយ (MICE) ក្នុងខេត្តសៀមរាប តាមរយៈ៖		- ក្រសួងទេសចរណ៍ - ក្រុមហ៊ុនវិនិយោគ	- គ.អ.ទ.ស. - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ - អាជ្ញាធរជាតិអប្សរា - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
- បង្កើតយន្តការសម្របសម្រួលការទាក់ទាញ និងរៀបចំព្រឹត្តិការណ៍ម៉ាយ (MICE) នៅខេត្តសៀមរាប អមជាមួយការផ្តល់ការលើកទឹកចិត្តដល់ភ្ញៀវទេសចរអន្តរជាតិនូវសំបុត្រចូលទស្សនាអង្គរដោយបង់កម្រៃតែពាក់កណ្តាល	មករា - ធ្នូ		
- សិក្សាបង្កើតមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍សៀមរាប-អង្គរ (Siem Reap-Angkor Convention and Exhibition Center) នៅទីតាំងអាកាសយានដ្ឋានអន្តរជាតិសៀមរាប (ចាស់) ឬទីតាំងសមស្របណាមួយនៅក្នុងក្រុងសៀមរាប។	មករា - ធ្នូ		

▪ រៀបចំព្រឹត្តិការណ៍ទាក់ទាញខ្នាតអន្តរជាតិខេត្តសៀមរាបៈ		- ក្រសួងទេសចរណ៍ - គ.ជ.អ.ក. - អាជ្ញាធរជាតិអប្សរា - រដ្ឋបាលខេត្តសៀមរាប	- គ.អ.ទ.ស. - ក្រ.ពាក់ព័ន្ធ - ស.ស.យ.ក. - វិស័យឯកជន
- ពិធីបុណ្យឆ្លងឆ្នាំសកល ឆ្នាំ២០២៥	មករា		
- ព្រឹត្តិការណ៍រត់ប្រណាំងចម្ងាយឆ្ងាយ "Angkor Ultra Trail"	កុម្ភៈ		
- ព្រឹត្តិការណ៍ព្រះអាទិត្យរះចំកណ្ដាលកំពូលប្រាសាទអង្គរវត្ត (Equinox)	មីនា / កញ្ញា		
- ព្រឹត្តិការណ៍រត់ប្រណាំងម៉ារ៉ាតុង (Marathon)	សីហា		
- ព្រឹត្តិការណ៍តន្ត្រីរបស់លោក Andrea Bocelli	កក្កដា - សីហា		
- ទិវារត់ប្រណាំងអន្តរជាតិពាក់កណ្ដាលម៉ារ៉ាតុង (International Angkor Half Marathon)	ធ្នូ		
- ព្រឹត្តិការណ៍ទេសចរណ៍ខ្នាតអន្តរជាតិផ្សេងៗ។	មករា - ធ្នូ		
▪ រៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ឆ្នាំ២០២៥	មេសា	- ស.ស.យ.ក.	- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/អាជ្ញាធរជាតិអប្សរា - ក្រសួងទេសចរណ៍ - រដ្ឋបាលខេត្តសៀមរាប
▪ កែលម្អផលិតផលដែលមានស្រាប់ រួមទាំងសណ្ឋាប់ធ្នាប់ សុវត្ថិភាព អនាម័យ និងបរិស្ថាន ព្រមទាំងបង្កើតផលិតផលទាក់ទាញថ្មីៗ (កីឡា ផ្សារទំនើប...)	មករា - ធ្នូ	- ក្រសួងទេសចរណ៍/គ.ជ.វ.ទ. - រដ្ឋបាលខេត្តសៀមរាប	- ក្រ.ពាក់ព័ន្ធ - វិស័យឯកជន
▪ រៀបចំទស្សនីយភាពអំពី **"គុនល្បុក្កតោ និងគុនខ្មែរបម្រុះ"** សម្រាប់ភ្ញៀវទេសចរ ឱ្យបានជាប្រចាំទាំងក្នុងទីក្រុង និងនៅទីលានជល់ដំរី។	មករា - ធ្នូ	- គ.ជ.អ.ក. - វិស័យឯកជន	- អាជ្ញាធរជាតិអប្សរា - រដ្ឋបាលខេត្តសៀមរាប
វិធានការទី៩ - កាត់បន្ថយភាពផ្ទុះផ្ដាយផ្នែកសេដ្ឋកិច្ចនៅក្នុងខ្សែច្រវាក់តម្លៃទេសចរណ៍			
▪ ពង្រឹងផលិតកម្មក្នុងស្រុក និងការអនុវត្តច្បាប់លើហាងលក់វត្ថុអនុស្សាវរីយ៍ក្លែងក្លាយៈ			

- គាំទ្រដល់និរន្តរភាពនៃសិប្បកម្ម និងផលិតករក្នុងស្រុក ទាំងផ្នែកធនធាន និងបច្ចេកទេសផលិត	មករា - ធ្នូ	- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ - ក្រសួងពាណិជ្ជកម្ម - ក្រសួងទេសចរណ៍	- គ.ជ.ភ.១ផ.១ - វិស័យឯកជន
- ជំរុញការដាក់លក់ផលិតផលក្នុងស្រុក តាមរយៈ ការផ្ដល់ស្លាកសញ្ញាទុកចិត្ត (Labelling on Quality Mark and/or Trust Marks)	មករា - មិថុនា		
- ពិនិត្យ ណែនាំ និងអនុវត្តពិន័យអន្តរការណ៍ចំពោះហាងលក់វត្ថុអនុស្សាវរីយ៍ ដែលលក់ផលិតផលក្លែងក្លាយ ដែលដាក់ការផលិតនៅកម្ពុជា	មករា - ធ្នូ		
- ជំរុញសិប្បកម្មផលិតវត្ថុអនុស្សាវរីយ៍ក្នុងស្រុកបម្រើឱ្យភ្ញៀវទេសចរ ក្នុងនោះលើកកម្ពស់ Artisans Angkor និងពង្រឹងការគ្រប់គ្រងហាងវត្ថុអនុស្សាវរីយ៍ អមជាមួយការបង្កើតម៉ាកសញ្ញាសម្រាប់ទទួលស្គាល់ហាងលក់វត្ថុអនុស្សាវរីយនៅខេត្តសៀមរាប។	មករា - មិថុនា		
▪ រៀបចំខ្សែក្រវាត់បៃតង (Green Belt) ក្នុងឧស្សាហកម្មទេសចរណ៍ ដើម្បីជំរុញការផ្គត់ផ្គង់កសិផលក្នុងស្រុក ដូចជា បន្លែ ផ្លែឈើ សាច់ និងផ្កា ដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ នៅខេត្តសៀមរាប តាមរយៈ ការរៀបចំវេទិកាផ្គូរផ្គងអាជីវកម្ម ឬជំនួបរវាងអ្នកលក់ និងអ្នកទិញ ការលើកកម្ពស់ផលិតផលកសិកម្ម ដែលមានតម្លៃបន្ថែមខ្ពស់ និងការអភិវឌ្ឍចង្កោមផលិតផលតាមមូលដ្ឋានក្រោមគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (AIMS) និងគម្រោងអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃនៅក្នុងឧស្សាហកម្មទេសចរណ៍ខេត្តសៀមរាប។	មករា - ធ្នូ	- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ - ក្រសួងពាណិជ្ជកម្ម	- ក្រសួងទេសចរណ៍ - រដ្ឋបាលខេត្តសៀមរាប - គ.អ.ទ.ស. - វិស័យឯកជន
វិធានការទី១០ - បង្កើនសហថាមភាពរវាងតំបន់បេតិកភណ្ឌអង្គរ និងតំបន់ទេសចរណ៍អាទិភាពផ្សេងទៀតក្នុងខេត្តសៀមរាប			
▪ រៀបចំផែនទីទេសចរណ៍សម្រាប់ខេត្តសៀមរាប និងតាមគោលដៅអាទិភាព ដោយបង្ហាញពីខ្សែទស្សនាចរណ៍ ព័ត៌មានគ្រប់ជ្រុងជ្រោយ និងមានភាពទាក់ទាញសម្រាប់ទេសចរជាតិ និងអន្តរជាតិ ដោយរៀបចំជាច្រើនភាសា និងច្រើនជម្រើស ទាំងទម្រង់ជាឯកសារបោះពុម្ព និងទម្រង់ឌីជីថល នូវ៖			
- **"ផ្លូវទស្សនាចរណ៍ទៅកាន់ទេសចរណ៍វប្បធម៌ បេតិកភណ្ឌ សាសនា និងជំនឿ"** សំដៅដល់ **១)**- ខ្សែទស្សនាចរណ៍បេតិកភណ្ឌពិភពលោក **២)**- ខ្សែទស្សនាចរណ៍បេតិកភណ្ឌប្រាសាទ	មករា - មិថុនា		

និងតំបន់ធម្មជាតិដ៏ពិសិដ្ឋនៃឧទ្យានជាតិភ្នំគូលែន ដែលមានសកម្មភាពផ្សារភ្ជាប់ជាមួយវត្ត អារាមនានា និង/ឬព្រឹត្តិការណ៍សាសនា ដែលឆ្លុះបញ្ចាំងពីសក្តានុពលនៃទេសចរណ៍សាសនា និងជំនឿ **៣)**- ផ្លូវទស្សនាចរណ៍សិក្សាស្វែងយល់និងស្រាវជ្រាវ ដោយផ្សារភ្ជាប់ជាមួយ សកម្មភាពទស្សនាតាមទីកន្លែងស្រាវជ្រាវ សារមន្ទីរអរិយធម៌ និងសារមន្ទីរជាច្រើនផ្សេងទៀត ក្នុងខេត្តសៀមរាប ដើម្បីពន្យល់អំពីអច្ឆរិយភាពរបស់អង្គរ និងអាចឱ្យភ្ញៀវស្វែងយល់ពីវប្បធម៌ អរិយធម៌ខ្មែរ ប្រវត្តិសាស្ត្រ ជំនឿ និងសាសនា និង **៤)**- ផ្លូវទស្សនាចរណ៍ផ្សារភ្ជាប់នឹង ឧស្សាហកម្មច្នៃប្រឌិត ដែលផ្សារភ្ជាប់នូវសកម្មភាពទេសចរណ៍នៅនឹងកន្លែង នៃសិប្បកម្ម ការផលិតវត្ថុអនុស្សាវរីយ៍ ការទស្សនាក្បាច់គុនល្បុក្កតោដែលមានអាយុកាលយូរលង់ណាស់ មកហើយ ការរៀបចំម្ហូបអាហារខ្មែរ និងចំណីអាហារពិសេសប្រចាំតំបន់ ជាដើម			
- **“ផ្លូវទស្សនាចរណ៍ទៅកាន់ទេសចរណ៍ធម្មជាតិ អេកូទេសចរណ៍”** សំដៅដល់ **១)**- ខ្សែទស្សនាចរណ៍ទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ដូចជា ការទស្សនាភូមិនេសាទ ភូមិបណ្តែតទឹក ដំណើរកម្សាន្តបែបឡើងភ្នំ និងដើរព្រៃ ការជិះទូកកម្សាន្តនៅកំពង់ភ្លុក សួនសត្វស្លាប និងសកម្មភាពកម្សាន្តជាច្រើនផ្សេងទៀត និង **២)**- ខ្សែទស្សនាចរណ៍ផ្សារភ្ជាប់នឹងសកម្មភាពកម្សាន្តដែលគិតគូរអំពីបរិស្ថានខ្ពស់ ដូចជាការចូលរួមដាំដើមឈើក្នុងសួនទេសចរណ៍ ឬទីតាំងនានាដែលមានការរៀបចំសម្រាប់ជាការចងចាំដ៏ល្អមួយដល់ភ្ញៀវទេសចរ និងការទស្សនា និងកម្សាន្តនៅក្នុងទីតាំង ឬតំបន់ទេសចរណ៍គ្មានការប្រើប្រាស់ប្លាស្ទិក ជាដើម។	មករា - មិថុនា	- ក្រសួងទេសចរណ៍	- គ.អ.ទ.ស. - អាជ្ញាធរជាតិអប្សរា - រដ្ឋបាលខេត្តសៀមរាប - អាជ្ញាធរទន្លេសាប - វិស័យឯកជន
- **“ផ្លូវទស្សនាចរណ៍ទៅកាន់ទេសចរណ៍ជនបទ និងកសិ-ទេសចរណ៍”** សំដៅដល់ **១)**- ខ្សែទស្សនាចរណ៍នៅតំបន់បឹងទន្លេសាបដែលពោរពេញដោយសត្វត្រីគ្រប់ប្រភេទ និង/ឬការទស្សនាសកម្មភាពនេសាទ របៀបរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរបែបសហគមន៍ទេសចរណ៍ ដែលគួរជាទីចាប់អារម្មណ៍ ប្រកបដោយទេសភាពធម្មជាតិដ៏ស្រស់ត្រកាល អាកាសធាតុ ខ្យល់បរិសុទ្ធ ភាពសម្បូរបែបនៃជីវៈចម្រុះ ដែលអនុញ្ញាតឱ្យភ្ញៀវទេសចរបានស្គាល់អំពីសក្តានុពល	មករា - មិថុនា		

នៃភាពជាខ្មែរ និង **២)**- ខ្សែទស្សនាចរណ៍នៅតំបន់បន្ទាយស្រី ដែលផ្សារភ្ជាប់គ្នារវាងប្រាសាទ និងសកម្មភាពទស្សនាទេសភាពកសិកម្មក្នុងតំបន់នោះ ជាអាទិ៍ ការជិះរទេះគោទស្សនាព្រឹត្តិការណ៍ប្រមូលផលកសិកម្ម ការទស្សនាការផលិតស្ករត្នោត និងតម្បាញផ្ដៅនៃស្រុកបន្ទាយស្រី ដំណាំស្រែចម្ការ កសិដ្ឋានចិញ្ចឹមត្រីធម្មជាតិ ផ្ទះស្នាក់ស្រុកបន្ទាយស្រី អមដោយការភ្លក់ម្ហូបអាហារខ្មែរ។ល។			
- **“ផ្លូវទស្សនាចរណ៍ទេសភាពទីក្រុងបេតិកភណ្ឌប្រវត្តិសាស្ត្រ និងភាពរីករាយ”** សំដៅដល់ **១)**- ខ្សែទស្សនាចរណ៍បេតិកភណ្ឌទីក្រុងប្រវត្តិសាស្ត្ររបស់ខេត្តសៀមរាប ដែលមានអគារបុរាណ និងដើមឈើចាស់ៗជាច្រើនដែលត្រូវបានអភិរក្ស ការទស្សនាសំណង់ស្ថាបត្យកម្មក្នុងវត្តអារាម និងសំណង់ក្នុងសម័យអាណានិគម ព្រះបរមរាជវាំង និងសារមន្ទីរនានា ជាពិសេសការទស្សនា និងកម្សាន្តតាមដងស្ទឹងសៀមរាប ដែលជាស្ទឹងប្រវត្តិសាស្ត្រមួយដ៏សំខាន់សម្រាប់ខេត្តសៀមរាប **២)**- ខ្សែទស្សនាចរណ៍ទេសចរណ៍បែបលម្ហែកាយ ដែលជាការដើរផ្សារទិញទំនិញវត្ថុអនុស្សាវរីយ៍ ភាពប្រណិតនៃសេវាកម្មទេសចរណ៍ សេវាកម្មកម្សាន្តមនុស្សពេញវ័យ និងភោជនីយដ្ឋានទេសចរណ៍ដែលមានគុណភាព និងបម្រើឱ្យគ្រប់ជាតិសាសន៍ **៣)**- ខ្សែទស្សនាចរណ៍ទេសចរណ៍ម៉ាយ (MICE) រួមមានព្រឹត្តិការណ៍សន្និសីទ កិច្ចប្រជុំនានា សិក្ខាសាលា ឬវេទិកា កម្រិតថ្នាក់ជាតិ តំបន់ និងអន្តរជាតិ អមជាមួយការរៀបចំព្រឹត្តិការណ៍ទាក់ទាញ ដូចជា ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ពិព័រណ៍ មហោស្រពវប្បធម៌អន្តរជាតិ និងការប្រគុំតន្ត្រីធំៗ ដែលមានបញ្ចូលលក្ខណៈសិល្បៈ និងតន្ត្រីខ្មែរ ជាដើម។	មករា - មិថុនា		
- **“ផ្លូវទស្សនាចរណ៍ទៅកាន់ទេសចរណ៍វ័យចំណាស់ ទេសចរណ៍សុខភាព និងទេសចរណ៍ផ្ទះទី២”** សំដៅដល់ **១)**- ខ្សែទស្សនាចរណ៍សម្រាប់ទេសចរវ័យចំណាស់ និងទេសចរណ៍សុខភាពដែលផ្សារភ្ជាប់នឹងសកម្មភាពកម្សាន្ត និងលម្ហែកាយ ដូចជា ការសម្រាកលំហែកាយនៅផ្ទះស្នាក់ធម្មជាតិ ការទទួលនូវសេវាកម្មស្ប៉ា និងម៉ាស្សាស្របតាមស្តង់ដាជាតិ និងអាស៊ាន ការធ្វើសមាធិនៅទីតាំងសមរម្យ ការបរិភោគម្ហូបអាហារដែលគ្មានជាតិគីមី ការទិញទំនិញសុខភាព និងសកម្មភាពកម្សាន្ត	មករា - មិថុនា		

ផ្សេងៗទៀត **២)-** ខ្សែទស្សនាចរណ៍ទេសចរណ៍សុខភាព ជាអាទិ៍ ការពិនិត្យសុខភាពនៅមន្ទីរពេទ្យ វេជ្ជសាស្ត្រ ឬគ្លីនិក ការទិញផលិតផលថែរក្សាសម្រស់ សេវាកម្មទន្តសាស្ត្រ ជាដើម និង **៣)-** ខ្សែទស្សនាចរណ៍បែបកីឡាដោយផ្សារភ្ជាប់ទៅនឹងការទស្សនាព្រឹត្តិការណ៍កីឡាជាតិ និងអន្តរជាតិធំៗ អមជាមួយការរៀបចំសកម្មភាពកីឡាទេសចរណ៍នៅក្នុងខេត្តសៀមរាប ដូចជា ជិះកង់កម្សាន្តគយគន់ទេសភាព រត់ប្រណាំងម៉ារ៉ាតុង (កម្រិតស្រាល) វាយកូនគោល ជាដើម ដើម្បីសុខភាព។			
▪ សហការជាមួយការីទេសចរណ៍ក្នុងការបញ្ចូលកញ្ចប់ទស្សនកិច្ចដោយមានតម្លៃសមរម្យសម្រាប់ភ្ញៀវទេសចរ ដែលមកទស្សនាខេត្តសៀមរាបនូវផ្លូវទស្សនាចរណ៍ខាងលើ	មករា - ធ្នូ	- ក្រសួងទេសចរណ៍	- គ.អ.ទ.ស. - Sub-DMO - វិស័យឯកជន
▪ រៀបចំប្រព័ន្ធទេសចរណ៍ធ្វើដំណើរដោយខ្លួនឯង (Self-driving tourists and FIT) សម្រាប់ទេសចរណ៍នៅខេត្តសៀមរាប។	មករា - មិថុនា	- គ.អ.ទ.ស.	- ក្រសួងទេសចរណ៍ - Sub-DMO
វិធានការទី១១ - បង្កើនសហថាមភាពរវាងខេត្តសៀមរាប និងគោលដៅអាទិភាពរបស់កម្ពុជា			
▪ បង្កើនសហថាមភាពផ្នែកទេសចរណ៍រវាងរាជធានីភ្នំពេញ -ខេត្តសៀមរាប		- ក្រសួងទេសចរណ៍	- គ.អ.ទ.ស. - អាជ្ញាធរជាតិអប្សរា - រដ្ឋបាលរាជធានីភ្នំពេញ - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
- ជំរុញការតភ្ជាប់ជើងហោះហើរ (Flight) ឱ្យមានតម្លៃសមរម្យ	មករា - ធ្នូ		
- រៀបចំរថយន្តទេសចរណ៍ (bus) ដែលធានាសុវត្ថិភាព និងគុណភាព	មករា - មេសា		
- រៀបចំសៀគ្វីទេសចរណ៍បេតិកភណ្ឌផ្សារភ្ជាប់នឹងទេសចរណ៍ទីក្រុង។	មករា - មិថុនា		
▪ បង្កើនសហថាមភាពផ្នែកទេសចរណ៍រវាងខេត្តព្រះសីហនុ -ខេត្តសៀមរាប		- ក្រសួងទេសចរណ៍	- គ.អ.ទ.ស. - អាជ្ញាធរជាតិអប្សរា - រដ្ឋបាលខេត្តសៀមរាប - រដ្ឋបាលខេត្តព្រះសីហនុ - វិស័យឯកជន
- ជំរុញការតភ្ជាប់ជើងហោះហើរ (Flight) ឱ្យមានតម្លៃសមរម្យ	មករា - ធ្នូ		
- រៀបចំរថយន្តទេសចរណ៍ (bus) ដែលធានាសុវត្ថិភាព និងគុណភាព	មករា - មេសា		
- រៀបចំសៀគ្វីទេសចរណ៍បេតិកភណ្ឌផ្សារភ្ជាប់នឹងទេសចរណ៍សមុទ្រ។	មករា - មិថុនា		

▪ បង្កើនសហថាមភាពផ្នែកទេសចរណ៍រវាងខេត្តសៀមរាប និងតំបន់ជុំវិញ		- គ.អ.ទ.ស.	- ក្រសួងទេសចរណ៍ - អាជ្ញាធរជាតិអប្សរា - រដ្ឋបាលខេត្តសៀមរាប - រដ្ឋបាលខេត្តពាក់ព័ន្ធ - វិស័យឯកជន
- បង្កើតសៀគ្វីទេសចរណ៍បេតិកភណ្ឌទេសចរណ៍ពិភពលោក (ព្រះវិហារ-សៀមរាប-កំពង់ធំ)	មករា - មិថុនា		
- បង្កើតសៀគ្វីទេសចរណ៍ខេត្តសៀមរាបភ្ជាប់នឹងបណ្ដាខេត្តជុំវិញ។	មិថុនា - ធ្នូ		
▪ បង្កើតបណ្ណទស្សនាសៀមរាប (Siem Reap Pass)។	មករា - កក្កដា	- គ.អ.ទ.ស.	- ក្រសួងទេសចរណ៍ - រដ្ឋបាលខេត្តសៀមរាប - Sub-DMO - គ្រឹះស្ថានអង្គរ - វិស័យឯកជន
វិធានការទី១២ - ពង្រឹងសេវាកម្ម និងឧស្សាហកម្មទេសចរណ៍ស្របតាមតម្រូវការភ្ញៀវទេសចរគ្រប់ប្រភេទ			
▪ សិក្សាធ្វើទំនើបកម្ម និងឌីជីថលូបនីយកម្មគោលដៅទេសចរណ៍ និងអាជីវកម្មទេសចរណ៍		- ក្រសួងទេសចរណ៍	- គ.ស.ធ.ឌ. - គ.អ.ទ.ស. - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ - ធនាគារជាតិនៃកម្ពុជា - រដ្ឋបាលខេត្តសៀមរាប - Sub-DMO - គ្រឹះស្ថាន[illegible] - វិស័យ[illegible]
- កែលម្អបទពិសោធទេសចរណ៍ និងជំរុញការប្រើប្រាស់បច្ចេកវិទ្យា នៅក្នុងការគ្រប់គ្រងគោលដៅទេសចរណ៍ គំរូអាជីវកម្មទេសចរណ៍ និងអាជីវកម្មក្នុងវិស័យគាំទ្រ ដើម្បីបង្កើនភាពទាក់ទាញរបស់ផលិតផល និងសេវាកម្មទេសចរណ៍នៅខេត្តសៀមរាប	មករា - ធ្នូ		
- បង្កើនការប្រើប្រាស់ប្រព័ន្ធទូទាត់ប្រាក់ជាឌីជីថលឱ្យបានទូលំទូលាយ	មករា - ធ្នូ		
- ពង្រឹងសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍ និងការផ្ដល់សេវាកម្មប្រកបដោយភាពកក់ក្ដៅនិងវិជ្ជាជីវៈ។	មករា - ធ្នូ		

▪ កម្មវិធីអភិវឌ្ឍន៍មូលធនមនុស្សដើម្បីភាពធន់និងចីរភាព	មករា - ធ្នូ	- គ.អ.ទ.ស. - ក្រសួងទេសចរណ៍	- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន - ដៃគូអភិវឌ្ឍ
▪ ពង្រឹងភាពធន់នៃឧស្សាហកម្មទេសចរណ៍នៅខេត្តសៀមរាប តាមរយៈ បន្តការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាប និងវិធានការអន្តរាគមន៍ផ្នែកពន្ធដារនានា ដាក់ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២៥។	មិថុនា - ធ្នូ	- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	- ក្រសួងទេសចរណ៍ - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
វិធានការទី១៣ - កាត់បន្ថយគម្លាតនៃដំណើរកម្សាន្តទេសចរណ៍រវាងរដូវភ្ញៀវតិច/រដូវកាលបៃតង (Green Season) និងរដូវភ្ញៀវច្រើន			
▪ ជំរុញការទាក់ទាញទីផ្សារទេសចរណ៍ដែលច្រើនមកទស្សនាខេត្តសៀមរាបនៅរដូវកាលភ្ញៀវតិច/រដូវកាលបៃតង ជាអាទិ៍៖ ទីផ្សារក្នុងតំបន់ ទីផ្សារអារ៉ាប់...	មករា - តុលា	- ក្រសួងទេសចរណ៍	- ក.ផ.ផ. - វិស័យឯកជន
▪ កំណត់ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំរបស់ខេត្តសៀមរាប និងទាក់ទាញការរៀបចំព្រឹត្តិការណ៍អន្តរជាតិ និងព្រឹត្តិការណ៍ថ្នាក់ជាតិ ព្រមទាំងព្រឹត្តិការណ៍នៅតាមមូលដ្ឋានក្រុង ស្រុក ឃុំ/សង្កាត់ ឱ្យមានក្នុងកំឡុងពេលរដូវកាលភ្ញៀវតិច/រដូវកាលបៃតង	មករា - កុម្ភៈ	-ក្រសួងទេសចរណ៍ -រដ្ឋបាលខេត្តសៀមរាប	-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ -ក្រ. ពាក់ព័ន្ធ -វិស័យឯកជន
▪ ដាក់ចេញយុទ្ធនាការបញ្ចុះថ្លៃលើគ្រប់សេវាទាំងអស់នៅរដូវកាលភ្ញៀវតិច ដូចជាបញ្ចុះតម្លៃលើសេវាកម្មដឹកជញ្ជូន មគ្គុទ្ទេសក៍ សំបុត្រចូលទស្សនា សេវាស្នាក់នៅ និងសេវាកម្សាន្តផ្សេងៗ ដោយផ្ទេករដ្ឋនិងឯកជនសហការបញ្ចុះតម្លៃព្រមគ្នាតែម្តង តាមរយៈការរៀបចំ **"កិច្ចសន្យាគោលដៅ"** អនុវត្តយុទ្ធនាការ **"ចុះថ្លៃ"** នៅរដូវកាលភ្ញៀវតិច/រដូវកាលបៃតង	មករា - មីនា	-ក្រសួងទេសចរណ៍ -គ្រឹះស្ថានអង្គរ	-គ.អ.ទ.ស. -រដ្ឋបាលខេត្តសៀមរាប -ក្រ. ពាក់ព័ន្ធ -វិស័យឯកជន

▪ សិក្សាផ្តល់ការលើកលែងកម្រៃទិដ្ឋាការទេសចរណ៍នៅក្នុងអំឡុងពេលរដូវកាលភ្ញៀវតិច/រដូវកាលបៃតង។	មករា - កុម្ភៈ	-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ -ក្រសួងមហាផ្ទៃ -ក្រសួងទេសចរណ៍/ក.ជ.ផ.
វិធានការទី១៤- បង្កើនការចងចាំល្អ ដោយផ្តល់បទពិសោធល្អដល់ភ្ញៀវទេសចរ			
▪ ដាក់ចេញយុទ្ធនាការ "**អង្គរ : គ្មានប្លាស្ទិក**" "**ភ្នំគូលែន : គ្មានប្លាស្ទិក**" "**ទន្លេសាប : គ្មានប្លាស្ទិក**" ត្រឹមឆ្នាំ២០៣០ សម្រាប់គោលដៅទេសចរណ៍សៀមរាប-អង្គរ	មករា - ធ្នូ	- ក្រសួងបរិស្ថាន	- អាជ្ញាធរជាតិអប្សរា - ក្រសួងទេសចរណ៍/គ.ជ.វ.ទ. - រដ្ឋបាលខេត្តសៀមរាប - អាជ្ញាធរទន្លេសាប - Sub-DMO - វិស័យឯកជន - សហគមន៍
▪ ពង្រឹងចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ**" និងជំរុញបដិសណ្ឋារកិច្ចល្អនៅតាមគ្រប់គោលដៅនិងសេវាកម្មទេសចរណ៍		- ក្រសួងទេសចរណ៍/គ.ជ.វ.ទ.	- អ.អ. / ក្រសួងមហាផ្ទៃ - អាជ្ញាធរជាតិអប្សរា - វិស័យឯកជន - សហគមន៍ - រដ្ឋបាលខេត្តសៀមរាប - Sub-DMO
- បង្កើនគុណភាពបដិសណ្ឋារកិច្ច ផ្តល់ដោយមន្ត្រីអន្តោប្រវេសន៍	មករា - ធ្នូ		
- បង្កើនគុណភាពបដិសណ្ឋារកិច្ច និងផ្តល់ភាពជឿជាក់ដល់ភ្ញៀវទេសចរ ដោយអ្នកបើកបរ និងសេវាដឹកជញ្ជូនទេសចរណ៍ អ្នកបើកកាណូតនៅបឹងទន្លេសាប មន្ត្រីត្រួតពិនិត្យសំបុត្រចូលទស្សនាតាមប្រាសាទ អ្នកបម្រើសេវាកម្មនៅគ្រប់មូលដ្ឋានអាជីវកម្មទេសចរណ៍	មករា - ធ្នូ		
- លើកទឹកចិត្តឱ្យមានជម្រើសមធ្យោបាយដឹកជញ្ជូនច្រើនសម្រាប់ទេសចរ	មករា - មិថុនា		
- ពង្រឹងគុណភាព អនាម័យ និងការផ្តល់សេវាកម្មល្អ និងបដិសណ្ឋារកិច្ចល្អ។	មករា - ធ្នូ		

វិធានការទី១៥- ពង្រឹងសន្តិសុខនិងសណ្តាប់ធ្នាប់			
▪ ពង្រឹងសន្តិសុខ សុវត្ថិភាព និងភាពកក់ក្តៅដល់ភ្ញៀវទេសចរនៅតាមគោលដៅទេសចរណ៍ ក្នុងនោះ ត្រូវបង្កើតប្រព័ន្ធទូរសព្ទទំនាក់ទំនងHotline ការពង្រឹងសមត្ថភាពសង្គ្រោះ ការបំពាក់កាមេរ៉ាសុវត្ថិភាពនៅទីតាំងសំខាន់ៗ	មករា - ធ្នូ	- ក្រសួងមហាផ្ទៃ / ន.ប.ជ.ក.	- រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
▪ ពង្រឹងសណ្តាប់ធ្នាប់ក្នុងក្រុងសៀមរាប ពិសេសពង្រឹងការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនទេសចរណ៍គ្រប់ប្រភេទនៅខេត្តសៀមរាប។	មករា - ធ្នូ	- ក្រសួងមហាផ្ទៃ / ន.ប.ជ.ក.	- រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
វិធានការទី១៦- បង្កើនការទទួលខុសត្រូវរបស់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប			
▪ បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ដើម្បីពង្រឹងអនុលោមភាព និងគុណភាពឧស្សាហកម្មទេសចរណ៍នៅខេត្តសៀមរាប ជាអាទិ៍ ការលុបបំបាត់កញ្ចប់ទេសចរណ៍ "ថ្លៃសូន្យ" (Zero-Cost Tour) ការឆបោកភ្ញៀវទេសចរ បទល្មើស និងឧក្រិដ្ឋកម្មនានា ក្នុងវិស័យទេសចរណ៍	មករា - ធ្នូ	- ក្រសួងទេសចរណ៍	- ក្រសួងពាណិជ្ជកម្ម - ក្រសួងមហាផ្ទៃ / ន.ប.ជ.ក. - រដ្ឋបាលខេត្តសៀមរាប - ក្រ.ពាក់ព័ន្ធ - វិស័យឯកជន
▪ ពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍នៅខេត្តសៀមរាប តាមរយៈការប្រឡងប្រណាំងអាជីវកម្មឆ្នើម ដោយប្រើប្រាស់ប្រព័ន្ធចំណាត់ថ្នាក់ និងស្តង់ដាគុណភាពទេសចរណ៍ដាក់ចេញដោយថ្នាក់ជាតិនិងអាស៊ាន	មករា - ធ្នូ	- ក្រសួងទេសចរណ៍	- រដ្ឋបាលខេត្តសៀមរាប - Sub-DMO - វិស័យឯកជន
▪ រៀបចំនិងជំរុញការអនុវត្តក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ សម្រាប់សេវាកម្មទេសចរណ៍	មករា - ធ្នូ	- ក្រសួងទេសចរណ៍	- រដ្ឋបាលខេត្តសៀមរាប - Sub-DMO - វិស័យឯកជន

▪ ពង្រឹងការគ្រប់គ្រងសេវាកម្រៃជើងសា (Commission) និងសេវាកម្រៃបន្ថែម (Service Charge) នៅក្នុងវិស័យទេសចរណ៍។	មករា - ធ្នូ	- រដ្ឋបាលខេត្តសៀមរាប	- ក្រសួងទេសចរណ៍ - ក្រសួងពាណិជ្ជកម្ម - វិស័យឯកជន
វិធានការទី១៧ - អង្កេតស្ដីពីភាពពេញចិត្តរបស់ភ្ញៀវទេសចរ			
▪ រៀបចំអង្កេត និងសិក្សាវាយតម្លៃពីភាពពេញចិត្តរបស់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ នៅតាមគោលដៅអាទិភាព ដើម្បីបានជាមូលដ្ឋានក្នុងការដាក់ចេញនូវយុទ្ធសាស្ត្រទាក់ទាញ បង្កើនគុណភាពបដិសណ្ឋារកិច្ច និងការរៀបចំសម្បទាសមស្រប សំដៅទាក់ទាញឱ្យភ្ញៀវទេសចរមកម្ដងទៀត	មករា - ធ្នូ	- គ.អ.ទ.ស.	- ក្រសួងទេសចរណ៍ - អាជ្ញាធរជាតិអប្សរា - រដ្ឋបាលខេត្តសៀមរាប - Sub-DMO - វិស័យឯកជន
▪ រៀបចំការវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងសំខាន់ៗ ពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាបតាមការចាំបាច់។	មករា - ធ្នូ	- គ.អ.ទ.ស.	- ក្រ.ពាក់ព័ន្ធ - រដ្ឋបាលខេត្តសៀមរាប
ចង្កោមទី២ - ទាក់ទាញភ្ញៀវទេសចរក្នុងស្រុក[5] មកទស្សនាខេត្តសៀមរាប			
វិធានការគន្លឹះទី៦ - បង្កើនភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរជាតិមកទស្សនាខេត្តសៀមរាប			
វិធានការទី១៨ - រៀបចំ និងសម្រួលឱ្យមានការធ្វើចលនាទេសចរណ៍ផ្ទៃក្នុងទៅកាន់ខេត្តសៀមរាបឱ្យបានកាន់តែច្រើន			
▪ សហការជាមួយការីទេសចរណ៍ និងទីភ្នាក់ងារទេសចរណ៍ក្នុងស្រុក រៀបចំកញ្ចប់ទស្សនកិច្ចក្នុងស្រុក ដែលមានថ្លៃសមរម្យ ប្លែកៗ ចម្រុះ និងប្រកបដោយគុណភាព សម្រាប់ភ្ញៀវទេសចរក្នុងស្រុក	មករា - មិថុនា	- ក្រសួងទេសចរណ៍	- រដ្ឋបាលខេត្តសៀមរាប - អាជ្ញាធរជាតិអប្សរា - Sub-DMO - វិស័យឯកជន

5 *ភ្ញៀវទេសចរក្នុងស្រុក សំដៅលើភ្ញៀវទេសចរជាតិ និងភ្ញៀវបរទេសផ្ទៃក្នុងដែលស្នាក់នៅកម្ពុជា។*

▪ បង្កើនសកម្មភាពកម្សាន្តសម្រាប់ទេសចរជាលក្ខណៈគ្រួសារ ដែលអាចបំពេញតម្រូវការបានទាំងឪពុក ម្តាយ កូន និងក្មេងតូចៗ ព្រោះថាភ្ញៀវទេសចរប្រភេទនេះយកចិត្តទុកដាក់ខ្ពស់ចំពោះភាពរីករាយរបស់សមាជិកគ្រួសារទាំងមូលក្នុងអំឡុងពេលដំណើរកម្សាន្ត	កុម្ភៈ - កញ្ញា	- ក្រសួងទេសចរណ៍	- រដ្ឋបាលខេត្តសៀមរាប - អាជ្ញាធរជាតិអប្សរា - Sub-DMO - វិស័យឯកជន
▪ បញ្ចូលកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់សិស្ស-និស្សិត និងគ្រូបង្រៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលនានាទៅតំបន់បេតិកភណ្ឌអង្គរ ខេត្តសៀមរាប	មករា - ធ្នូ	- ក្រសួងអប់រំ យុវជន និងកីឡា - ក្រសួងទេសចរណ៍	- វិស័យឯកជន - អាជ្ញាធរជាតិអប្សរា - រដ្ឋបាលខេត្តសៀមរាប - គ្រឹះស្ថានបណ្តុះបណ្តាល
▪ បញ្ចូលកម្មវិធីទស្សនកិច្ចសម្រាប់មន្ត្រីរាជការរបស់ក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិទៅតំបន់បេតិកភណ្ឌអង្គរ ខេត្តសៀមរាប	មករា - ធ្នូ	- ក្រ.ពាក់ព័ន្ធ - ក្រសួងទេសចរណ៍	- រដ្ឋបាលខេត្តសៀមរាប - រដ្ឋបាលថ្នាក់ក្រោមជាតិ
▪ បញ្ចូលកម្មវិធីទស្សនកិច្ចសម្រាប់បុគ្គលិកក្នុងវិស័យឯកជន ទៅតំបន់បេតិកភណ្ឌអង្គរ ខេត្តសៀមរាប	មករា - ធ្នូ	- ក្រសួងទេសចរណ៍ - វិស័យឯកជន	- សភាពាណិជ្ជកម្ម - រដ្ឋបាលខេត្តសៀមរាប
▪ រៀបចំនិងជំរុញការប្រើប្រាស់ "**បណ្ណដំណើរកម្សាន្ត**" ដែលមានតម្លៃសមរម្យសម្រាប់ភ្ញៀវទេសចរជាតិពិសេសសម្រាប់មន្ត្រីរាជការ កងកម្លាំងសមត្ថកិច្ច គ្រូបង្រៀន កម្មករ-កម្មការិនី	មករា - មិថុនា	- ក្រសួងទេសចរណ៍	- វិស័យឯកជន - Sub-DMO
▪ បន្តពិនិត្យលើការបន្ធូរបន្ថយកម្រៃសម្រាប់សេវាកម្មទេសចរណ៍នៅតាមគោលដៅទេសចរណ៍សំខាន់ៗក្នុងខេត្តសៀមរាបឱ្យមានតម្លៃសមរម្យសម្រាប់ភ្ញៀវទេសចរជាតិ (ឧទា. តម្លៃជិះទូកនៅចុងឃ្នៀស[6]...)	មករា - ធ្នូ	-ក្រសួងទេសចរណ៍ -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/គ្រឹះស្ថានអង្គរ -រដ្ឋបាលខេត្តសៀមរាប	-ក្រ.ពាក់ព័ន្ធ -វិស័យឯកជន -សហគមន៍
▪ បន្តជំរុញគម្រោងសាងសង់ផ្លូវល្បឿនលឿនពីរាជធានីភ្នំពេញ-ខេត្តសៀមរាប។	មករា - ធ្នូ	- ក្រសួងសាធារណការ និងដឹកជញ្ជូន	- ក្រុមហ៊ុនសាងសង់ផ្លូវល្បឿនលឿន (CRBC) - រដ្ឋបាលខេត្តសៀមរាប

[6] គ្រឹះស្ថានអង្គរបានកែសម្រួលការងារនេះ ក្រោយទទួលបានការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**។

វិធានការទី១៩ - ដាក់ចេញយុទ្ធសាស្ត្រលើកកម្ពស់ការយល់ដឹងជាសាធារណៈ			
▪ ពង្រឹងយុទ្ធនាការ **"ទស្សនាស្រុកយើង"** ក្រោមស្មារតី **"ស្រលាញ់ជាតិ ត្រូវស្គាល់ទឹកដី"** និង **"ទេសចរណ៍ផ្សារភ្ជាប់ទឹកដី និងធម្មជាតិ"**	មករា - ធ្នូ	- ក្រសួងទេសចរណ៍	- ក. ផ. ផ. - ក្រ. ពាក់ព័ន្ធ - វិស័យឯកជន
▪ បង្កើតនូវបទសម្ភាសន៍ជាមួយបុគ្គលសំខាន់ៗនៅក្នុងវិស័យទេសចរណ៍ ដូចជា ថ្នាក់ដឹកនាំ មន្ត្រី អ្នកជំនាញប្រតិបត្តិករទេសចរណ៍ និងភាគីពាក់ព័ន្ធ មកពីវិស័យរដ្ឋនិងឯកជន ដែលមានភាពជោគជ័យ នៅក្នុងកម្មវិធីទូរទស្សន៍និងវិទ្យុល្បីៗជាប្រចាំ ដើម្បីលើកទឹកចិត្តឱ្យប្រជាពលរដ្ឋស្វែងយល់និងចូលរួមចំណែកនៅក្នុងសកម្មភាពអភិវឌ្ឍន៍វិស័យទេសចរណ៍	មករា - ធ្នូ	- ក្រសួងទេសចរណ៍	- ក. ផ. ផ. - ក្រសួងព័ត៌មាន - វិស័យឯកជន
▪ បំផុសចលនាផ្សព្វផ្សាយ តាមរយៈប្រជាពលរដ្ឋម្ចាស់ស្រុក និងម្ចាស់អាជីវកម្ម ដោយ **"អ្នកស្រុកណាផ្សាយពីស្រុកនោះ"** និង **"អាជីពណា ផ្សាយពីអាជីពនោះ"** ស្របតាមទស្សនាទាន **"ទេសចរណ៍ដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីទេសចរណ៍"** និង **"ម្នាក់ៗ ជាអ្នកផ្សព្វផ្សាយទេសចរណ៍កម្ពុជាម្នាក់"** ដែលជាការផ្សព្វផ្សាយបង្ហោះដោយខ្លួនឯងលើបណ្តាញសង្គម ដូចជា ការថតពីសកម្មភាពកម្សាន្តទេសភាពរបស់ទីតាំង រូបភាព និងវីដេអូ អមជាមួយការពិពណ៌នាខ្លីៗ	មករា - ធ្នូ	- ក្រសួងទេសចរណ៍	- រដ្ឋបាលខេត្តសៀមរាប - អ្នកសារព័ត៌មាន - ប្រជាពលរដ្ឋ - វិស័យឯកជន
▪ ការរំលេចសាច់រឿង (Feature Stories) ដើម្បីបង្កើនចំណាប់អារម្មណ៍របស់សាធារណជននៅក្នុងការធ្វើដំណើរកម្សាន្តផ្ទៃក្នុង ដោយត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចជា៖		- ក្រសួងទេសចរណ៍	- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/អាជ្ញាធរជាតិអប្សរា - ក្រសួងព័ត៌មាន - ក្រ. ពាក់ព័ន្ធ - វិស័យឯកជន
- លើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ឱ្យមានការសរសេរជាអត្ថបទរំលេចអំពីប្រភេទទេសចរណ៍ដែលទាក់ទាញចំណាប់អារម្មណ៍របស់អ្នកអាន	មករា - មិថុនា		
- ជំរុញការផលិតខ្សែភាពយន្តដែលបង្ហាញពីគោលដៅទេសចរណ៍អាទិភាពសំខាន់ៗក្នុងខេត្តសៀមរាប	មករា - ធ្នូ		

- ផលិតវីដេអូអំពីគោលដៅសក្តានុពលទេសចរណ៍ក្នុងខេត្តសៀមរាប និងចម្រៀងទេសចរណ៍ ដើម្បីចាក់ផ្សាយតាមបណ្តាញស្ថានីយទូរទស្សន៍ និងប្រព័ន្ធបណ្តាញសង្គមនានា	មេសា - សីហា		- ក្លឹបអ្នកកាសែតកម្ពុជា - បុគ្គលល្បីៗ - សិល្បករ សិល្បការិនី - ពិធីករ ពិធីការិនី - អ្នកថតរូប
- ជំរុញការផ្សព្វផ្សាយ ការផលិតរូបភាព វីដេអូ និងមាតិកាទេសចរណ៍ ការអប់រំ និងបញ្ជ្រាបការយល់ដឹងជាសាធារណៈអំពីវិស័យទេសចរណ៍ តាមរយៈបុគ្គលដែលមានឥទ្ធិពល (Influencers) និងអ្នកផលិតរូបភាព និងវីដេអូជំនាញ នៅលើប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គម (YouTube, Facebook, Tiktok, Instagram, X ...) និងប្រព័ន្ធផ្សព្វផ្សាយនានា។	មករា - ធ្នូ		
វិធានការទី២០ - លើកទឹកចិត្តការរៀបចំកម្មវិធីផ្សេងៗ ដូចជាកិច្ចប្រជុំនិងសិក្ខាសាលានៅខេត្តសៀមរាបនារដូវភ្ញៀវតិច			
▪ រៀបចំព្រឹត្តិការណ៍និងកម្មវិធីកម្សាន្តឱ្យបានច្រើននៅរដូវកាលភ្ញៀវតិច	មិថុនា - កញ្ញា	- ក្រសួងទេសចរណ៍	- ក្រ. ពាក់ព័ន្ធ - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
▪ ទាក់ទាញការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា នៅខេត្តសៀមរាប ជាពិសេសនារដូវភ្ញៀវតិច តាមរយៈកិច្ចសហការជាមួយវិស័យឯកជនក្នុងការបង្កើតកម្មវិធីផ្តល់ជូនក្នុងតម្លៃពិសេស។	មិថុនា - កញ្ញា	- ក្រសួងទេសចរណ៍ - គ.អ.ទ.ស.	- ក្រ. ពាក់ព័ន្ធ - រដ្ឋបាលខេត្តសៀមរាប - វិស័យឯកជន
វិធានការទី២១ - បន្តបង្កើនភាពទាក់ទាញតាមរយៈការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ធំៗប្រចាំឆ្នាំក្នុងខេត្តសៀមរាបឱ្យបានច្រើន			
▪ ក្រៅពីព្រឹត្តិការណ៍ទេសចរណ៍អន្តរជាតិ (ដូចមានចង្អុលក្នុងវិធានការទី៨) ត្រូវរៀបចំព្រឹត្តិការណ៍ទេសចរណ៍ប្រចាំឆ្នាំផ្សេងៗទៀតក្នុងខេត្តសៀមរាបឱ្យបានច្រើន ជាអាទិ៖	[redacted]	- ក្រសួងទេសចរណ៍ - វិស័យឯកជន	- ក្រសួងអប់រំ យុវជន និងកីឡា - ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/អាជ្ញាធរជាតិ... - ក្រសួង... សា...
- ព្រឹត្តិការណ៍ទេសចរណ៍ បុណ្យទាន ប្រពៃណី ពិធីបុណ្យ និងព្រឹត្តិការណ៍សាសនាផ្សេងៗ (ដូចជាបដិបត្តិសមាធិ និងពិធីរាប់បាត្រព្រះសង្ឃ ជាដើម)	មករា - ធ្នូ		
- ព្រឹត្តិការណ៍កីឡា ពិសេសព្រឹត្តិការណ៍កម្រិតថ្នាក់ជាតិ ដូចជា ព្រឹត្តិការណ៍ជិះកង់ និងរត់ម៉ារ៉ាតុង	មករា - ធ្នូ		
- ទិវាអន្តរជាតិកីឡាយ៉ូហ្គា	មិថុនា		

- ព្រឹត្តិការណ៍ **"ស្នាមញញឹមនៃកម្ពុជា"**	មករា - ធ្នូ		- រដ្ឋបាលខេត្តសៀមរាប - គ.ជ.ប.អ. - គ.ជ.អ.ក. - ស.ស.យ.ក.
- សិក្សាបង្កើតកម្មវិធី ឬបុណ្យថ្មីៗផ្សារភ្ជាប់នឹងទេសចរណ៍ប្រចាំឆ្នាំសម្រាប់ខេត្តសៀមរាប ដូចជា បុណ្យតន្ត្រី ពិធីបុណ្យពន្លឺអង្គរ។ល។	មករា - ធ្នូ		
វិធានការទី២២ - ទាក់ទាញភ្ញៀវទេសចរជាប្រជាពលរដ្ឋខ្មែររស់នៅក្រៅប្រទេស មកទស្សនាខេត្តសៀមរាប			
▪ ពង្រឹង និងបង្កើនការផ្សព្វផ្សាយទាក់ទាញប្រជាពលរដ្ឋខ្មែរ និងសហគមន៍ខ្មែរដែលរស់នៅក្រៅប្រទេស តាមរយៈ៖		- ក្រសួងទេសចរណ៍	- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ / ស្ថានតំណាងកម្ពុជានៅបរទេស - យុវជនគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស (CPP) - ស.ស.យ.ក.
- បំផុស និងលើកទឹកចិត្តឱ្យមកទស្សនាទឹកដីអង្គរដែលជាដែនដីមាតុភូមិ ក្រោមយុទ្ធនាការផ្សព្វផ្សាយ **"ស្រឡាញ់ជាតិ ត្រូវស្គាល់ទឹកដី"**	មករា - ធ្នូ		
- ជំរុញឱ្យមានការចូលរួមផ្សព្វផ្សាយអំពីរូបភាពវិជ្ជមានរបស់ទឹកដីកំណើតខ្លួន និងសក្ដានុពលទេសចរណ៍របស់ខេត្តសៀមរាប តាមរយៈការដាក់ចេញនូវយន្តការលើកទឹកចិត្តនានាដល់ប្រជាពលរដ្ឋខ្មែរ និងសហគមន៍ខ្មែរដែលរស់នៅក្រៅប្រទេស ដើម្បីអាចអញ្ជើញមកឱ្យឃើញពីការអភិវឌ្ឍក្រោមម្លប់នៃសុខសន្តិភាពដោយផ្ទាល់ភ្នែក។	មករា - ធ្នូ		
វិធានការគន្លឹះទី៧ - បង្កើនភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុង			
វិធានការទី២៣ - បង្កើតខ្សែទស្សនកិច្ចស្វែងយល់បេតិកភណ្ឌពិភពលោករបស់កម្ពុជាសម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុង			
▪ រៀបចំខ្សែទស្សនកិច្ចស្វែងយល់បេតិកភណ្ឌពិភពលោកនៅខេត្តសៀមរាបសម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុង។	មករា - ធ្នូ	- ក្រសួងទេសចរណ៍/ ក.ផ.ផ.	- រដ្ឋបាលខេត្តសៀមរាប - អាជ្ញាធរជាតិអប្សរា - [illegible]

វិធានការទី២៤- ពង្រឹង និងបង្កើនការផ្សព្វផ្សាយទាក់ទាញភ្ញៀវទេសចរបរទេសផ្ទៃក្នុង			
▪ ជំរុញ និងលើកទឹកចិត្តឱ្យមានដំណើរកម្សាន្តទេសចរណ៍សម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុង តាមរយៈការរៀបចំកញ្ចប់ទស្សនកិច្ចទេសចរណ៍បេតិកភណ្ឌពិភពលោក ដោយយករមណីយដ្ឋានអង្គរជាអ័ក្សស្នូល ផ្សារភ្ជាប់ជាមួយប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក និងរមណីយដ្ឋានទេសចរណ៍សំខាន់ៗផ្សេងទៀត ដោយអាចឱ្យភ្ញៀវទេសចរបរទេសផ្ទៃក្នុងទស្សនាបានច្រើនដង ក្នុងតម្លៃសមរម្យ	មករា-ធ្នូ	- ក្រសួងទេសចរណ៍/ ក.ផ.ផ.	-រដ្ឋបាលខេត្តសៀមរាប -វិស័យឯកជន
▪ បន្តការបង្កើនភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុងមកកាន់ខេត្តសៀមរាប ដោយផ្តោតលើការផ្តល់ជម្រើសបន្ថែមនៃប្រភេទបណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ដូចករណីដែលគ្រឹះស្ថានអង្គរបានដាក់ចេញនូវកម្មវិធីស្នើសុំបណ្ណចូលទស្សនារមណីយដ្ឋានអង្គរ និងប្រាសាទកោះកេរ ដោយឥតបង់ថ្លៃ ដែលអាចធ្វើតាមអនឡាញ សម្រាប់ជនបរទេសដែលបានរស់នៅក្នុងប្រទេសកម្ពុជាចាប់ពី២ឆ្នាំឡើងទៅ។	មករា-ធ្នូ	-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / គ្រឹះស្ថានអង្គរ	-ក្រសួងទេសចរណ៍ -អាជ្ញាធរជាតិអប្សរា -រដ្ឋបាលខេត្តសៀមរាប

សរុបរួម វិធានការគន្លឹះមានចំនួន **៧** និងវិធានការចំនួន **២៤** ចែកជា **៧៣**សកម្មភាព។

សម្គាល់ : អក្សរកាត់ឈ្មោះស្ថាប័ន

- **ក.ផ.ផ.** = ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា
- **ក.អ.ក.** = ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- **អ.អ.** = អគ្គនាយកដ្ឋានអន្តោប្រវេសន៍
- **ន.ប.ជ.ក.** = អគ្គស្នងការដ្ឋាននគរបាលជាតិ
- **ឧ.ជ.ភ.គ.** = ឧទ្យានជាតិភ្នំគូលែន
- **ក្រ.ពាក់ព័ន្ធ** = ក្រសួង - ស្ថាប័នពាក់ព័ន្ធ
- **ស.ស.យ.ក.** = សហភាពសហព័ន្ធយុវជនកម្ពុជា
- **គ.ជ.អ.ក.** = គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា
- **គ.ជ.ភ.១ ផ.១** = គណៈកម្មាធិការជាតិជំរុញចលនា ភូមិ១ ផលិតផល១
- **គ.អ.ទ.ស.** = គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- **គ.ស.ធ.ឌ.** = គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល
- **គ.ជ.ប.អ.** = គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ
- **គ.ជ.វ.ទ.** = គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- **គ.អ.ច.ទ.** = គណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរនិងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិនិងច្រកទ្វារអន្តរជាតិទូទាំងប្រទេស
- **គ.អ.រ.ព.ស.** = គណៈកម្មការអន្តរក្រសួងដើម្បីរៀបចំនិងអភិវឌ្ឍទីប្រជុំជនវុនតាឯក និងទីប្រជុំជនពាក់ស្នែង ខេត្តសៀមរាប
- **Sub-DMO** = អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក

៣៣/៣៣

ព្រះរាជាណាចក្រកម្ពុជា * ទីស្តីការគណៈរដ្ឋមន្ត្រី *

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៦០........សហវ.ប្រក.

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងជំនួយការបុរេប្រទាន និងជំនួយការបុរេប្រទានរង ប្រចាំនៅអង្គភាពថវិកាពហុកីឡដ្ឋានជាតិ នៃក្រសួងអប់រំ យុវជន និងកីឡា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្ម មាត្រា៩និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បកចុះថ្ងៃទី២០ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២៥៩ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងថវិកា គណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៧១ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុ ជូនមន្ត្រីហិរញ្ញវត្ថុ ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់ គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងពហុកីឡដ្ឋានជាតិ នៃក្រសួងអប់រំ យុវជន និងកីឡា។

សម្រេច

ប្រការ១ ._

ត្រូវបានតែងតាំងមន្ត្រីជាប់កិច្ចសន្យា នៅពហុកីឡដ្ឋានជាតិ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

១.លោក **ឈុន លាងផេង** មុខងារ ជាមន្ត្រីផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ ជារដ្ឋទេយ្យករបុរប្រទាន នៅពហុកីឡដ្ឋានជាតិ នៃក្រសួងអប់រំ យុវជន និងកីឡា

២.លោក **ផេង ស៊ីទី** មុខងារ ជាមន្ត្រីផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ ជារដ្ឋទេយ្យករបុរប្រទានរង នៅពហុកីឡដ្ឋានជាតិ នៃក្រសួងអប់រំ យុវជន និងកីឡា

៣.កញ្ញា **ឈាន ពុទ្ធី** មុខងារ ជាមន្ត្រីផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ ជារដ្ឋទេយ្យករបុរប្រទានរង នៅពហុកីឡដ្ឋានជាតិ នៃក្រសួងអប់រំ យុវជន និងកីឡា។

ប្រការ២ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣._

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងពហុកីឡដ្ឋានជាតិ នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៤កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០២៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

កន្លែងទទួល

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ក្រសួងអប់រំ យុវជន និងកីឡា
-ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៣
-រាជកិច្ច
-ឯកសារ
-កាលប្បវត្តិ

រក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី